ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Oct-2012, 13:31
CMS/CFO: Uch Arun

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០៩ នាទី**

**សវនាការលើកទី១១៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល *(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក នួន ជា | ខ្មែរ |

# ឧបសម្ព័ន្ធ

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការចំនួនពីរ។ ទី១ គឺអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅលោកជនជាប់ចោទ នួន ជា ដើម្បីមានឱកាសក្នុងការធ្វើការកត់សម្គាល់ ឬក៏ធ្វើសេចក្តីថ្លែងការណ៍តបទៅនឹងបណ្តាខណ្ឌ ទាំងឡាយ ដែល -- នៃដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានសម្រេចលើកយកមកធ្វើសវនាការ វគ្គ៣ នៃសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះបានចាត់ឲ្យក្រឡាបញ្ជីសវនាការអាននូវបណ្តាកថា ខណ្ឌពាក់ព័ន្ធទៅនឹងបញ្ហានេះ នៅកាលពីដើមសប្តាហ៍មុន ហើយនិងកាលពីរសៀលម្សិលមិញ។

[០៩:១០:៥៥]

នេះជាដំណាក់កាលនៃសវនាការវគ្គទី១ លើកលែងតែលោក នួន ជា គាត់ផ្លាស់ប្តូរនូវគំនិតរបស់ គាត់ក្នុងការឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលនឹងអាចសួរដោយចៅក្រមនៃអង្គជំនុំជម្រះ ឬក៏ភាគី ដែលពាក់ព័ន្ធនឹងបញ្ហានេះ ចំពោះអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការសម្រាប់ វគ្គ៣ នៃសំណុំរឿង០០២/០១ នោះកិច្ចដំណើរការនីតិវិធីនៃការសួរដេញដោលចំពោះជនជាប់ចោទលើ អង្គហេតុនេះ អង្គជំនុំជម្រះនឹងដំណើរការ។ ហើយប្រសិនបើពុំដូច្នោះទេ គឺអង្គជំនុំជម្រះនឹងដំណើរការ តាមកាលវិភាគដែលបានគ្រោងទុក នូវដំណើរការសវនាការថ្ងៃនេះ ដែលបានជម្រាបជូនរួចហើយ គឺ អង្គជំនុំជម្រះនឹងធ្វើសវនាការការដាក់បង្ហាញឯកសារដោយចៅក្រមអង្គជំនុំជម្រះ ឬភាគីនូវឯកសារ ដែលចៅក្រម ឬភាគីនីមួយៗយល់ឃើញថា ជាឯកសារពាក់ព័ន្ធបំផុត ទៅនឹងអង្គហេតុរចនាសម្ព័ន្ធរដ្ឋ បាល នៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចបានបញ្ជាក់នៅក្នុងសេចក្តីណែនាំ ដែលអង្គជំនុំជម្រះបានចេញ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១២ ទាក់ទងនឹងកាលវិភាគនៃការធ្វើសវនាការ បន្ទាប់ពីថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ២០១២ ឯកសារ E233។

គោលបំណងនៃឯកសារនេះ គឺមិនមែនដើម្បីបើកការជជែកវែកញែកជាថ្មី ពាក់ព័ន្ធនឹងភាពអាច ទទួលយកបាននៃឯកសារណាមួយ ដែលត្រូវបានស្នើដាក់ចំពោះមុខអង្គជំនុំជម្រះឡើយ។ អង្គជំនុំជម្រះ

នឹង បានដឹងថា ឯកសារជាច្រើនដែលបានលើកឡើងកន្លងមកនៅក្នុងសវនាការ គឺមានសារៈសំខាន់ ប៉ុន្តែនៅក្នុងការពិភាក្សាដេញដោលជាក់ស្តែងនៅក្នុងសវនាការនោះ ឯកសារទាំងនោះមិនអាចឲ្យសាធារណជនទទួលបាននូវព័ត៌មានគ្រប់គ្រាន់ទាំងអស់នោះទេ។

[០៩:១៣:០១]

បន្ថែមលើនេះទៀត ដោយសារឯកសារមានចំនួនច្រើន ដូចបានដាក់ដោយភាគីនានានាពេលសវនាការ រហូត -- ហេតុដូច្នេះ វាជាការប្រសើរណាស់សម្រាប់អង្គជំនុំជម្រះក្នុងការទទួលបាននូវការបញ្ជាក់ពីភាគី នូវចំនួនឯកសារនានាក្នុងកម្រិតមួយជាក់លាក់ ឯកសារដាក់បន្ទុក ឯកសារដោះបន្ទុកដែលពាក់ព័ន្ធនឹងវគ្គនៃសវនាការដែលត្រូវបានបញ្ចប់នេះ។

ដើម្បីឲ្យសាធារណជនបានជ្រាបកាន់តែច្បាស់ អង្គជំនុំជម្រះនឹងផ្តល់ឱកាសដល់ភាគីនានា ដែលបង្ហាញនូវចំនួនឯកសារជាក់លាក់នានាដល់អង្គជំនុំជម្រះ និងគូសបញ្ជាក់នូវផ្នែកពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ជនជាប់ចោទត្រូវបានអនុញ្ញាតផងដែរ ក្នុងការធ្វើការកត់សម្គាល់ ឬក៏ធ្វើអត្ថាធិប្បាយទៅលើឯកសារនានា ប្រសិនបើជនជាប់ចោទមានបំណងធ្វើដូច្នេះ។ ការធ្វើដូច្នេះ នឹងជួយសម្រួលដល់អង្គជំនុំ-ជម្រះក្នុងការកំណត់នូវឯកសារសំខាន់ៗ ទាំងឯកសារដោះបន្ទុក ឯកសារដាក់បន្ទុក ទៅតាមករណីពាក់ព័ន្ធនីមួយៗ។

[០៩:១៤:០៩]

អង្គជំនុំជម្រះសង្ឃឹមថា ភាគីនីមួយៗនឹងជ្រើសរើសយកតែឯកសារសំខាន់ៗជាក់លាក់មួយចំនួនដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកមួយនៃសវនាការវគ្គ២នេះតែប៉ុណ្ណោះ។ អង្គជំនុំជម្រះក៏ស្នើសុំទៅភាគីផងដែរ ចៀសវាងនូវការដែលលើកឡើងយកឯកសារដដែលៗ ហើយក៏មិនគប្បីជ្រើសរើសយកឯកសារទាំងឡាយណា ដែលត្រូវបានលើកយកមកពិភាក្សាដោយលម្អិតរួចហើយ នៅក្នុងសវនាការដែលបានធ្វើរហូតមកដល់ពេលបច្ចុប្បន្ននេះ។

បាទ នេះជាគោលបំណងនៃដំណើរការសវនាការនេះ អាចចំណាយពេលប្រហែលជា៣ ទៅ ៤ ថ្ងៃ តាមស្ថានភាពនៃលទ្ធភាពក្នុងការឯកសារ ចំនួនឯកសារដែលភាគីនឹងលើកឡើងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬក៏អង្គជំនុំជម្រះដាក់ឯកសារចំពោះមុខភាគីនោះទេ។

បាទ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ីៈ**

សូមអរគុណលោកប្រធាន។ សួស្តីអស់លោក លោកស្រី ភាគីទាំងអស់។ ខ្ញុំមានចំណុចខ្លីៗនោះទេ។ ខ្ញុំបានប្រឹក្សាជាមួយនឹងកូនក្តីរបស់ខ្ញុំ មុនពេលដែលយើងចាប់ផ្តើមសវនាការនេះ គាត់ថាគាត់ត្រូវការ៥នាទី កូនក្តីរបស់ខ្ញុំ។

[០៩:១៥:៤០]

ចំពោះសំណើរបស់ខ្ញុំពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតឡើងកាលពីម្សិលមិញ ជាពិសេសបញ្ហានៃការស្តាប់ចម្លើយសាក្សី។ នៅក្នុងខែកក្កដា អង្គជំនុំជម្រះបានសម្រេចថា យើងអាចយើងទទួលការមានសិទ្ធិសួរព័ត៌មានដែលមាននៅក្នុងឯកសារ មិនមាននៅចំពោះមុខអង្គជំនុំជម្រះ ដរាបណាយើងមិនដកស្រង់ខ្លឹមសារ ឬក៏យោងទៅលើឯកសារនោះដោយផ្ទាល់។

កាលពីម្សិលមិញអង្គជំនុំជម្រះបានបង្គាប់ឡើងថា សំណួរទាំងឡាយ គ្រប់សំណួរទាំងអស់ដែលសួរទៅកាន់សាក្សីត្រូវតែជាប់ទាក់ទងយ៉ាងជាក់លាក់ទៅនឹងឯកសារ។ នេះជាអ្វីដែលអង្គជំនុំជម្រះបានលើកឡើង ហើយយើងគឺមានកាតព្វកិច្ចត្រូវយោងទៅលើឯកសារនេះ។ ដូច្នេះហើយគឺខ្ញុំមិនដឹងថាវាលក្ខណៈយ៉ាងម៉េចចំពោះចំណុចហ្នឹងនោះទេ។ ប៉ុន្តែវាច្បាស់ណាស់សម្រាប់ភាគីទាំងអស់ នៅក្នុងសវនាការ ហើយវាជាសេចក្តីបង្គាប់របស់អង្គជំនុំជម្រះ ជាសេចក្តីសម្រេចរួមពាក់ព័ន្ធទៅនឹងចំណុចនេះ។

[០៩:១៦:៥៦]

សូមឲ្យលោក លោកចៅក្រមពិចារណាទៅលើចំណុចខុសគ្នានេះ ពីរនេះ យ៉ាងម៉េចដែរ ទៅលើចំណុចហ្នឹង? ហើយសូមឲ្យជួយបញ្ជាក់បំភ្លឺជូនភាគីឲ្យបានយល់ច្បាស់ផងដែរ។

ចំណុចទី៣ ពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងកាលពីម្សិលមិញ ខ្ញុំបានមើលសៀវភៅកំណត់ហេតុរបស់ខ្ញុំ ខ្ញុំនឹងទៅញូវយ៉ក ក្នុងចុងខែនេះ ហើយប្រសិនបើអង្គជំនុំជម្រះនឹងដាក់ពាក្យប្តឹងដោយលាយលក្ខណ៍អក្សរចំពោះខ្ញុំនោះ គឺថាខ្ញុំរីករាយណាស់ ខ្ញុំអាចយកពាក្យប្តឹងនេះយកទៅដាក់ទីនោះដោយផ្ទាល់ជូនអង្គជំនុំជម្រះតែម្តង។ ខ្ញុំរីករាយ និងស្វាគមន៍ ប្រសិនបើអង្គជំនុំជម្រះចង់ដាក់ពាក្យប្តឹងជាលាយលក្ខណ៍អក្សរ ខ្ញុំអាចយកជូនទៅបាន។

នៅពេលនេះ គឺខ្ញុំសូមអនុញ្ញាតសូមឲ្យអង្គជំនុំជម្រះផ្តល់វេទិកានេះជូនទៅកាន់កូនក្តីរបស់ខ្ញុំ។ សូមអរគុណ។

[០៩:១៨:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ប៉ុន្តែយើងសម្រាប់ជម្រាបលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ថា យើងមានមធ្យោបាយគ្រប់គ្រាន់ហើយ មិនបាច់ពឹងលោកទេ លើៗការធ្វើការងាររបស់យើង។ ទី២ សំណើអម្បាញ់មិញនេះ លោកសរសេរជាលាយលក្ខណ៍អក្សរឲ្យបានច្បាស់លាស់ ពីព្រោះយើងបានជម្រាបហើយ ថាតម្រូវឲ្យសរសេរលាយលក្ខណ៍អក្សរឲ្យបានច្បាស់លាស់ នូវសំណើផ្សេងៗដើម្បីបង្ហាញអំពីបញ្ហាដែលជួបប្រទះ ហើយនិងសំអាងហេតុផ្សេងៗ ដល់ពេលអង្គជំនុំជម្រះសម្រេចទៅវិញតបទៅវិញទៅ ឲ្យមានសំអាងហេតុដូចគ្នា។ ចៀសវាងលោកមេធាវីលើកឡើងនូវសំណួមពរត្រួសៗអ៊ីចឹងទៅ ដល់ពេលអង្គជំនុំជម្រះសម្រេចទៅ ថាអង្គជំនុំជម្រះសម្រេចហ្នឹងគ្មានសំអាងហេតុ។ នេះដែលយើងបានកត់សម្គាល់។ អ៊ីចឹងហើយយើងបានកំណត់រួចហើយ ថាសំណើសុំរបស់មេ -- របស់ភាគីដែលពាក់ព័ន្ធត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ។ ហើយបញ្ហានេះដូចយើងបាននិយាយញឹកញាប់ហើយ ហើយរំឭកកាលមុនប្រាប់លោកថា គប្បីប្រើប្រាស់នូវអ្វីដែលបានអង្គជំនុំជម្រះបានណែនាំឲ្យបានត្រឹមត្រូវ។

[០៩:១៩:០៧]

ទី១ មុននឹងនិយាយអ្វីត្រូវតែកំណត់នូវរបៀបវារៈ ឬក៏កម្មវត្ថុនៃបញ្ហាឲ្យបានច្បាស់លាស់ជាមុនសិន ដើម្បីអង្គជំនុំជម្រះកំណត់ថាឲ្យលោកនិយាយតទៅទៀត ឬក៏មិនឲ្យនិយាយ។

បញ្ហាទី២ សំណើសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដើម្បីដោះស្រាយបញ្ហាឲ្យវាមានតម្លាភាព ឲ្យវាភាពត្រឹមត្រូវ ចៀសវាងមានការទិតៀនពីភាគីពាក់ព័ន្ធ ដូចបញ្ហាកើតកន្លងមក។

លោក នួន ជា អង្គជំនុំជម្រះសម្រេចតាមសំណើសុំរបស់លោក ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកលោកថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍ ឬការកត់សម្គាល់ណាមួយក្រៅពីបណ្តាកថាខណ្ឌ ដែលបានបង្ហាញអំពីអង្គហេតុដែលបានចោទប្រកាន់លើជនជាប់ចោទ ដែលបានអានដោយក្រឡាបញ្ជីសវនាការកាលពីដើមសប្តាហ៍មុន និងកាលពីរសៀលម្សិលមិញឡើយ។ នេះជាបញ្ហាដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍តបទៅនឹងការចោទ -- បណ្តាកថាខណ្ឌដែលចោទប្រកាន់ទៅលើជនជាប់ចោទ ដោយអនុវត្តតាមវិធាន៨៩ស្ទួន អនុវិធាន២ នៃវិធានផ្ទៃក្នុងរបស់អង្គ-ជំនុំជម្រះ។

តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោក នួន ជា ដើម្បីមានឱកាសនៅក្នុងការធ្វើសេចក្តីតប ឬក៏ថ្លែងការណ៍តបនេះ ប៉ុន្តែមុននឹងផ្តល់វេទិកាជូនទៅលោក នួន ជា យើងចង់សួរមួយសំណួរ ថាតើលោកត្រៀមខ្លួនហើយឬនៅ នៅក្នុងការឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលអាចនឹងចោទសួរដោយអង្គជំនុំជម្រះ ឬក៏ភាគីដែលពាក់ព័ន្ធទៅនឹងការជំនុំជម្រះសំណុំរឿង០០២/០១ វគ្គ៣នេះ។

លោកឆ្លើយនឹងសំណួរនេះជាមុនសិន មុននឹងលោកផ្តល់ -- ធ្វើសេចក្តីថ្លែងការណ៍។

[០៩:២១:៥០]

**លោក នួន ជា៖**

គោរពលោកប្រធាន! ដោយសុខភាពខ្ញុំមិនស្រួល ខ្ញុំសូមប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយ។

គោរពលោកប្រធាន! បន្ទាប់ពីបានស្តាប់ការអានដីកាដំណោះស្រាយដែលចោទប្រកាន់មកលើរូបខ្ញុំ។ ខ្ញុំសូមបំភ្លឺនូវចំណុចមួយចំនួនអំពីតួនាទីរបស់ខ្ញុំ ជាពិសេសនៅក្នុងកថាខណ្ឌ១២១, ១២២, ១២៣, ៨៧៣ ដល់៨៨១ និងកថាខណ្ឌទាំងឡាយណាដែលចោទប្រកាន់ពីតួនាទីរបស់ខ្ញុំក្នុងគណៈកម្មាធិការយោធា និងមន្ទីរស-២១ និងបណ្តា និងបញ្ហាសន្តិសុខ។ ខ្ញុំសូមបដិសេធថា ខ្ញុំមិនដែលជាសមាជិកក្នុងគណៈកម្មាធិការនេះទេ។ ដូចគ្នានេះដែរ ខ្ញុំក៏ពុំមានតួនាទីអីគ្រប់គ្រងលើមន្ទីរស-២១ នោះទេ។

សូមគោរពលោកប្រធាន។ ចប់។

[០៩:២៣:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អរគុណណាស់។ ដោយសារលោកបានបង្ហាញជំហរច្បាស់លាស់ហើយក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ នេះជាសិទ្ធិរបស់លោក ដែលមានចែងនៅក្នុងច្បាប់ ហើយនិងវិធានផ្ទៃក្នុង។

អង្គជំនុំជម្រះសូម -- មុននឹងផ្តល់វេទិកាជូនទៅចៅក្រមនៃអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធ អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ចំពោះការដាក់ឯកសារនេះ សហព្រះរាជអាជ្ញាមានពេលវេលា១ថ្ងៃកន្លះ ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាកន្លះថ្ងៃ ក្នុងការបង្ហាញឯកសាររបស់ខ្លួន។ ចំណែកឯមេធាវីការពារក្តីទាំងបីក្រុមមានពេល២ថ្ងៃ ដើម្បីបង្ហាញឯកសាររបស់ខ្លួន។ ពេលវេលាដែលបានបែងចែកសម្រាប់មេធាវីការពារក្តីនេះ គិតបញ្ចូលទាំងឱកាសរបស់ជនជាប់ក្នុងការធ្វើសេចក្តីអត្ថាធិប្បាយតាមការស្នើសុំទៅលើឯកសារណាមួយដែលត្រូវបានបង្ហាញ ឬដែលត្រូវ

បានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលសវនាការក្នុងដំណាក់កាលនេះ។

[០៩:២៤:២៩]

ដូចដែលបានលើកឡើងក្នុងសេចក្ដីណែនាំ អង្គជំនុំជម្រះនឹងទុកឱកាសឲ្យជនជាប់ចោទ អៀង សារី នាពេលបន្ទាប់មកទៀត ដើម្បីពិនិត្យឯកសារនានាដែលត្រូវបានបង្ហាញនៅក្នុងសវនាការនេះ ប្រសិនបើមានសំណើសុំ។ ហើយទន្ទឹមនេះ អង្គជំនុំជម្រះក៏សូមស្នើឲ្យមេធាវីការពារក្ដីទាំងបីក្រុមចង្អុលបង្ហាញថាតើខ្លួនបានធ្វើការបែងចែកពេលវេលាយ៉ាងដូចម្ដេចក្នុងការ -- ក្នុងចំណោមមេធាវីទាំងបីក្រុម ក្រោយពេលមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបញ្ចប់នូវការបង្ហាញឯកសាររបស់គាត់។

ហើយមុននឹងផ្ដើមនូវកិច្ចដំណើរការ អង្គជំនុំជម្រះសូមរំឭកដល់ជនជាប់ចោទ លោក នួន ជា និងលោក ខៀវ សំផន ដែលអង្គជំនុំជម្រះបានដឹងច្បាស់អំពីប្រសិទ្ធ -- ប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប មិនធ្វើអត្ថាធិប្បាយអ្វីផ្សេងៗ ចំពោះកិច្ចដំណើរការពិភាក្សាដេញដោលក្នុងដំណាក់កាលនេះ ហើយចំពោះលោក អៀង សារី គឺគាត់បានបង្ហាញជំហររបស់គាត់ច្បាស់ហើយថា គាត់ប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួររហូត។

ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ជនជាប់ចោទថា អង្គជំនុំជម្រះរៀបចំនូវកិច្ចដំណើរការនីតិវិធីនៃការដាក់ឯកសារភស្តុតាងចំពោះមុខអង្គជំនុំជម្រះ ហេតុដូច្នេះជនជាប់ចោទមានឱកាសនៅក្នុងការធ្វើការកត់សម្គាល់ ឬក៏ការធ្វើសេចក្ដីអត្ថាធិប្បាយផ្សេងៗ ទៅលើឯកសារដែលអង្គជំនុំជម្រះនឹងដាក់ ឬភាគីនឹងដាក់ចំពោះមុខអង្គជំនុំជម្រះ។ នេះជាសិទ្ធិរបស់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទមានបំណងប្រើសិទ្ធិនេះ។

[០៩:២៥:៥៨]

អង្គជំនុំជម្រះសូមបញ្ជាក់ថា ការស្នើឲ្យជនជាប់ចោទធ្វើសេចក្ដីអត្ថាធិប្បាយលើឯកសារ ឬកត់សម្គាល់លើឯកសារណាមួយនោះ មិនមែនជាការដាក់កាតព្វកិច្ច ឬគាបសង្កត់ទៅលើជនជាប់ចោទនោះទេ។ តែនេះគឺជាការគោរពសិទ្ធិ និងជាការផ្ដល់ឱកាសឲ្យគាត់ ប្រសិនបើគាត់មានបំណងធ្វើដូច្នេះ។

លោក នួន ជា ហើយនិងលោក ខៀវ សំផន តើលោកមានបំណងធ្វើការកត់សម្គាល់ ឬ អត្ថាធិប្បាយលើឯកសារដែលចៅក្រមនៃអង្គជំនុំជម្រះ ឬក៏ភាគីដែលនឹងដាក់បង្ហាញដែរឬទេ? មុន លោក នួន ជា មុន។

[០៩:២៧:០១]

**លោក អេនគ្រូ អ៊ីនូហ្សឹ៖**

សូមអរគុណលោកប្រធាន។ យើងកំពុងតែប្រឹក្សាយោបល់ជាមួយនឹងកូនក្តីរបស់ខ្ញុំនៅឡើយ។ ហើយថាតើគាត់នឹងមានវត្តនៅទីនេះ ឬក៏យ៉ាណា? យើងនៅតែជជែកនៅលើបញ្ហាសិទ្ធិ និងផលប្រយោជន៍របស់កូនក្តីរបស់យើងខ្ញុំនៅពេលដែលយើង -- មុនពេលដែលយើងលើកឡើងអំពីបញ្ហាឯកសារ។ ហើយខ្ញុំក៏មិន នៅតែមិនយល់ថាតើយើងនឹងធ្វើអ្វីក្នុងរយៈពេល៤ថ្ងៃនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ លោក ខៀវ សំផន មិនធ្វើមតិយោបល់អ្វីទេនៅក្នុងដំណាក់កាលនេះ។ ហើយយើងខ្ញុំសូមបញ្ជាក់ផងដែរថា យោងទៅតាមលក្ខណៈរឹតត្បិត ពីព្រោះថាយើងមិនអាចជជែកតវ៉ាពាក់ព័ន្ធទៅនឹងការដាក់ឯកសារនោះ។ ដូច្នេះយើងមិនទាន់ចង់ដាក់ឯកសារអ្វីនោះទេ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយស្តាយដែរ ដោយសារកិច្ចការនេះ អង្គជំនុំជម្រះបានធ្វើរួចមកនៅក្នុងការបញ្ចប់កិច្ចពិភាក្សាដេញដោលវគ្គ១។ ហើយមិនត្រឹមតែប៉ុណ្ណោះទេ អង្គជំនុំជម្រះបានធ្វើសេចក្តីណែនាំរួចហើយនៅក្នុងសេចក្តីអនុស្សារណៈរបស់ខ្លួន ឯកសារ E233 ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១២។ ហើយស្រាប់តែមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ឡើងថាខ្លួនមិនដឹងថា តើនីតិវិធីនៃការដាក់ឯកសារនេះ ធ្វើអ្វីខ្លះ? ហើយធ្វើយ៉ាងម៉េចនោះទេ? យើងក៏មិនដឹងដែរ ហើយយើងក៏មិនចាំបាច់ពន្យល់ដែរ ព្រោះកិច្ចដំណើរការនេះបានប្រព្រឹត្តទៅរួចហើយនៅកាលបញ្ចប់វគ្គ១ ហើយនិងមានលិខិតណែនាំដើម្បីធ្វើកិច្ចការនេះនៅក្នុងឯកសារបានជម្រាបជូនរួចហើយ។

[០៩:២៩:៣០]

**លោក អេនគ្រូ អ៊ីនូហ្សឹ៖**

ខ្ញុំសូមបញ្ជាក់ចំណុចមួយចំនួន។ ខ្ញុំមិនយល់អនុស្សារណៈរបស់លោកប្រធាន គឺឯកសារ E233 នេះ ហើយខ្ញុំមិនយល់គំនិតនៅក្នុងអនុស្សារណៈនេះ។ ហើយមិនមែនថា ខ្ញុំមិនយល់ពេលនេះត្រូវធ្វើអ្វីនោះទេ។ គឺខ្ញុំមិនយល់អនុស្សារណៈនេះ គឺចង់បានន័យថាយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ យើងមិនដែលឮសោះតាំងពីចេញអនុស្សរណៈមករហូតដល់ពេលនេះ។ ប្រសិនបើលោកមិនយល់គួរតែត្រូវបានឲ្យយើងពន្យល់ នៅក្នុងអំឡុងពេលដែលលោកទទួលពីដំបូង មិនមែនដល់ម៉ោងនេះទើបតែលោកនោះទេ ពីព្រោះលោកបានទទួលដូចភាគីពាក់ព័ន្ធដទៃទៀតដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣២:០១]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅខាងតំណាងសហព្រះរាជអាជ្ញា បានរៀបចំនូវឯកសារសម្រាប់ដាក់ចំពោះមុខអង្គជំនុំជម្រះតាមសេចក្ដីណែនាំឯកសារ E233 របស់អង្គជំនុំជម្រះហើយឬនៅ?

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន យើងខ្ញុំបានផ្ដល់ឯកសារទៅឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់នូវបញ្ជីឯកសារដែលយើងខ្ញុំយកមកបង្ហាញនៅក្នុងរយៈពេល ១ថ្ងៃកន្លះនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយចុះក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមទោសចំពោះការមកយឺតយ៉ាវរបស់ខ្ញុំ ដោយសារស្ទះចរាចរ។ ឯកសារដែលយើងខ្ញុំត្រៀម យើងខ្ញុំបានផ្ញើរួចហើយជូនទៅភាគី។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីដាក់បង្ហាញឯកសារចំពោះមុខអង្គជំនុំជម្រះ។

[០៩:៣៣:៣៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ថ្ងៃនេះ ខ្ញុំចាប់ផ្ដើមពិនិត្យមើលយ៉ាងឆាប់រហ័សទេ នូវការបង្ហាញនៅថ្ងៃនេះ និងថ្ងៃស្អែក ដែលជាពេលវេលារបស់សហព្រះ

រាជអាជ្ញា។ ការបង្ហាញឯកសារនេះ គឺថាវាពាក់ព័ន្ធទៅនឹងឯកសារចោទប្រកាន់សំខាន់ៗនៅក្នុងដីកាដំណោះស្រាយ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង ហើយយើងខ្ញុំនឹងចែកទៅជាបីផ្នែក។ ផ្នែកទី១ ដែលខ្ញុំ និងសហការីរបស់ខ្ញុំផ្តល់ជូននោះគឺ នឹងផ្តោតទៅលើតួនាទីរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា រួមទាំងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេច និងការទំនាក់ទំនងនៅក្នុងជួរបក្ស ក៏ដូចជាទំនាក់ទំនងផ្សេងៗទៅដល់អង្គការដទៃៗទៀតក្នុងទម្រង់របស់បក្សកុម្មុយនីស្តកម្ពុជា។

[០៩:៣៤:៣៩]

ការបង្ហាញទី២ គឺនឹងបង្ហាញឡើងដោយសហការីរបស់ខ្ញុំ តំណាងសហព្រះរាជអាជ្ញាមួយរូបទៀត គឺយើងផ្តោតទៅលើឯកសារពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រួមទាំងមុខងារ និងប្រតិបត្តិការរបស់ក្រសួងចំនួនបួន ក្រសួងការបរទេស ពាណិជ្ជកម្ម ឃោសនាការ និង សង្គមកិច្ច។ ហើយថាតើក្រសួងទាំងបួននេះ រាយការណ៍ជូនទៅដល់ថ្នាក់ដឹកនាំបក្ស ក៏ដូចជាការអនុវត្តគោលនយោបាយបក្សដោយរបៀបណានោះ។ ទី៣ ដែលជាទីចុងក្រោយ គឺផ្តោតទៅលើឯកសារទាក់ទងទៅនឹងប្រព័ន្ធទំនាក់ទំនង រួមទាំងចំណុចលម្អិតនៃសារទូរលេខ ក៏ដូចជារបាយការណ៍ដែលផ្ញើពីភូមិភាគ ក៏ដូចជាមកពីតំបន់ ទៅថ្នាក់លើ ហើយរបាយការណ៍របស់រដ្ឋាភិបាល ដើម្បីឱ្យបានស្វែងយល់អំពីគណៈកម្មាធិការមជ្ឈិមនេះ។ ហើយពេលនោះ ក៏នឹងឃើញឧទាហរណ៍មួយចំនួននិយាយអំពីរបាយការណ៍មកពីថ្នាក់ឃុំ ថ្នាក់ស្រុក ជូនទៅថ្នាក់តំបន់ ដើម្បីបង្ហាញថាតើរបាយការណ៍ទាំងអស់ហ្នឹងបង្ហាញជូនទៅដល់ថ្នាក់លើដោយរបៀបណា និងមកដល់ថ្នាក់លើខ្ពស់បំផុតនៅទីក្រុងភ្នំពេញ។

[០៩:៣៥:៥៧]

ឯកសារដែលត្រូវបង្ហាញរបស់ព្រះរាជអាជ្ញា ថាតើអង្គការសំខាន់ៗដែលបង្កើតបានជារបបកម្ពុជាប្រជាធិបតេយ្យនេះ ដោយរបៀបណា? ហើយថាតើព័ត៌មាននេះ ត្រូវបានបញ្ជូនទៅដល់ថ្នាក់លើទៅដល់ថ្នាក់មជ្ឈិមដោយរបៀបណា? ហើយថាតើគោលនយោបាយត្រូវបានផ្សព្វផ្សាយពីមជ្ឈិម ទៅដល់មូលដ្ឋាន ដើម្បីអនុវត្តបានដោយរបៀបណា?

ឥឡូវនេះ ខ្ញុំសូមជូនវេទិកានេះ ជូនទៅតំណាងសហព្រះរាជអាជ្ញាជាតិ ដើម្បីឱ្យគាត់បង្ហាញនូវឯកសារពាក់ព័ន្ធទៅនឹងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម។ សូមអរគុណ។

[០៩:៣៦:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាជាតិ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

ហើយជាបឋម ខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ ដែលមានវត្តមាននៅទីនេះ។

នៅពេលនេះ ខ្ញុំនឹងធ្វើការបទបង្ហាញដូចដែលសហការីខ្ញុំបានជម្រាបជូនអម្បាញ់មិញ គឺទាក់ទង ទៅនឹងតួនាទីជាទូទៅ និងសមាសភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈមជ្ឈិម នៃបក្ស កុម្មុយនីស្តកម្ពុជា។

ជាដំបូង ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញនូវឯកសារនៅលើអេក្រង់នូវឯកសារមួយ ចំនួន ដែលមានការពាក់ព័ន្ធទៅនឹងការបទបង្ហាញរបស់ខ្ញុំនេះ។ ហើយឯកសារដំបូង គឺមានលេខ E3/130។ ឯកសារនេះ មានចំណងជើងថា "លក្ខន្តិកបក្ស -- លក្ខន្តិកបក្សកុម្មុយនីស្តកម្ពុជា" បាទ។

[០៩:៣៧:៤១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតសូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

ឯកសារនេះ មានការទាក់ទងទៅនឹងតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈកម្មាធិការ មជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា នៅត្រង់មាត្រា៧ ចំណុចទី១ នៃលក្ខន្តិកបក្ស បានចែងថា "ក្នុងរយៈ ពេលពីមហាសន្និបាតមួយទៅមួយទៀត មានអង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុត សម្រាប់ទូទាំង ប្រទេស គឺគណៈកម្មាធិការមជ្ឈិម"។ ហើយនៅក្នុងមាត្រា៨ នៃលក្ខន្តិកបក្សនេះ ក៏បានចែងដែរថា "ចំពោះតំបន់ណា ឬអង្គការណា ដែលមានកល្លណៈពិសេសខាងនយោបាយក្តី ខាងយោធាក្តី ខាងសេដ្ឋកិច្ចក្តី ខាងវប្បធម៌សង្គមកិច្ចក្តី អាចចាត់តាំងជាផ្នែកដោយឡែក ដោយគណៈកម្មាធិការមជ្ឈិម ទទួលភារៈដឹកនាំដោយផ្ទាល់ ឬដោយប្រយោល តាមខ្សែចាត់តាំងជាក់ស្តែង"។

[០៩:៣៨:៥៤]

តួនាទីភារកិច្ចជាក់លាក់របស់គណៈកម្មាធិការមជ្ឈិមបក្សក្នុងលក្ខន្តិកបក្ស ដែលមានចែងនៅក្នុងមាត្រា២៣ផងដែរ ដែលបានបញ្ជាក់ថា “ភារកិច្ចរបស់កិច្ចគណៈកម្មាធិការមជ្ឈិម គឺទី១ អនុវត្តមាគ៌ានយោបាយបក្ស និងលក្ខន្តិករបស់បក្សនៅក្នុងបក្សទាំងមូល។ ទី២ ណែនាំអង្គការភូមិភាគ តំបន់ក្រុងទាំងអស់ និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោ-បាយ។ ទី៣ គ្រប់គ្រង និងចាត់ចែង កម្មាភិបាល និងបក្ខជន ក្នុងបក្សទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ ដោយក្តាប់ប្រវត្តិរូប ជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឲ្យច្បាស់”។ ហើយនៅក្នុងមាត្រា២៥ នៃលក្ខន្តិកបក្ស ក៏បានចែងដែរថា “គណៈកម្មាធិការមជ្ឈិមត្រូវប្រជុំជាសាមញ្ញ៦ខែម្តងដើម្បីពិនិត្យតាមដានវិនិច្ឆ័យការងារចាស់គ្រប់ផ្នែក ហើយលើកការងារថ្មីគ្រប់ផ្នែក”។ ជាមួយគ្នានេះដែរ លោក ខៀវ សំផន បានឆ្លើយនៅចំពោះសហចៅក្រមស៊ើបអង្កេត ដោយបានផ្តល់នូវព័ត៌មានសំខាន់ៗទាក់ទងទៅនឹងទាំងគណៈកម្មាធិការមជ្ឈិម និងទាំងគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា គឺមានឯកសារលេខ E3/27 ដែលជាកំណត់ហេតុនៃការសួរចម្លើយជនជាប់ចោទ ខៀវ សំផន កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧។ នៅក្នុងឯកសារនេះ គឺត្រង់ ERN ជាភាសាខ្មែរ គឺ 00156618 រហូតទៅដល់ 20, ជាភាសាអង់គ្លេស គឺ 00156749 រហូតដល់51, ហើយជាភាសាបារាំង គឺមានលេខ 00156671 ដល់ 72។ លោក ខៀវ សំផន បានរៀបរាប់ថា “កម្ពុជាប្រជាធិបតេយ្យ គឺជារបបកុម្មុយនីស្ត ដែលមានបក្សជាអ្នកដឹកនាំរដ្ឋ”។ គាត់ក៏បានបញ្ជាក់ដែរថា “ជាគោលការណ៍អង្គការដែលសំខាន់ជាងគេ គឺគណៈកម្មាធិការមជ្ឈិម។ ប៉ុន្តែជាក់ស្តែងគឺគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយថាទាំងមាគ៌ានយោបាយ និងការដាក់ចេញសេចក្តីសម្រេចត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍”។

[០៩:៤២:០៨]

លោក ខៀវ សំផន លើកឡើងថា “គណៈកម្មាធិការមជ្ឈិមគឺជួបប្រជុំជារៀងរាល់៦ខែម្តង ចាប់ពីឆ្នាំ១៩៧០មក។ គណៈកម្មាធិការអចិន្ត្រៃយ៍ជួបប្រជុំជាទៀងទាត់ប្រហែលជា៧ ទៅ១០ ថ្ងៃម្តង ឬញឹកញាប់ជាងនេះក្នុងករណីបន្ទាន់”។

នៅក្នុងការឆ្លើយតបទៅនឹងសំណួរ ដែលទាក់ទងទៅនឹងសមាសភាពរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ លោក ខៀវ សំផន បានឆ្លើយថា “គណៈកម្មាធិការអចិន្ត្រៃយ៍មានសមាជិក៧រូប គឺប៉ុល ពត, នួន ជា, វន វេត, សោ ភឹម, តាម៉ុក, សុន សេន និង អៀង សារី។ ខ្ញុំ

សូមបញ្ជាក់ថា គណៈកម្មាធិការនេះមិនចាំបាច់មានសមាជិកចូលរួមប្រជុំគ្រប់គ្នានោះទេ។ ចំណែកឯគណៈកម្មាធិការមជ្ឈិមមានសមាជិកប្រមាណ៣០នាក់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់នោះទេ។ ខ្ញុំចាំដូចជា មាស មុត កូនប្រសាររបស់ តាម៉ុក ដែលជាលេខានៃកងពលមួយ ដែលឈរជើងនៅកំពត ហើយក្រោយឆ្នាំ១៩៧៥ បានបញ្ជូនទៅជា -- ត្រូវបានប្តូរទៅជាកងទ័ពជើងទឹក និង សឿ វ៉ាស៊ី ហៅឌឿន ជាប្រធានមន្ទីរ៨៧០ ឬផងដែរ កុយ ធួន, កែ ពក។

[០៩:៤៣:៤៣]

ខ្ញុំខ្លួនឯង ក៏ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម។ ជាដំបូងជាសមាជិកត្រៀមនៅឆ្នាំ១៩៧១ និងក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ១៩៧៦"។

នៅក្នុងឯកសារលេខ E3/37 ជាកំណត់ហេតុនៃការសួរចម្លើយចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានសួរលោក ខៀវ សំផន ឱ្យរៀបរាប់អំពីមន្ទីរ ក-១ និងមន្ទីរ ក-៣។ ហើយពេលនោះលោក ខៀវ សំផន បានឆ្លើយថា "វាគឺជាកន្លែងរស់នៅ និងធ្វើការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ក-១ ស្ថិតនៅទល់មុខទន្លេបាសាក់ អគារមួយដែលនៅខាងត្បូងជិតសាលមហោស្រពជាតិ។ ហើយ ក-៣ ស្ថិតនៅក្រោយព្រះបរមរាជវាំង គឺជាផ្ទះជាច្រើនដែលត្រូវព័ទ្ធខណ្ឌ នៅផ្លូវប៉ាស្ទ័រ និងកម្ពុជាក្រោម និងផ្លូវវេជ្ជបណ្ឌិតហាន និងមានផ្លូវស្របមួយទៀត។

ចំពោះខ្ញុំ ខ្ញុំរស់នៅ ក-៣ បន្ទាប់ពីបានស្នាក់នៅ ក-១ បាន១ ឬ២ខែ បន្ទាប់ពីបានប្តូរមកពីប្រាសាទប្រាក់។ តាមពិតទៅមេដឹកនាំភាគច្រើនស្នាក់នៅ ក-៣ ដូចជា នួន ជា, អៀង សារី និង សុន សេន។ ចំណែកឯ ប៉ុល ពត វិញគាត់បានមកស្នាក់ពេលយប់ម្តងម្កាល។ ប៉ុន្តែជាវិធានការបង្ការ និងការពារ គាត់ផ្លាស់ប្តូរទីកន្លែងស្នាក់នៅញឹកញាប់ ហើយក្នុងចំណោមទីកន្លែងទាំងនោះ គាត់ទៅស្នាក់ក-១ ផងដែរ។ កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ភាគច្រើនត្រូវបានធ្វើនៅ ក-១ ពេលខ្លះនៅ ក-៣ នៅផ្ទះរបស់ ប៉ុល ពត ឬផ្ទះបាយ។

[០៩:៤៥:៥៦]

ឯកសារមួយទៀតដែរទាក់ទងទៅនឹង គឺមានលេខ E3/89 ដែលជាអត្ថបទសម្ភាសជាមួយលោក អៀង សារី កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦។ ក្នុងឯកសារនេះលោក អៀង សារី បានបញ្ជាក់អំពីសមាសភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយនិងវត្តមានរបស់លោក ខៀវ សំផន នៅក្នុងកិច្ចប្រជុំទាំងនោះ។ នៅក្នុងឯកសារ E3/89 នោះ ត្រង់ ERN ជាភាសាខ្មែរគឺ 00062453 ដល់ 54, ជា

ភាសាអង់គ្លេសគឺ 00417600, ជាភាសាបារាំងគឺ 00332682។ លោក អៀង សារី បានឆ្លើយទៅនឹងសំណួររបស់អ្នកសម្ភាសដូចតទៅ៖

"សំណួរ៖ អ៊ីចឹងបានសេចក្តីថា នៅក្នុងចុងឆ្នាំ៧៥ ហ្នឹងមានការប្រជុំមួយថ្នាក់មជ្ឈិម ដែលបានបានសម្រេចទិសដៅមួយចំនួន ឬក៏យ៉ាងម៉េច? លោក អៀង សារី បានឆ្លើយថា៖បាទ គឺថានៅក្នុងខែ៩ ឆ្នាំ១៩៧៥ មានការប្រជុំហ្នឹង គឺថាឥឡូវនេះធ្វើយ៉ាងណាកុំឲ្យវៀតណាមនេះមកកាន់កាប់កម្ពុជាបាន។ សំណួរបន្តទៀតបានសួរថា៖ ហើយអាហ្នឹងប្រជុំថ្នាក់គណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិមទាំងអស់ ឬក៏យ៉ាងម៉េច? លោក អៀង សារី បានបន្តឆ្លើយថា៖ គណៈអចិន្ត្រៃយ៍ទេ មិនមែនគណៈមជ្ឈិម គឺគណៈអចិន្ត្រៃយ៍។ បន្ទាប់មកមានសំណួរសួរទៀតថា៖ ហើយក្នុងពេលនោះ តើអ្នកណាខ្លះនៅក្នុងគណៈអចិន្ត្រៃយ៍ ហើយអ្នកណាខ្លះចូលរួមក្នុងការប្រជុំនោះ? លោក អៀង សារី បានឆ្លើយថា៖ គណៈអចិន្ត្រៃយ៍ហ្នឹង គឺតាមខ្ញុំមើលទៅ គឺសឹងតែទាំងអស់គ្នា គឺថា ប៉ុល ពត, នួន ជា, សោ ភឹម, ខ្ញុំ, សុន សេន, តាម៉ុក។

[០៩:៤៨:១០]

ពេលនោះសំណួរក៏បានសួរទៀតដែរថា៖ តាម៉ុក, វន វេត ដែរអត់ទេ? លោក អៀង សារី ឆ្លើយថា៖ វន វេតៗ អ្ហឹះ!។ សំណួរជាបន្តទៀតគឺសួរថា៖ ខៀវ សំផន? ចម្លើយរបស់លោក អៀង សារី ឆ្លើយថា៖ អត់មានទេ ក៏ប៉ុន្តែ ខៀវ សំផន នៅនុ៎ងដែរ មានមុខ មានវត្តមាននៅហ្នឹងដែរ។ ហើយអ្នកសួរក៏បានសួរទៀតដែរថា៖ បាទ មានវត្តមាន ប៉ុន្តែមិនមែនជាសមាជិកអចិន្ត្រៃយ៍? លោក អៀង សារី ក៏បានឆ្លើយថា៖ មិនមែនជាសមាជិកអចិន្ត្រៃយ៍ទេ"។ បាទនេះខ្ញុំសូមបញ្ចប់ការដកស្រង់ត្រឹមនេះ។

ដូច្នេះសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការមជ្ឈិម គឺមានបង្ហាញក្នុងឯកសារ E3/12 ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ ឯកសារនេះមានចំណងជើងថា "សេចក្តីសម្រេចគណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន"។ នៅក្នុងត្រង់ផ្នែកទី១ នៃឯកសារនេះមានចំណងជើងថា "សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ" ដែលមានសរសេរដូចតទៅ៖

សំណូមពរ ១) ឲ្យមានក្របខ័ណ្ឌក្នុងកិច្ចអនុវត្តផ្តាច់ការបដិវត្តន៍របស់យើង។ ២) ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង។ ទាំងអស់នេះដើម្បីពង្រឹងរដ្ឋអំណាចរបស់យើង បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច។ ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច។ កងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច។ ហើយនៅក្នុងផ្នែកទី

១២ នៃសេចក្ដីសម្រេចនេះ បានបង្ហាញអំពីការរៀបចំចាត់តាំងអង្គការរដ្ឋ ដែលបានបង្កើតឡើងនៅពេលនោះ។ នៅក្នុងផ្នែកនេះបានសរសេរថា "ត្រូវរៀបចំអង្គការរដ្ឋយើងឲ្យមានលក្ខណៈជាអង្គការរដ្ឋបដិវត្តន៍របស់យើងសុទ្ធសាធ"។

បន្ទាប់មកទៀតនៅក្នុងផ្នែកទី១២នេះដដែលក៏បានសរសេរដែរថា ធាតុពិតអង្គការរដ្ឋយើងពេលនេះខុសពីពេលមុន។ ពេលមុនធាតុពិតរណសិរ្ស ឥឡូវមិនដូច្នេះទេ ជាអង្គការរដ្ឋរបស់បក្សសុទ្ធសាធ។ មានឧទាហរណ៍មួយទៀតទាក់ទងទៅនឹងបញ្ហានេះដែរ គឺនៅក្នុងឯកសារលេខ E3/232 ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦។ ឯកសារនេះគឺជាកំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋាន ដែលមានការចូលរួមដោយសមមិត្តលេខា ប៉ុល ពត, អនុលេខា នួន ជា ហើយនិងមានលោក ខៀវ សំផន ក៏បានចូលរួមជាមួយផងដែរ។

[០៩:៥១:១៣]

ក្នុងកិច្ចប្រជុំនេះ លោក ខៀវ សំផន បានរាយការណ៍អំពីការបោះឆ្នោតដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ខាងមុខនេះ ដើម្បីជ្រើសរើសសភាតំណាងប្រជាជន។

មតិរបស់ថ្នាក់ដឹកនាំទាក់ទងទៅនឹងសភានេះ គឺបានបញ្ជាក់នៅក្នុងកំណត់ហេតុនេះ ជាពិសេសនៅត្រង់ផ្នែកទី១ធំ ចំណុចទី២ ត្រង់ចំណុច ឃ ពោលគឺត្រង់ ERN ជាភាសាខ្មែរ 00017118, ជាភាសាអង់គ្លេស 00182630, និងជាភាសាបារាំងគឺ 00323933 ដែលមានដូចតទៅ៖ "បើមានគេសួរយើងត្រូវពន្យល់ កុំច្រងេងច្រងាង កុំឲ្យឃើញថាយើងចង់បង្ក្រាប។ ទន្ទឹមនេះ កុំនិយាយលេងពីសភានៅមុខប្រជាជនឲ្យគេឃើញថាយើងបន្ទឹមបន្ថំ ហើយសភាយើងគ្មានតម្លៃអី។ ការពិតគឺនៅតែជាភារកិច្ចរបស់បក្សដដែល"។ នៅក្នុងឯកសារមួយទៀត គឺមានលេខ E3/557 ដែលជាកំណត់ហេតុនៃកិច្ចពិភាក្សាដេញដោលរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានធ្វើជាមួយនឹងលោក ខៀវ សំផន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។ លោក ខៀវ សំផន បានលើកឡើងថា "វាជាការពិត ដែលថាខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំដែលមានការពង្រីកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលនៅក្នុងនោះគេពិភាក្សាតែបញ្ហាទូទៅប៉ុណ្ណោះ ដូចជា ការការពារជាតិ ការកសាងជាតិ វៀតណាម ឬការលាលែងរបស់ នរោត្តម សីហនុ"។

ជាបន្តទៅទៀត ខ្ញុំនឹងលើកឡើងអំពីកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ដែលមានការចូលរួមរបស់លោក ខៀវ សំផន នៅក្នុងអង្គប្រជុំដែរ -- នេះដែរ។ ឯកសារ E3/197 ដែលជាកំណត់ហេតុ

នៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលបានធ្វើនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ដែលមានរបៀបវារៈស្តីអំពី “សីហនុ លាឈប់ពីតំណែង”។

[០៩:៥៤:០០]

នៅក្នុងឯកសារនេះបានកត់ត្រាថា “សមាសភាពដែលបានចូលរួមក្នុងកិច្ចប្រជុំនេះរួមមានសមមិត្តលេខា ប៉ុល ពត សមមិត្តអនុលេខា នួន ជា, វន វ៉េត, សុន សេន ហៅ ខៀវ, ខៀវ សំផន ហៅ ហែម, និងសមមិត្ត ឌឿន”។ នៅក្នុងកិច្ចប្រជុំនេះ លោក ខៀវ សំផន បានរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា អំពីស្ថានភាពទាក់ទងនឹងសម្តេចឪ នរោត្តម សីហនុ។ ដែលក្នុងកិច្ចប្រជុំនេះបានពិភាក្សាដោយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី១១ និងថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦។ នៅក្នុងកំណត់ហេតុប្រជុំថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ត្រង់ផ្នែកទីII អំពីមតិរបស់អង្គការ និងចំណុចទី១ អំពីមូលហេតុដែលនាំឲ្យសម្តេចសីហនុ លាឈប់។ កំណត់ហេតុនេះ បានកត់ត្រាអំពីមូលហេតុវែងឆ្ងាយសម្រាប់ការលាឈប់របស់សម្តេច សីហនុ។

ខ្ញុំសូមដកស្រង់ដូចតទៅ៖

“ក) មូលហេតុវែងឆ្ងាយ

គឺទំនាស់វណ្ណៈជាមូលដ្ឋានរវាងបដិវត្តន៍នឹងគាត់ ព្រមទាំងគ្រួសារគាត់។ គាត់រស់នៅជាមួយយើងមិនបាន។ កន្លងមក គាត់រស់នៅបានជាយុទ្ធវិធីទេ។ ដោយយើងដំណើរការជាយុទ្ធវិធីទៅ គាត់ចេះតែនៅបានជាបណ្តើរៗ។ សីហនុ មិនមែនលាឈប់តែម្តងនេះទេ។ គាត់លាឈប់តាំងពីឆ្នាំ១៩៧១មក”។

ឯកសារ E3/197 ដដែលក៏បានលើកឡើងអំពីបញ្ហានេះដែរ ហើយបានបន្តធ្វើនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦។

ត្រង់ផ្នែកទី៣ធំ ស្តីអំពីមតិរបស់អង្គការ អង្គប្រជុំយប់ថ្ងៃទី១៣។ ដែលក្នុងនេះបានកត់ត្រាថា “សមមិត្ត ហែម រាយការណ៍ជូនអចិន្ត្រៃយ៍អំពីបញ្ហា សីហនុ។ គាត់សម្រេចសុំលាលែងពីតំណែងដាច់ខាត។ គាត់បញ្ជាក់ថា ឲ្យអង្គការអាណិតគាត់ គាត់លួនសំពះឲ្យតែឲ្យគាត់ឈប់។ ការឈប់នេះ មិនមែនជាការប្រឆាំងនឹងយើងទេ។

[០៩:៥៦:៣៣]

សមមិត្តលេខាបានបញ្ជាក់ថា បញ្ហានេះជាបញ្ហាធំទុកឲ្យអង្គការមជ្ឈិមយើងអារកាត់ចុះ”។ នៅក្នុងកំណត់ហេតុអង្គប្រជុំអចិន្ត្រៃយ៍នេះ ក៏បានកត់ត្រាអំពីវិធានការចំនួនប្រាំមួយចំណុច ដែលក្នុងនេះ

គណៈអចិន្ត្រៃយ៍ទាំងមូល ក៏យល់ស្របផងដែរ។ ហើយខ្ញុំសូមលើកចំណុចមួយចំនួនមួយ ដែលទាក់ទង គឺចំណុចទី១ គឺ "មិនឲ្យសីហនុចេញទៅក្រៅទេ"។ ចំណុចទី៣ "វាយខ្សែឲ្យលួសឲ្យកូនគាត់មកភ្លាម ដោយបញ្ជាក់ថាឲ្យមកចូលឆ្នាំ និងបុណ្យឯករាជ្យ យើងចង់ដោះស្រាយបញ្ហានេះឲ្យស្អាត។ យើងត្រូវដោះស្រាយយ៉ាងនេះទើបចំណេញបដិវត្តន៍"។ បន្ទាប់មកនៅក្នុងកំណត់ហេតុនេះបានបន្តពន្យល់អំពីការសម្រេចចិត្តរបស់គណៈអចិន្ត្រៃយ៍ ដោយបានកត់ត្រាដូចជា៖ "ការពិត សីហនុ ជាខ្លាសម្លុម នៅតែស្បែក និងឆ្អឹង អត់ក្រចក អត់ចង្កូម។ រោមមាត់ក៏ត្រូវដកអស់ទៀត ដូច្នេះចាំតែថ្ងៃស្លាប់។ ក៏ប៉ុន្តែបើលែងខ្លាចាស់នេះឲ្យដើរទៅតាមផ្លូវ ក្មេងៗច្បាស់ជាខ្លាច។ មនុស្សចាស់ខ្លះដែលពុំស្គាល់ថា ជាខ្លាស្គម ក៏ខ្លាចដែរ"។

[០៩:៥៨:០៦]

ចំណុចមួយទៀតនៅក្នុងកំណត់ហេតុនេះ ក៏បានកត់ត្រាដែរថា "គាត់បានចូលរួមក្នុងបដិវត្តន៍ជាមួយយើងដែរ ទោះគាត់មានទំនាស់ជាមួយយើងក្តី ដោយហេតុនេះហើយបានជាបក្សសម្រេចឲ្យគាត់ធ្វើប្រធានគណៈប្រធានរដ្ឋទៀត។ តែគាត់មិនព្រម ដូច្នេះគាត់នៅបាន ឬមិនបាន ជារឿងគាត់។ យើងទុកគាត់ជាឥស្សរៈជនមួយរូប។ យើងមិនកាប់សម្លាប់គាត់ទេ តែចំពោះប្រជាជាតិ និងប្រជាជន គាត់ក៏មានទោសធ្ងន់ក្នុងឋានៈជាអ្នកកាប់សម្លាប់ប្រជាជន។ ដូច្នេះការសម្រេចរបស់យើង សមហេតុសមផលគ្រប់យ៉ាង។ យើងនៅតែរក្សាគាត់ តែបើគាត់នៅតែរើបម្រាស់ យើងត្រូវបញ្ចប់"។

ចំណុចមួយទៀត បានលើកឡើងអំពីទិសដៅបដិវត្តន៍ដែលមានដូចតទៅ៖

"ទិសដៅរបស់បដិវត្តន៍ គឺត្រូវតែបញ្ចប់សក្តិភូមិយ៉ាងដូច្នេះឯង។ ក្រឡាអុក វាចេញមកដល់ត្រង់ហ្នឹងហើយ។ របបសក្តិភូមិទាំងមូលត្រូវបដិវត្តន៍កម្ទេច និងគាស់រម្លើងជាស្ថាពរ។ ស្តេចដែលមានមក ២.០០០ឆ្នាំហើយ ទីចុងបំផុតត្រូវស្អាត។ យើងគ្មានផ្លូវអីចេញក្រៅពីនេះទេ"។

ជាមួយគ្នានេះដែរ យោងតាមឯកសារស្តីពីកំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ដែលខ្ញុំបានលើកឡើងមុននេះបន្តិច គឺឯកសារលេខ E3/557 នេះ។ លោក ខៀវ សំផន បានលើកឡើងផងដែរថា មានបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនទៀតដែលលើកយកមកពិភាក្សា នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលរូបគាត់ក៏បានចូលរួមដែរនោះ គឺជាបញ្ហាស្តីពីវៀតណាម។ ទាក់ទងនឹងបញ្ហានេះ ក៏បានលើកឡើងនៅក្នុងឯកសារ E3/218 ដែលជាកំណត់ហេតុនៃអង្គប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ ដែលមានរបៀបវារៈស្តីពីលទ្ធផលនៃការចរចាជាមួយវៀតណាមស្តីអំពីព្រំដែនខាង

កើត។ កិច្ចប្រជុំគណៈអចិន្ត្រៃយ៍នេះ ត្រូវបានដឹកនាំដោយសមមិត្តអនុលេខានួន ជា ហើយក៏មានការចូលរួមដោយសមមិត្ត សុន សេន ហៅ ខៀវ , សមមិត្ត ខៀវ សំផន ហៅ ហែម, សមមិត្ត យ៉ា និងសមមិត្ត ឌឿន។ ក្នុងកំណត់ហេតុប្រជុំនេះ បានលើកឡើងអំពីសេចក្តីរាយការណ៍របស់សមមិត្ត យ៉ា ដែលក្នុងនោះ សមមិត្ត យ៉ា បានរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការចរចាជាមួយវៀតណាម កាលពីយប់ថ្ងៃទី០៧ ដល់ព្រឹកថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៧៦។

[១០:០១:១២]

យោងតាមការរាយការណ៍នេះ សមមិត្តអនុលេខា នួន ជា បានដាក់ចេញនូវសេចក្តីណែនាំ និងវិធានការមួយចំនួនដូចដែលបានកត់ត្រានៅក្នុងផ្នែកទីII “ស្តីពីមតិណែនាំរបស់សមមិត្តអនុលេខា” គឺត្រង់ឯកសារ ERN ជាភាសាខ្មែរគឺ 00000756 ដល់ 57, ជាភាសាអង់គ្លេស គឺ 00182656 ដល់ 57, ជាភាសាបារាំង គឺ 00334971។ ជាមួយគ្នានេះដែរ ចំណុចទី២ ស្តីពីវិធានការតទៅទៀត ត្រង់ចំណុច “ក” ក៏បានលើកឡើងដែរថា បន្តអនុវត្តវិធានការរបស់បក្សតទៅទៀត ទាំងនយោបាយ ទាំងយោធា ទាំងទូត។ សមមិត្តអនុលេខាបានរំឭកអំពីខ្លឹមសារនៃសេចក្តីសម្រេចរបស់អចិន្ត្រៃយ៍ ក្នុងសម័យប្រជុំថ្ងៃទី១១ ខែមីនា ស្តីពីបញ្ហាព្រំដែនខាងកើត ព្រមទាំងជូនសេចក្តីកំណត់ហេតុមួយច្បាប់ទៅសមមិត្តយ៉ា។

[១០:០២:៣៦]

យោងតាមកិច្ចប្រជុំថ្ងៃទី១១ ខែមីនា ដែលទាក់ទងទៅនឹងបញ្ហាស្តីពីព្រំប្រទល់ខាងកើតដែលមាននៅក្នុងឯកសារលេខ E3/217 ដែលជាកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ គឺឃើញថា មានការចូលរួមប្រជុំដោយលោកជនជាប់ចោទទាំងបីរូប គឺលោក នួន ជា, លោក ខៀវ សំផន និងលោក អៀង សារី។ លើសពីនេះទៀត នៅត្រង់ចំណុច “ខ” ដែលស្ថិតនៅក្នុងវិធានការតទៅទៀតនោះ នៃឯកសារ E3/218 ដដែល បានកត់ត្រាអំពីការចាត់តាំង សុន សេន ឲ្យរៀបចំផែនទីឲ្យហើយ ដើម្បីត្រៀមចរចាជាមួយវៀតណាម នៅពេលខាងមុខ។

[១០:០៣:២៩]

កំណត់ហេតុប្រជុំដដែលនៅត្រង់ចំណុចទី៣ ស្តីពីសកម្មភាពវៀតណាមនៅកន្លែងផ្សេងទៀត គឺបានកត់ត្រាអំពីការដឹងឮរបស់គណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងជម្លោះជាមួយនឹងវៀតណាម នៅកន្លែងផ្សេង១ទៀត។ ហើយនិងមានសេចក្តីសម្រេចណែនាំរបស់គណៈអចិន្ត្រៃយ៍ទាកទងទៅនឹងការប្រើមីន

ការចាប់ខ្លួន ការវាយប្រហារលើកាណូត និងតម្រូវឲ្យមានការប្រុងប្រយ័ត្នចំពោះមនុស្សដែលរត់ទៅវៀតណាម។ ខ្ញុំសូមអានកំណត់ហេតុនេះដូចតទៅ៖ "ក្នុងពេលចរចាដែលយើងកំពុងចរចានៅព្រៃសាន នៅកន្លែងផ្សេងៗទៀត វៀតណាមវាក៏ធ្វើសកម្មភាពឥតឈប់ឈរដែរ ដូចជា៖

ក- នៅបូព៌ា ត្រង់ម្តុំច្បុចស្រុកស្នួល វាធ្វើផ្លូវកាត់លើដីយើងតាមផ្លូវបារាំងចាស់ ហើយចូលមកក្នុងដីយើងប្រាំគីឡូម៉ែត្រ។ បក្សបានណែនាំឲ្យប្រើមីន នៅក្បាលចាម ត្រាក់ទ័រវាបើកចូលដីយើងជាន់មីនស្លាប់ទាំងអ្នកបើក។

ខ- នៅពាមជរ ក្អមសំណរ មានក្រុមវៀតណាមប្រាំ ឬប្រាំមួយនាក់ចូលមកសំងំនៅក្នុងព្រៃមិនដឹងជាវៀតណាមខាងណា យើងឲ្យចាប់ហើយ។

[១០:០៥:០០]

គ- នៅតាមសមុទ្រ វាឲ្យកាណូត កប៉ាល់ល្បាតពានដែនទឹកយើងជាញឹកញាប់ យើងបាញ់លិចការណូតខ្លះ។ ដូច្នេះ ជាមួយវៀតណាមរឿងយើងមិនចេះចប់ទេ។ យើងត្រូវបន្តធ្វើការតស៊ូខាងនយោបាយ តស៊ូខាងទូត តែក៏ត្រូវប្រើកម្លាំងយោធារួមផ្សំផង។ ប្រយ័ត្នម្យ៉ាងចំពោះមនុស្សដែលរត់ទៅវៀតណាម ហើយវាលែងមកវិញ ឲ្យធ្វើការឃោសនាការ នាំមនុស្សរត់ទៅវាទៀត។ បញ្ហានេះមូលដ្ឋាន ក៏មានវិធានការហើយ"។ ហើយបើពិនិត្យទៅលើប្រធានបទមួយទៀត ដែលលោក ខៀវ សំផន បានបញ្ជាក់នៅក្នុងឯកសារស្តីពីកំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល គឺឯកសារ E3/557 គឺលោក ខៀវ សំផន "បានលើកឡើងថា មានការប្រជុំពិភាក្សានៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ដែលរូបគាត់ ក៏បានចូលរួមប្រជុំដែរនោះ គឺបញ្ហាស្តីការការពារជាតិ"។

នៅក្នុងឯកសារលេខ E3/229 ដែលជាកំណត់ហេតុអង្គប្រជុំអចិន្ត្រៃយ៍ យប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដែលមានរបៀបវារៈស្តីពីបញ្ហាការពារជាតិ។ នៅក្នុងឯកសារនេះ បានបញ្ជាក់អំពីសមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ មានចំនួន៨រូប គឺសមមិត្តលេខា ប៉ុល ពត, សមមិត្តអនុលេខា នួន ជា, អៀង សារី ហៅ វ៉ាន់, វន វ៉េត, សុន សេន ហៅ ខៀវ, កុយ ធួន ហៅ ធុច, ខៀវ សំផន ហៅ ហែម និង ស៊ើ វ៉ាស៊ី ហៅ ឌឿន។

[១០:០៦:៥៧]

កិច្ចប្រជុំនេះ ចាប់ផ្តើមដោយការរាយការណ៍របស់ សុន សេន អំពីសភាពការណ៍នៅព្រំដែនខាងកើត។ បញ្ហាជំនួយចិន ទាក់ទងខាងអាកាស និងខាងជើងទឹក និងបញ្ហាដឹកគ្រាប់រំសេវ ហើយនិង

សំណើរបស់ សុន សេន ថា "ស្នើអង្គការបង្កើតពេទ្យមួយសម្រាប់យោធា"។ នៅក្នុងកំណត់ហេតុប្រជុំនេះ ក៏កត់ត្រាអំពីវិធានការដែលបានសម្រេចដោយគណៈអចិន្ត្រៃយ៍នៅក្នុងកិច្ចប្រជុំនេះ ដែលរួមមានដូចជា៖

<u>វិធានការរបស់យើង</u>

ក. ជាគោលការណ៍ យើងចរចាជាមួយវា ក៏ចរចា តែសំខាន់ត្រូវរៀបចំកម្លាំងការពារ។ ត្រូវពិនិត្យកន្លែងខ្លាំង កន្លែងខ្សោយ ហើយប្រុងប្រៀបប្រយុទ្ធ វាមកជ្រុល ដាក់វាភ្លាម។

ខ. ត្រូវសហការឲ្យជាប់ជាមួយមូលដ្ឋាន ដូច្នេះ យោធារាយការណ៍ទៅមូលដ្ឋាន ហើយរាយ-ការណ៍មកសេនាធិការជាព័ត៌មាន។ ខាងមណ្ឌលគិរី មានសមមិត្ត ឡាំង ខាងនិរតីមានសមមិត្ត យ៉ា ទទួលខុសត្រូវ។ សំខាន់ គឺកងទ័ព និងមូលដ្ឋានឯកភាពគ្នា និងជាប់គ្នា។

[១០:០៨:១៧]

គណៈអចិន្ត្រៃយ៍ក៏បានស្នើឲ្យមានកន្លែងថ្មី សម្រាប់ព្រលានយន្តហោះនៅកំពង់ឆ្នាំង ហើយក៏បានយល់ព្រមឲ្យរៀបចំមន្ទីរពេទ្យយោធា តាមសេចក្ដីស្នើរបស់សេនាធិការ។

នៅក្នុងកិច្ចប្រជុំ ដែលបានធ្វើនៅយប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ក៏បានលើកឡើងអំពីរបៀបវារៈស្ដីបញ្ហាសេដ្ឋកិច្ចផងដែរ។ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍អំពីបញ្ហាសេដ្ឋកិច្ចនេះ មាននៅក្នុងឯកសារលេខ E3/230។

កិច្ចប្រជុំនេះ ក៏មានការចូលរួមដោយជនជាប់ចោទទាំងបីនាក់ផងដែរ ហើយមានសមាសភាពដដែល ដូចមាននៅក្នុងកិច្ចប្រជុំស្ដីពីបញ្ហាការពារប្រទេសដែរ។ ដោយគ្រាន់តែបន្ថែមវត្តមានសមមិត្ត ទូច ម្នាក់ទៀតប៉ុណ្ណោះ។

នៅក្នុងកិច្ចប្រជុំនេះ វន វ៉េន, កុយ ធួន និង អៀង សារី បានរាយការណ៍អំពីបញ្ហាមួយចំនួនទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម ដឹកជញ្ជូន និងបញ្ហាជំនួយ យូហ្គោស្លាវី។

នៅក្នុងកំណត់ហេតុនេះ បានកត់ត្រាអំពីមតិយោបល់ និងមតិណែនាំជាច្រើនរបស់អង្គការ។ បើយើងពិនិត្យលើចំណុចទី១ ស្ដីបញ្ហាផលិតអំបិល គឺគណៈអចិន្ត្រៃយ៍ស្នើឲ្យមានការជំរុញបន្ថែមផលិតអំបិល ឲ្យបាន៥០.០០០ ទៅ៦០.០០០តោន។ ហើយនៅក្នុងចំណុចទី៥ ស្ដីពីបញ្ហាបន្ថែមកម្លាំង គណៈអចិន្ត្រៃយ៍បានស្នើឲ្យប្រើប្រាស់កម្លាំងកុមារជំទង់ៗពីមូលដ្ឋានបន្ថែម ហើយប្រគល់ឲ្យឧស្សាហកម្មចាត់ចែង។

[១០:១០:០៥]

ចំណុចទី៧ ស្ដីពីការបែង -- ស្ដីពីការចែកចាយអង្ករជំនួយចិន គណៈអចិន្ត្រៃយ៍បានសម្រេចធ្វើបែងចែកអង្ករជំនួយចិន ដែលបានណែនាំឲ្យបែងចែកទៅខាងសមមិត្ត មុត ចំនួន៥.០០០បាវ ចែកទៅខាងកោះកុង ចំនួន ២.០០០បាវ ចែកទៅតំបន់២៥ ចំនួន១.០០០បាវ រីឯចំណែកនៅសល់ ទុកបម្រុង និងទុកប្រើប្រាស់នៅភ្នំពេញ។

ជាបន្ត ប្រធានបទចុងក្រោយ ដែលខ្ញុំនឹងលើកយកមកបង្ហាញនៅពេលនេះ គឺទាក់ទងទៅនឹងការផ្សព្វផ្សាយជាសាធារណៈនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលកំណត់ដោយសមាជិករបស់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ដែលយើងឃើញថាមានសាក្សីមួយចំនួននៅក្នុងសវនាការនេះ ក៏បានធ្វើការកត់សម្គាល់ថា ពួកគេបានស្វែងយល់ និងយល់ដឹងអំពីសមាជិកនៃគណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការផ្សព្វផ្សាយតាមវិទ្យុជាដើម។

[១០:១១:១៨]

ហើយជាបន្ត ខ្ញុំនឹងលើកឡើងនូវឧទាហរណ៍មួយចំនួន ដែលទាក់ទងទៅនឹងការផ្សព្វផ្សាយវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យនេះ។ ខ្ញុំនឹងលើកឡើងតែការផ្សព្វផ្សាយរយៈពេលតែ១ខែ ពោលគឺនៅក្នុងខែធ្នូ ឆ្នាំ១៩៧៧។ ហើយខ្ញុំកត់សម្គាល់ឃើញថា អង្គជំនុំជម្រះក៏អាចនឹងស្វែងរកឯកសារជាច្រើនបន្ថែមទៀត ដែលមាននៅក្នុងឧបសម្ព័ន្ធ៥ នៃបញ្ជីឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញា ចាប់ពីចុងខែកញ្ញា ឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៨។

ជាបន្ត ខ្ញុំនឹងលើកនូវឯកសារមួយចំនួន ដែលទាក់ទងទៅនឹងការផ្សព្វផ្សាយរបស់កម្ពុជាប្រជា-ធិបតេយ្យ។ ឯកសារដំបូងគឺមានលេខ E3/1495 ត្រង់ERN ជាភាសាខ្មែរគឺ 00720832, ជាភាសាអង់គ្លេសគឺ 00168315, និងជាភាសាបារាំងគឺ 00750223 ដែលបានកត់ត្រាទុកនូវការចាក់ផ្សាយដោយវិទ្យុភ្នំពេញ នៅម៉ោង ២៣:០០ ម៉ោងសកលថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានផ្សព្វផ្សាយទាក់ទងទៅនឹងកិច្ចប្រជុំរវាងសមាជិកនៃការិយាល័យនយោបាយ នៃគណៈមជ្ឈិមបក្សរបស់បក្សកុម្មុយនីស្តចិន ជួបជាមួយនឹងថ្នាក់ដឹកនាំមួយចំនួនរបស់កម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន សមមិត្ត ប៉ុល ពត ជាលេខានៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រី, សមមិត្ត នួន ជា ជាអនុលេខានៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន, សមមិត្ត អៀង សារី ជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាឧបនាយករដ្ឋមន្ត្រី

ទទួលបន្ទុកកិច្ចការបរទេស, សមមិត្ត វន វ៉េត ជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្សកុម្មុយ-នីស្តកម្ពុជា និងជាឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច, សមមិត្ត សុន សេន ជាសមាជិកអចិន្ត្រៃយ៍នៃគណៈមជ្ឈិបបក្សកុម្មុយនីស្តកម្ពុជា និងឧបនាយករដ្ឋមន្ត្រីក្រសួងការពារជាតិ។

[១០:១៣:៥៣]

ហើយឯកសារលេខ E3/1496 ត្រង់ERN ជាភាសាខ្មែរគឺ 00727587, និងជាភាសាអង់គ្លេសគឺ 00168351, ជាភាសាបារាំង គឺ 00726150។ ក៏បានកត់ត្រានូវការចាក់ផ្សាយដោយវិទ្យុភ្នំពេញម៉ោង២៣:00 ម៉ោងសកលនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានផ្សព្វផ្សាយទាក់ទងទៅនឹងពិធីជប់លៀងបញ្ចប់បេសកកម្ម ដែលមានសមាសភាពគណៈប្រតិភូនៃសមាជិក នៃការិយាល័យនយោបាយប្រទេសចិនដដែល។

ការផ្សព្វផ្សាយវិទ្យុ -- របស់វិទ្យុនេះ ក៏បានប្រកាសអំពីតួនាទីដូចក្នុងឯកសារមុន ចំពោះតួនាទីរបស់ ប៉ុល ពត, នួន ជា, អៀង សារី និង វន វ៉េត ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា។

ហើយឯកសារចុងក្រោយ គឺឯកសារលេខ E3/1499 ត្រង់ ERN ជាភាសាខ្មែរគឺ 00714316 និង 00714318 ហើយជាភាសាអង់គ្លេសគឺ 00168363 ដល់ 64, ជាភាសាបារាំងគឺ 00743645 ដល់ 46 ដែលបានកត់ត្រាទុកនូវការចាក់ផ្សាយដោយវិទ្យុភ្នំពេញ នៅម៉ោង២១:00 -- ២៣:00ៗ ម៉ោងសកល ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៧ និងម៉ោង០៤:00ៗ ម៉ោងសកល ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានផ្សព្វផ្សាយទាក់ទងទៅនឹងពិធីជប់លៀងសាយភោជន ជូនចំពោះប្រធានាធិបតីប្រទេសឡាវ។ ហើយក្នុងការផ្សព្វផ្សាយនេះ ក៏បានលើកឡើងដដែលទាក់ទងទៅនឹងតួនាទីរបស់ លោក នួន ជា, អៀង សារី និង វន វ៉េត នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាផងដែរ។

[១០:១៦:៣៩]

បាទ ហើយបទបង្ហាញរបស់ខ្ញុំដែលលើកនៅពេលនេះ សូមចប់នៅត្រឹមនេះ ហើយសូមអនុញ្ញាតដើម្បីឱ្យសហការីរបស់ខ្ញុំបន្តការធ្វើបទបង្ហាញនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ លោក លោកស្រីចៅក្រមជាទីគោរព នៅថ្ងៃនេះគឺថាខ្ញុំនឹងផ្ដោតបទបង្ហាញរបស់ខ្ញុំលើឯកសារទាំងឡាយ ដែលបង្ហាញអំពីតួនាទីរបស់គណៈអិចន្ត្រៃយ៍ សេចក្ដីសម្រេចគោលនយោបាយក្នុងការអនុវត្តរបស់កងទ័ពយោធាតំបន់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:១៧:៤៣]

ឯកសារទី១ ដែលខ្ញុំចាប់ផ្ដើមបង្ហាញនោះ គឺឯកសារ E3/182។ ឯកសារ E3/182 នេះគឺជាកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ ដែលរៀបចំឡើងក្នុងថ្ងៃ០៩ តុលា ឆ្នាំ៧៥។ ផ្នែកដែលខ្ញុំចង់បង្ហាញនេះគឺឆ្លុះបញ្ចាំងអំពីសេចក្ដីប្រកាសរបស់គណៈអចិន្ត្រៃយ៍ ពាក់ព័ន្ធទៅនឹងកាតព្វកិច្ចរបស់អង្គការថ្នាក់តំបន់ក្នុងការអនុវត្តគោលនយោបាយមាគ៌បក្ស និងសេចក្ដីសម្រេចដែលបានធ្វើឡើងដោយមជ្ឈិម។

ផ្នែកនៅក្នុងកំណត់ហេតុនេះ គឺលើកឡើងអំពីវិធានការ ចាប់ផ្ដើមនៅក្នុងទំព័រ២ ខាងក្រោម និងទំព័រ៣ ខាងដើម ជាភាសាខ្មែរ។ ERN ជាភាសាខ្មែរគឺ 00019110 និង 19109។ យើងដឹងហើយថាទំព័រជាភាសាខ្មែរនៅក្នុងនោះគឺថាវាត្រឡប់ត្រឡិន ២ ទៅ៣, ៣ ទៅ ២ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាប។ អង់គ្លេស ERN គឺ 00183394 រហូតដល់ 183395, បារាំងលេខ ERN គឺ 00292869 រហូតទៅដល់ 292870។

[១០:១៩:៤២]

នៅក្នុងកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ត្រង់ផ្នែកនេះ គឺមានការលើកឡើងវិធានការដូចតទៅខ្ញុំសូមដកស្រង់សម្ដី៖

“ផ្នែកនីមួយៗ ត្រូវម្ចាស់ការសព្វគ្រប់ទាំងអស់ ក្នុងន័យអនុវត្តមាគ៌ា និងសេចក្ដីសម្រេចរបស់បក្ស ដោយគំនិតផ្ដើមវាយសម្រុក ចាត់ចែងឲ្យហ្មត់ចត់ ឲ្យបានរហ័ស ហើយជាបន្តបន្ទាប់”។ បន្តទៅដល់កថាខណ្ឌខាងក្រោមទៀត “ដើម្បីសម្រេចគោលបំណងនេះ ម្យ៉ាងត្រូវមានគោលជំហរទទួលខុសត្រូវដោយឡែកខ្ពស់ ដោយក្ដាប់មាគ៌ារួមរបស់បក្ស ជាពិសេសមាគ៌ាទាក់ទងនឹងផ្នែករបស់ខ្លួន ត្រូវក្ដាប់មាគ៌ាឲ្យច្បាស់ និងកិច្ចដំណើរការឲ្យច្បាស់ក្នុងអនុវត្តដើម្បីគំនិតផ្ដើមចាត់ចែងវា។ ដូច្នេះ យើងយកមាគ៌ាសេចក្ដីសម្រេចចិត្តរបស់បក្ស លៃលកឆ្នៃប្រឌិត”។ នៅផ្នែកខាងក្រោមនោះគឺលើកឡើងថា “នៅក្នុងការលើកឡើងគម្រោងត្រូវសួរយោបល់អចិន្ត្រៃយ៍ដើម្បីសម្រេច និងអនុម័ត”។ បញ្ចប់ការដកស្រង់សម្ដីនេះ។

បន្ទាប់មកទៀត ខាងក្រោមទំព័របន្ទាប់គឺ នៅក្នុងកថាខណ្ឌចំណុច២ ដែលមានសរសេរដូចតទៅ សូមដកស្រង់សម្តី៖ "ធ្វើតែនាមផ្នែកនីមួយៗមិនសួរអចិន្ត្រៃយ៍ នេះក៏ជាការខុសឆ្គង។ ដូច្នេះបានជាត្រូវដោះស្រាយ ដោយយកសេចក្តីសម្រេចរបស់បក្សទៅអនុវត្ត តាមដានតម្រែតម្រង់ឲ្យបានល្អ"។ បញ្ចប់ការដកស្រង់។

[១០:២១:៣៦]

លោក លោកស្រីចៅក្រមជាទីគោរព! មធ្យោបាយមួយដែលគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមផ្សព្វផ្សាយមាគ៌ាបក្ស និងការណែនាំរបស់ខ្លួនទៅអង្គការតំបន់នោះ គឺតាមរយៈសុន្ទរកថា ឬក៏សន្និបាតនៅតាមភូមិភាគ។ មហាសន្និបាតនេះបន្ទាប់មកបង្កើតទង់ -- ទស្សនាវដ្តីទង់បដិវត្ត។ ទង់បដិវត្តចំនួនបីដែលមានសុន្ទរកថា និងយោបល់របស់តំណាងមជ្ឈិម និងអចិន្ត្រៃយ៍ គឺលើកឡើងនៅក្នុងពេលសន្និបាតនោះ ដូចដែលខ្ញុំចង់លើកឡើងនៅទីនេះ។

ឯកសារទី១ គឺ E3/760 ឯកសារ E3/760។ ឯកសារនេះ គឺទង់បដិវត្តចុះខែមិថុនា ឆ្នាំ១៩៧៦។ នៅក្នុងឯកសារនេះចាប់ផ្តើមដោយខ្មែរ ERN លេខ 000062845 (ស៊ីក) (00062845) រហូតទៅដល់6246, អង់គ្លេសគឺ 00509611, បារាំងគឺ 00487756។ បក្សបានដកស្រង់នូវចំណុចដកស្រង់ចេញពីការណែនាំរបស់កម្មាភិបាល និងអ្នកតំណាងរបស់បក្សក្នុងសន្និបាតរៀបចំឡើងពីថ្ងៃ៣ ដល់ថ្ងៃ៧ ខែមិថុនា ឆ្នាំ១៩៧៦។ នៅក្នុងការពន្យល់ដែលបានលើកឡើងនៅក្នុងឯកសារនេះ គឺពាក់ព័ន្ធទៅនឹងហេតុផលដែលគេផ្សព្វផ្សាយទៅនឹងសុន្ទរកថានេះ ដែលមានការលើកឡើងដូចតទៅ។

[១០:២៣:៤៥]

នេះគឺជាការដកស្រង់ចេញមកពីផ្នែកដែលគូសក្នុងរង្វង់ក្រហមក្រោមចំណងជើងរបស់វា។ "ពីថ្ងៃ៣ ខែមិថុនា ឆ្នាំ១៩៧៦ ដល់ថ្ងៃ៧ សន្និបាតនៅតាមភូមិភាគបានរៀបចំឡើង។ តំណាងរបស់គណៈកម្មាធិការបានចូលរួមនៅក្នុងសន្និបាតនេះ ហើយលើកឡើងជាយោបល់ និងការណែនាំលើបញ្ហាសំខាន់ៗនីមួយៗ បានលើកឡើងយកមកពិចារណា។ ជាពិសេសលើបញ្ហាយុទ្ធសាស្ត្រ និងយុទ្ធវិធីក្នុងការវាយសម្រុក និងទទួលបានបីតោនក្នុងមួយហិកតាក្នុង១ឆ្នាំ។ បទពិសោធន៍ចេញមកពីកំហុស និងចំណុចត្រូវ ដែលបានពិនិត្យឃើញ គឺឃើញមាននៅក្នុងការណែនាំរបស់សមមិត្តតំណាងអង្គការបក្សលើកឡើងក្នុងសន្និបាតពេលនោះ។ ដោយក្នុងនោះ គឺបានឲ្យតំបន់ និងភូមិភាគធ្វើការលើកកម្ពស់យុទ្ធសាស្ត្រ យុទ្ធវិធីរបស់ខ្លួនដើម្បីសម្រេចឲ្យបានទិន្នផលបីតោនក្នុងមួយហិកតា។ ហេតុដូច្នេះហើយ

យើងខ្ញុំសូមផ្តល់នូវការដកស្រង់នៃការគំនិត និងការណែនាំរបស់សមមិត្តតំណាងអង្គការបក្សក្នុងសន្និបាតនេះ ដើម្បីឲ្យកម្មាភិបាលពិចារណា និងសិក្សាដូចតទៅ”។

[១០:២៥:២៤]

ទំព័របន្ទាប់នៅក្នុងឯកសារដែលមានទៀតនោះ គឺថាមានសុន្ទរកថាថ្លែងបើករបស់តំណាងគណៈកម្មាធិការ។ ក្រោមសុន្ទរកថាថ្លែងបើកនេះ គឺយើងឃើញមានអត្ថបទមួយ ដែលមាននៅក្នុងខ្មែរទំព័រលេខ 00062848 ទៅដល់ 62849, អង់គ្លេសគឺ 00509614, បារាំងគឺ 0048 -- 00487758។ អត្ថបទនេះគឺមានសរសេរដូចតទៅ។ ខ្ញុំសូមដកស្រង់សម្តី “សន្និបាតបានបន្តស្តាប់របាយការណ៍របស់គណៈកម្មាធិការតំ -- ភូមិភាគ ដែលលើកយកមកពិភាក្សានៅក្នុងរបៀបវារៈ។ ក្រោយការស្តាប់របាយការណ៍ និងការពិភាក្សាលើបញ្ហានីមួយៗរួចមកហើយ សមមិត្តតំណាងគណៈកម្មាធិការបានផ្តល់យោបល់ និងការណែនាំ។ យើងចង់ផ្តល់ការណែនាំ និងមតិយោបល់របស់សមមិត្តតំណាងគណៈកម្មា-ធិការ”។ នៅក្រោមនេះបន្តិច គឺផ្នែកមួយដែលពាក់ព័ន្ធទៅនឹងមតិយោបល់ និងការណែនាំពាក់ព័ន្ធទៅនឹងស្ថានភាពខ្មាំង។ នៅចុងបំផុតនៃផ្នែកនេះ គឺនៅក្នុងទស្សនាវដ្តីទង់បក្សបដិវត្ត ត្រង់ខ្មែរ ERN 000062873 (ស៊ីក) (00062873) រហូតទៅដល់ 62874, អង់គ្លេស គឺមានលេខ ERN 00509634, បារាំង ERN គឺ 00487783 ទៅដល់ 487784 គឺផ្នែកមួយដែលមានចំណងជើងថា “មតិផ្តាំផ្ញើក្នុងពិធីបិទសន្និបាតភូមិភាគ”។

ដោយមានការលើកឡើងចំណុចថ្លែងមួយចំនួនដែលគេបានផ្សព្វផ្សាយ។

[១០:២៨:២៤]

ខ្ញុំសូមដកស្រង់សម្តី “ល្ងាចនេះ យើងធ្វើពិធីបិទសន្និបាតយើង ក្រោយពីបានធ្វើការងារអស់៣ថ្ងៃកន្លះ ប្រកបដោយជោគជ័យ”។ បន្តទៅខាងក្រោមនៅក្នុងទំព័រនេះ ខ្ញុំសូមដកស្រង់សម្តី “យើង លទ្ធផលសន្និបាតភូមិភាគបើកនេះ យើងសូមយកទៅរាយការណ៍ឲ្យគណៈកម្មាធិការមជ្ឈិមជ្រាប ហើយនិងផ្សព្វផ្សាយនូវបទពិសោធន៍ -- នូវពិសោធន៍ភូមិភាគនេះ។ សន្និបាតនេះ នៅទូទាំងប្រទេសដែរ ហើយតាមរយៈនេះ យើងនឹងកែលម្អយុទ្ធសាស្ត្រ យុទ្ធវិធីរបស់យើង”។ បន្ទាប់មកទៀត នៅក្រោមកថាខណ្ឌមួយទៀតខាងក្រោម គឺមានសរសេរដូចតទៅ។ ខ្ញុំសូមដកស្រង់សម្តី “គោលបំណងរបស់យើងនោះគឺថាដើម្បីឲ្យតំណាង -- សមមិត្តតំណាងទាំងអស់នេះទទួលបាននូវលទ្ធផល ហើយជាពិសេសសម្រេចបាននូវយុទ្ធសាស្ត្រ និងយុទ្ធវិធីក្នុងការសម្រេច ដើម្បីសម្រេចបដិវត្តន៍សង្គមនិយម និងកសាងសង្គម

និយម សម្រេចបីតោនក្នុងមួយហិកតា ទៅអនុវត្តជាមួយបេក្ខជនយើងទាំងអស់នៅភូមិភាគ ទៅអនុវត្តជាមួយកងទ័ពយើងទាំងអស់ក្នុងភូមិភាគ ទៅអនុវត្តជាមួយសហករណ៍យើងទាំងអស់នៅក្នុងភូមិភាគជាមួយនឹងក្រសួងរបស់យើងទាំងអស់ឲ្យបានបីតោនក្នុងមួយហិកតា”។

[១០:២៩:៥៥]

ហើយបន្ទាប់មកទៅនៅចំណុចចុងក្រោយ គឺមានដកស្រង់ថា “នៅទីបញ្ចប់សំណូមពរសមមិត្តទាំងអស់អញ្ជើញត្រឡប់ទៅមូលដ្ឋានវិញ អនុវត្តសេចក្ដីសម្រេចសន្និបាតយើងឲ្យបានជោគជ័យ ជាពិសេសឲ្យបានបីតោនក្នុងមួយហិកតា ក្នុងឆ្នាំ៧៦”

ឯកសារបន្ទាប់ទៀតដែលខ្ញុំសូមបង្ហាញជូននោះ គឺឯកសារលេខ E3/193 ។ គឺទង់បដិវត្ត ខែសីហា ៧៧។ ឯកសារទង់បដិវត្តនេះ គឺចុះផ្សាយនូវបទបង្ហាញរបស់សមមិត្តតំណាងគណៈកម្មាធិការស្ដីអំពីការកសាង និងការពង្រីកការដឹកនាំរបស់បក្ស។ នៅក្នុងពេលដែលធ្វើសន្និបាតនៅភូមិភាគបស្ចិមក្នុងខែ ដែលបានរៀបចំឡើងក្នុងខែកក្កដា ឆ្នាំ១៩៧៧ នៅក្នុងសន្និបាតនេះ គឺវាបន្តពីសន្និបាតខែមិថុនាឆ្នាំ៧៦ ដែលក្នុងនេះ គឺផ្ដោតសំខាន់ទៅលើការសម្រេចឲ្យបានបីតោនក្នុងមួយហិកតាដដែល។

ឯកសារដែលខ្ញុំគ្រោងនឹងបង្ហាញនេះ គឺផ្ដោតអំពីបញ្ហាខ្មាំងផ្ទៃក្នុង នៅក្នុងជួរបក្ស។ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ ជាពិសេសបទបង្ហាញនេះ បានចុះផ្សាយនៅក្នុងឯកសារទង់ -- ទស្សនាវដ្ដីទង់បដិវត្តដោយចាប់ផ្ដើមលើកឡើងនៅក្នុងខ្មែរ ERN លេខ 00062948, អង់គ្លេស ERN គឺ 00399222 រហូតទៅដល់ 399223, បារាំង ERN គឺមានលេខ 00611826។

ខ្ញុំនឹងដកស្រង់សម្ដីចេញមកពីបទឧទ្ទេសនាមនេះ ខ្ញុំសូមដកស្រង់សម្ដី “ខ្ញុំសូមឧទ្ទេសនាម អំពីសេចក្ដីណែនាំរបស់បក្សលើបញ្ហាមួយចំនួនសំខាន់ៗ សម្រាប់អនុវត្តនៅក្នុងឆមាសទី២ ឆ្នាំ១៩៧៧ គឺជាបញ្ហាសំខាន់ៗដែលត្រូវអនុវត្តពីពេលនេះទៅដល់ចុងឆ្នាំ១៩៧៧។ តាមខ្ញុំដឹង តាមសេចក្ដីរាយការណ៍របស់ភូមិភាគក្នុងប៉ុន្មានថ្ងៃកន្លងទៅនេះ សមមិត្តគ្រប់តំបន់បានរៀនសូត្រនូវសេចក្ដីណែនាំរបស់បក្សនេះហើយ ក៏ប៉ុន្តែក្នុងឱកាសដែលរៀនសូត្រពីស្រុកគំរូ ពេលនេះ កំពង់ត្រឡាចលើ ក៏គណៈបក្សភូមិភាគរួមជាមួយ -- យល់ឃើញថា ចាំបាច់ផ្សាយនូវសេចក្ដីណែនាំនេះ បញ្ជាក់ថែមទៀត ដើម្បីជូនសមមិត្តពិនិត្យពិចារណាថែម ក្នុងន័យអនុវត្តជាក់ស្ដែងនៅក្នុងមូលដ្ឋានរៀងៗខ្លួន។

ការដែលយើងលើបញ្ហានេះជាថ្មីមកបញ្ជាក់ដើមទៀត គឺដើម្បីអ្វី? គឺដើម្បីពិនិត្យនៅចុងឆ្នាំតើយើងសម្រេចការ សម្រេចភារកិច្ចយ៉ាងម៉េចឲ្យបានខ្លាំង សម្រេចភារកិច្ចឆ្នាំ៧៧ របស់យើងឲ្យបាន

ទាំងស្រុង នេះជាសំណួមពរ។ បើប្រសិនណាយើងក្តាប់នូវសេចក្តីណែនាំនេះបានច្បាស់លាស់ក្នុងន័យអនុវត្តជាក់ស្តែង នោះច្បាស់ជាយើងសម្រេចផែនការបានក្នុងឆ្នាំ១៩៧៧។ ដូច្នេះសេចក្តីណែនាំដែលនឹងបញ្ជាក់នៅពេលនេះ គឺដើម្បីសម្រេចបានបីតោន និងប្រាំមួយតោន ដើម្បីវាយប្រហារ និងបោសសម្អាតខ្មាំង និងដើម្បីកសាងជួរដឹកនាំរបស់បក្ស”។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្តី។

[១០:៣៤:២៨]

នៅទំព័រចាប់ផ្តើមនៃផ្នែកនេះដដែល នៃឯកសារនេះ គឺខ្មែរ ERN លេខ 00062949, អង់គ្លេស គឺ 00399223, បារាំង គឺ 00611827។ នៅក្នុងនេះគឺ យោងទៅលើសេចក្តីសម្រេចលើសន្និបាតភូមិភាគ ដែលបានរៀបចំកាលពីឆ្នាំ១៩៧៧ លើកមុន។ ខ្ញុំសូមអានចេញពីឯកសារនេះ ដកស្រង់សម្តី “តាមការសម្រេចរបស់បក្សទូទាំងប្រទេសក្តី តាមការសម្រេចរបស់បក្សភូមិភាគបស្ចិមក្តី តាមខ្ញុំចាំក្នុងសន្និបាតខែ២ ដល់ ខែ២ ៧៧ នៅកំពង់ឆ្នាំង គឺយើងឯកភាពគ្នា ជាសហករណ៍ ១.000គ្រួសារ ធ្វើម៉េច ឲ្យមានបេក្ខជនប្រមាណ៣០រូប អង្គការស្នូល៥០រូប ហើយមានជនចម្រើន៨០រូប។ នេះនិយាយជាមធ្យម”។ បញ្ចប់ការដកស្រង់សម្តី។

នៅក្នុងសុន្ទរកថាដែលបានលើកឡើងនៅក្នុងភូមិភាគបស្ចិម ហើយបានចុះផ្សាយនៅក្នុងទស្សនាវដ្តីបដិវត្តទង់ គឺរួមមានការណែនាំមួយចំនួនបានបញ្ជូនឲ្យភូមិភាគអនុវត្ត។

លោកប្រធាន ជាទីគោរព! គឺខ្ញុំរៀបនឹងចូលផ្នែកនេះ នៅក្នុងឯកសារ។ ដូច្នេះហើយលោកប្រធានគួរគិតថា ឲ្យខ្ញុំបន្តរហូតដល់ចប់ ឬក៏យើងខ្ញុំអាចចាប់ផ្តើមក្រោយពេលឈប់សម្រាកពិសាកាហ្វេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោង១១ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៦ នាទី ដល់ម៉ោង ១០:៥៩ នាទី)*

[១០:៥៩:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការបង្ហាញឯកសារ។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលយើងឈប់សម្រាកនោះ គឺថាខ្ញុំបង្ហាញឯកសារ E3/193 គឺទស្សនាវដ្តីទង់បដិវត្តខែសីហា ឆ្នាំ១៩៧៧ ដែលចុះផ្សាយសុន្ទរកថាលើកឡើងដោយតំណាងអង្គការបក្សនៅក្នុងសន្និបាតភូមិភាគបស្ចិម។ ខ្ញុំនឹងចូលទៅដល់ផ្នែកមួយនៅក្នុងសុន្ទរកថានេះ ដែលក្នុងនោះរៀបរាប់លើកឡើងអំពីការអនុវត្តរបស់ភូមិភាគនានា។

[១១:០១:១២]

ក្រោយការពន្យល់ប្រវត្តិលម្អិតរបស់នៃជនក្បត់នៅភូមិភាគបស្ចិម គឺយើងឃើញថាមានការលើកឡើងចំពោះចំណុចនេះផងដែរ នៅក្នុងសក្ខីកម្មប៉ុន្មានថ្ងៃនេះ។ ខ្ញុំនឹងអាននូវសេចក្តីសម្រេចមួយចំនួនដែលក្នុងនោះមាននូវលេខខ្មែរ ERN 0062955 (ស៊ីក), អង់គ្លេសគឺមានលេខ ERN 00399228 ទៅដល់ 399229, បារាំងគឺ 00611832--

**អ្នកបកប្រែ៖**

លេខ ERN ជាភាសាខ្មែរ អ្នកបកប្រែសូមកែតម្រូវ គឺ 00062955។

**លោក ឌេល លីសាក់៖**

ដែល ក្នុងអត្ថបទនេះគឺថា មានសុន្ទរកថាថ្លែងនៅក្នុងសន្និបាតភូមិភាគបស្ចិម។ ក្នុងនេះខ្ញុំសូមដកស្រង់សម្តី "ទី១ បក្សកំណត់ថា ពង្រីកបេក្ខជនថ្មីតែកន្លែងណាដែលល្អ គ្មានសមាសភាពក្បត់។ ខ្ញុំនិយាយកន្លែងហ្នឹងបានសេចក្តីថា នៅក្នុងតំបន់ នៅក្នុងស្រុក ក្នុងការដ្ឋាន ក្នុងក្រសួង មន្ទីរតូចធំ អង្គភាពផ្សេងៗ កន្លែងណាល្អ ដែលគ្មានក្បត់ ដែលមានសមាសភាពល្អ សមាសភាពជាកម្មាភិបាល ជាបេក្ខជនល្អៗគឺត្រូវពង្រីក នេះទី១។ ទី២ បក្សកំណត់ថា កន្លែងដែលមានសកម្មភាព ដែលអាក្រក់ ក្បត់នោះ គឺថាកន្លែងហ្នឹងមិនត្រូវពង្រីកទេ"។ សុន្ទរកថានេះ គឺបន្តប្រាប់ថា "៥០ភាគរយ នៃភូមិភាគ

សមាសភាពនៅក្នុងនោះ គឺ៥០ភាគរយ គឺមិនល្អ មានសមាសភាពមិនល្អទេ។ ១៥ ទៅ ២០ភាគរយ -- សមាសភាព១៥ ទៅ ២០ ភាគរយ គឺជាជនក្បត់។ កម្មាភិបាលភូមិភាគត្រូវបានជម្រាបថា ទាហានពីរបបចាស់ និងអ្នកជំនួញនៅកំពង់សោម គ្រប់គ្រងទៅលើសហករណ៍នៅក្នុងតំបន់"។

[១១:០៣:៥៤]

បន្ទាប់មកនៅខ្មែរ ERN លេខ 00062963 -- គឺ 00062963 រហូតទៅដល់ 62964, ERN ជាភាសាអង់គ្លេស 00399235, បារាំងគឺមានលេខ 00611839។ ការណែនាំដូចតទៅនេះ បានលើកឡើងនៅក្នុងអត្ថបទនេះ។ ខ្ញុំសូមដកស្រង់សម្ដី "យកភូមិភាគជាឧទាហរណ៍ នៅក្នុងភូមិភាគនេះមានខ្មាំងបង្កប់នៅក្នុងតំបន់ គឺមានសមាសភាពខ្មាំងបង្កប់។ នៅក្នុងស្រុកក៏មានខ្មាំងបង្កប់...។ល។ ក្រោយពីដែលយើងទទួលជ័យជម្នះនៅក្នុងប្រទេស ពួកគេបានស៊ីរូងផ្ទៃក្នុង ដើម្បីទាញយកអំណាចពីយើង គឺអំណាចភូមិភាគ អំណាចតំបន់ អំណាចស្រុក ជាពិសេសពួកគេបានយក ក្ដោបក្ដាប់អំណាចក្នុងសហករណ៍ដោយសារតែយើងមានសមាជិកពួងមួយចំនួនតែប៉ុណ្ណោះនៅក្នុងកន្លែងនោះ។ អ្វីដែលជាទំនាស់គឺយើងត្រូវធ្វើ មើលសមាសភាពទាំងឡាយដែលគ្រប់គ្រងនៅក្នុងនោះ ហើយធ្វើយ៉ាងណាយើងមើលទៅលើក្រុមបង្កបង្កើនផល ក្រុមច្រូតកាត់ តើនរណាគេជាអ្នកគ្រប់គ្រងសហករណ៍។ កសិករក្រីក្រថ្នាក់កណ្ដាល ឬក៏ថ្នាក់កណ្ដាលខ្ពស់នោះ គឺជាវណ្ណៈមួយដែលយើងត្រូវពិចារណា"។

បន្តទៅមុខទៀត ខ្មែរ ERN គឺ 00062964 ទៅដល់ 62965, ERN ជាភាសាអង់គ្លេស 00399236, បារាំងគឺមានលេខ ERN 00611840។ គឺមានការលើកឡើងដូចតទៅ "សហ -- រៀបចំកសិករក្រ កសិករថ្នាក់កណ្ដាល ថ្នាក់ក្រោមទៅសហករណ៍ ទៅវៃកម្ទេចរដ្ឋអំណាច វណ្ណៈផ្សេង ដែលមកលួចកាន់កាប់សហករណ៍របស់យើងឲ្យកសិករក្រ និងកសិករកណ្ដាលថ្នាក់ក្រោមទៅកាន់កាប់វិញ"។ ឥឡូវយើងសម្រិតសម្រាំងប្រយុទ្ធក្នុងភាគបាន ប្រយុទ្ធក្នុងតំបន់បាន និងប្រយុទ្ធក្នុងស្រុកបាន ក៏ប៉ុន្តែសហករណ៍យើងមិនទាន់ប្រយុទ្ធបានជាមូលដ្ឋាននៅឡើយ។ ត្រូវរៀបចំកម្លាំងទៅវៃ វៃកម្ទេចខ្មាំង និងសមាសភាពមិនល្អ បង្កប់កាន់កាប់នៅក្នុងសហករណ៍។ យកកម្លាំងណាទៅវៃ យកកសិករ និងកសិករកណ្ដាលថ្នាក់ក្រោមទៅវៃ។ បញ្ហានេះមិនមែនតែភូមិភាគបស្ចិមទេ គ្រប់ភូមិភាគទូទាំងប្រទេស គឺយ៉ាងនេះ។ ដូច្នេះយើងធ្វើវាអីមិនបានទេ ត្រូវឃើញថាសហករណ៍ខ្មាំង និងវណ្ណៈផ្សេងទៅកាន់កាន់ -- នៅកាន់កាប់នៅឡើយ" បញ្ចប់ការដកស្រង់សម្ដី។

[១១:០៧:៤១]

នៅចុងក្រោយនៃសុន្ទរកថានេះ គឺមានការរៀបរាប់អំពីរឿងរ៉ាវដោយសមមិត្តតំណាងបក្ស ហើយក្នុងនោះក៏មានការណែនាំផងដែរ។ គឺយើងឃើញនៅត្រង់ទំព័រជាភាសាខ្មែរ ERN លេខ 00062977 រហូតទៅដល់ 00062978, ERN ជាភាសាអង់គ្លេស 00399245 ទៅដល់ 3992446, បារាំងមានលេខ ERN 00611850 រហូតដល់ 611851។ សូមដកស្រង់សម្តី “ការប្រជុំសន្និបាតតំណាងបក្សភូមិភាគនៅខែ៥ ឆ្នាំ៧៦ នៅលង្វែក ខ្ញុំទៅដល់ជួបគណៈភាគភ្លាម មានឈ្មោះ ហំ នៅក្នុងនោះដែរ។ និយាយលេងពីនេះពីនោះ។ ហំ ថា គោឯកជនធាត់ជាងគោសមូហភាព។ គោអនុធន គោកសិករមានធាត់ជាងគោកសិករក្រ។ ក្នុងសន្និបាត ខ្ញុំប្រយុទ្ធភ្លាមត្រូវតស៊ូ។ ជាតស៊ូវណ្ណៈ ជាការតស៊ូខាងជំហរនយោបាយ។ ខាងជំហរសតិអារម្មណ៍ និងខាងជំហរចាត់តាំង។ បើប្រសិនណាមិនតស៊ូទេ កម្លាំងវាផ្សាយមកនៅក្នុងសន្និបាតទៀត។ យើងចេះតែកាន់ច្រឡំ។ ជឿទៅថា គោឯកជនធាត់ជាងគោសមូហភាព។ ដូច្នេះវាយរបបសមូហភាព វាយបដិវត្តន៍សង្គមនិយមរបស់បក្សដោយដឹងខ្លួន ឬមិនដឹងខ្លួន។ ប៉ុន្តែឈ្មោះ ហំ វាវាយដោយចាត់តាំង វាវាយក្នុងឋានៈជាខ្មាំង។ ក្នុងពេលនោះ យើងមិនទាន់ដឹងថា វាជាខ្មាំងនោះទេ។ ប៉ុន្តែនិយាយយ៉ាងនេះយើងដឹងថា គោលជំហរប្រឆាំងបដិវត្តន៍ ប្រឆាំងរបបសមូហភាពហើយ។ អ៊ីចឹងបានជាក្នុងសន្និបាតយើងតស៊ូភ្លាម។ មួយរយៈពេលយើងរកឃើញថា ឈ្មោះ ហំ វាជាខ្មាំងបង្កប់ខាងផ្ទៃក្នុងបក្សយើង។ ដូច្នេះ ធាតុដែលវាចេញមកវាយរបបសង្គមនិយម។ គ្រាន់តែពីរឿងប៉ុណ្ណឹង យើងឃើញធាតុវាបណ្តើរៗ។ វាវាយតាំងពីតូចៗ អ៊ីចឹងទៅ។ តាមពិត វាវាយរបបសមូហភាព។ អ៊ីចឹងបានជាត្រូវបំផុសកសិករក្រ និងកណ្តាលថ្នាក់ក្រោមឲ្យយល់ហេតុផល បើប្រសិនណា បើកទ្វារឲ្យឯកជនឡើងវិញ តើវណ្ណៈកសិករក្រ និងកណ្តាលថ្នាក់ក្រោមទៅជាស្អី? ដូច្នេះ ត្រូវបំផុស ១) បំផុសក្នុងជួរយើង ២) បំផុសក្នុងប្រជាជន។

[១១:១១:២៩]

បន្តទៅខាងក្រោមទៀត មានកថាខណ្ឌមួយដែលសរសេរបន្ថែម។ សុន្ទរកថានេះបញ្ចប់ដូចតទៅ សូមដកស្រង់សម្តី “ឥឡូវដំណើរការយ៉ាងម៉េច ក្នុងការរៀបចំសហករណ៍។ ស្នើដល់ចុងឆ្នាំ១៩៧៧ រៀបចំសហករណ៍ក្នុងភូមិភាគទាំងមូលឲ្យល្អស្អាតតាមមាគ៌ាវណ្ណៈឲ្យបានយ៉ាងហោច៥០ភាគរយឡើងទៅ។ ដូច្នេះធ្វើម៉េចពីនេះទៅចុងឆ្នាំ ត្រូវរៀបចំឲ្យកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោមទៅកាន់រដ្ឋអំណាចគ្រប់ផ្នែកនៅក្នុងសហករណ៍នីមួយៗ ឲ្យបានចំនួនលើសពី៥០ភាគរយ នៃសហករណ៍ទូទាំងភូមិភាគ។ ហើយដល់ពាក់កណ្តាលឆ្នាំ១៩៧៨ យ៉ាងយូរឲ្យបាន១០០ភាគរយ”។ ខ្ញុំសូមបញ្ចប់ការដក

ស្រង់សម្តី។

ហើយនៅក្រោមហ្នឹងបន្តិច នៅចុងអត្ថបទទស្សនាវដ្តីទង់បដិវត្តនេះ គឺក្នុងនេះលើកឡើងអំពីការសិក្សា និងការអនុវត្តនៅទូទាំងប្រទេស។ ខ្ញុំដកស្រង់ដូចតទៅ “ដឹងថាជាខ្មាំងទេ ប៉ុន្តែយើងត្រូវតែសិក្សាអំពីបញ្ហានេះឲ្យបានហ្មត់ចត់ ដើម្បីអនុវត្តនៅក្នុងភូមិភាគនីមួយៗ ហើយធ្វើយ៉ាងណាឲ្យមានលទ្ធផលល្អ”។

[១១:១៣:១៨]

លោក លោកស្រីចៅក្រម ជាទីគោរព! ចម្លើយសារភាព ស-២១ របស់ ហ៊ូ ហ៊ីម ហៅ ហំ ជាអនុលេខាតំបន់៣២ នៃភូមិភាគបស្ចិម ដែលក្នុងនោះគាត់ប៉ានរិះគន់នូវទ្រព្យសម្បត្តិឯកជន គឺឯកសារ IS71 -- IS571។ នៅក្នុងឆ្នាំ១៩៧៨ ផងដែរ បក្សក៏បានចេញផ្សាយនូវទស្សនាវដ្តីទង់បដិវត្តមួយទៀតដែលក្នុងនោះរួមមានបទបង្ហាញសុន្ទរកថានៅក្នុងសន្និបាតភូមិភាគបស្ចិម។ នេះជាឯកសារមួយទៀតដែលខ្ញុំនឹងបង្ហាញ E3/745 ឯកសារ E3/745។ ឯកសារនេះគឺទស្សនាវដ្តីទង់បដិវត្តៗ ចុះថ្ងៃមីនា ឆ្នាំ១៩៧៨។ ផ្នែកដំបូងនៃឯកសារនេះរួមមានមតិយោបល់របស់សមមិត្តបក្សកុម្មុយនីស្តកម្ពុជា គឺលេខាបក្សកុម្មុយនីស្តកម្ពុជាក្នុងសន្និបាតប្រចាំឆ្នាំ៧៧ របស់ភូមិភាគបស្ចិម។

[១១:១៤:៣៩]

ខ្ញុំសូមអានការដកស្រង់សម្តីមួយចំនួនរបស់ ប៉ុល ពត ពាក់ព័ន្ធទៅនឹងការការពារចំពោះខ្មាំងផ្ទៃក្នុង។ លេខយោងខ្មែរ ERN គឺ 00064455 រហូតទៅដល់ 0 -- ទៅដល់លេខ 64456, អង់គ្លេសមានលេខ 00504072, បារាំង គឺមានលេខ 00491845។ នៅក្នុងទំព័រនេះ លេខាបក្សកុម្មុយនីស្តកម្ពុជាបានធ្វើសុន្ទរកថាទៅដល់កម្មាភិបាលភូមិភាគបស្ចិមដូចតទៅ សូមដកស្រង់សម្តី៖ “ក្នុងខែ៥ ឆ្នាំ១៩៧៦ សមាសភាពខ្មាំងនៅកាន់កាប់អំណាចច្រើននៅឡើយ។ មាគ៌ារបស់បក្សគ្រប់ផ្នែកមិនបានផ្សាយ ចុះដល់មូលដ្ឋាន ហើយក៏មិនបានអនុវត្តនៅក្នុងមូលដ្ឋានទៀតផង មកពីអ្វី? មកពីយើងមិនបានដោះស្រាយបញ្ហាចាត់តាំង។ ប៉ុន្តែដល់ឆ្នាំ១៩៧៧ យើងដោះស្រាយបញ្ហាចាត់តាំងបាន។ ក្រោយពីប្រយុទ្ធខាងនយោបាយ ខាងសតិអារម្មណ៍ យើងប្រយុទ្ធខាងចាត់តាំង។ យើងសម្រិតសម្រាំងខាងចាត់តាំង លុះដល់ការយើងបានសម្រិតសម្រាំងខាងចាត់តាំងបានច្រើនជាងមូលដ្ឋានទៅ ខាងនយោបាយសតិអារម្មណ៍របស់បក្សក៏បានអនុវត្តនៅក្នុងមហាជន។ ដូច្នេះ សមាសភាពក្នុងឆ្នាំនេះ វាខុសពីឆ្នាំ៧៦ ច្រើនណាស់ ហើយវាខុសពីកាលខែ២ ឆ្នាំ៧៧ ឆ្ងាយណាស់ទៀតផង។ អ៊ីចឹងបានយើងឃើញថា ការប្រយុទ្ធនេះតឹង

តែងណាស់ ប្រែប្រួល ក្រឡាប់ចាក់ ព្រោះហេតុអ្វី? ព្រោះអ្នកកាន់អំណាចនៅក្នុងកងទ័ព នៅក្នុងបក្ស នៅក្នុងក្រសួង មន្ទីរមួយចំនួន ហើយដែលចូលធ្វើសកម្មភាពបដិវត្តន៍មកយូរហើយ ខ្វះតាំងពីជំនាន់តស៊ូ ហិង្សានយោបាយរាប់សិបឆ្នាំហើយ ហៅថា មានស្លាក មានយីហោល្បីល្បាញ ហើយមកលួចបង្កប់ នៅក្នុងជួររដ្ឋអំណាចដើម្បីបំផ្លាញបក្ស បដិវត្តន៍យើង។ យើងរកឃើញខ្សែទាំងអស់នេះ ហើយកំចាត់វាអស់ជាមូលដ្ឋាន ធ្វើឲ្យមុខមាត់ភូមិភាគនេះប្រែប្រួលថ្មីស្រឡាងច្រើនណាស់ អាចសន្មតថា ជាក្រឡាប់ចាក់បាន"។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដី។

[១១:១៧:៣៣]

ត្រង់ខ្មែរ ERN 00064456 ទៅដល់ 57, អង់គ្លេសគឺមានលេខ 00504073 បារាំងគឺ 00491846។ សមមិត្តលេខាបន្តលើកឡើងដូចតទៅ សូមដកស្រង់សម្ដី៖ "ឆ្នាំ៧៧ គឺ១២ខែ យើងឃើញថាវាមានការអូសបន្លាយជាច្រើនឆ្នាំ។ នៅក្នុងឆ្នាំ១៩៧៧ គឺយើងឃើញថា ទសវត្សរ៍នេះគឺបានរកឃើញ រឿងរ៉ាវទាំងឡាយត្រូវបានក្រឡាប់ចាក់។ តែមួយភ្លែតយើងឃើញមានការផ្លាស់ប្ដូរធំធេង។ នេះគឺជាអ្វីដែលយើងហៅថា "បដិវត្តន៍អស្ចារ្យរបស់យើង"។ នៅពេលយើងកម្ទេចខ្មាំង -- បើសិនមិនទាន់បានកម្ទេចខ្មាំង គឺស្ថានភាពមិនក្រឡាប់ចាក់នោះទេ ខ្មាំងនៅជាមួយយើង ខ្មាំងនៅបង្កប់នៅសហករណ៍ នៅក្នុងគណៈកម្មាធិការស្រុក គណៈកម្មាធិការតំបន់ និងគណៈកម្មាធិការផ្សេងទៀត។ នេះគឺជាបញ្ហាធ្ងន់ធ្ងរដោយសារតែ ស្រុក តំបន់។ល។ គឺមានសិទ្ធិគ្រប់គ្រងសហករណ៍។ ដូច្នេះហើយវាកាន់តែធ្ងន់ធ្ងរ។ មជ្ឈិមមិនបានសិក្សា និងរៀនសូត្រពីការវាយប្រហារ វាយប្រយុទ្ធនៅក្នុងឆ្នាំ១៩៧៧។ យើងត្រូវតែវាយកម្ទេចខ្មាំង សម្រិតសម្រាំងខ្មាំង" សូមបញ្ចប់ការដកស្រង់។

[១១:១៩:២១]

ឧទាហរណ៍មួយនៃសកម្មភាពតំបន់វាយប្រយុទ្ធនោះគឺថា បានលើកឡើងនៅក្នុងសុន្ទរកថាមួយ ត្រង់ខ្មែរ ERN 00644558 ទៅដល់ 59, អង់គ្លេសគឺ 00504073, បារាំងគឺ 00491847 រហូតទៅដល់ 48។ នៅក្នុងផ្នែកនេះ គឺមានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី៖ "ឧទាហរណ៍ ខ្មាំងយួនវាវាយយើងភ្លាម ផ្នែកខាងកើត បក្ស សារចរភ្លាម ឲ្យតាមដានគ្រប់មូលដ្ឋាន តើមានសមាសភាពខាងក្នុងយ៉ាងម៉េច? វាឃោសនាឲ្យយួនវាយយើងយ៉ាងម៉េច? យើងណែនាំភ្លាម យើងបានគ្រប់គ្រងម្ចាស់ការភ្លាម ដល់យួនវាយយើងភ្ញាក់ងារយួនក៏លេចមុខ ភ្នាក់ងារ សេ.អ៊ី.អា ក៏លេចមុខ។ សេ.អ៊ី.អា និងយួនវាដូចតែគ្នា វាវាយបដិវត្តន៍កម្ពុជាដូចគ្នា។ វាគ្រាន់តែមួយស្លាកយួន មួយស្លាក សេ.អ៊ី.អា ខ្លឹមសារ

វាតែមួយ ភារកិច្ចវាតែមួយ សមាសភាពដែលមិនល្អ សមាសភាពដែលបំផ្លិចបំផ្លាញមកឃោសនា ឬក៏មកធ្វើវិច្ឆេទកម្មអ្វីផ្សេងៗក៏ត្រូវប្រយុទ្ធដោះស្រាយឲ្យពេលវេលា។ បើយើងពិនិត្យឲ្យទាន់ពេលវេលា យើងឃើញខ្លាំងភ្លាម"។ ត្រង់ខ្មែរ ERN 004460 (ស៊ីក) រហូតទៅដល់ 61, អង់គ្លេស ERN 00504075 និងបារាំង ERN 00491849។

[១១:២១:៥៥]

សមមិត្តលេខាបានបញ្ចប់ការលើកឡើងចំណុចនេះ ដូចតទៅ សូមដកស្រង់សម្ដី "អំពីបញ្ហាទាំងអស់នេះ ដើម្បីការពារឲ្យបានល្អមានតែសម្រិតសម្រាំងបក្សផ្ទៃក្នុងកងទ័ព ផ្ទៃក្នុងប្រជាជនឲ្យល្អ។ ឲ្យពួកគេស្អាតស្អំ បញ្ហានេះជាបញ្ហាគន្លឹះទោះបីមានកងទ័ពច្រើនយ៉ាងណាក៏ដោយ មានអាវុធច្រើនយ៉ាងណាក៏ដោយ បើបក្សមិនស្អាត បើកងទ័ពមិនស្អាត បើប្រជាជនមិនស្អាតទេ នោះការពារក៏មិនបានដែរ"។

លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំសូមឲ្យលោក លោកស្រីចាប់អារម្មណ៍ត្រង់ឯកសារនេះផងដែរ ដែលផ្នែកចុងក្រោយនៅក្នុងសុន្ទរកថារបស់សមមិត្តលេខា គឺត្រង់ខ្មែរ ERN លេខ 00064466, អង់គ្លេស ERN គឺ00504081, បារាំងគឺ 00491853។ ត្រង់ផ្នែកនេះ រួមមានការលើកឡើងរបស់សមមិត្តលេខាអំពីផែនការឆ្នាំ៧៨ ដាក់ជូនភូមិភាគបស្ចិម។

[១១:២៣:៣០]

ឯកសារចុងក្រោយដែលខ្ញុំសូមលើកឡើងបង្ហាញអំពីអ្វីដែលមជ្ឈិមនេះបញ្ជូនទៅភូមិភាគ បញ្ជូនមាគ៌ានយោបាយ និងគោលនយោបាយរបស់បក្ស គឺឯកសារ E3/1094 ។ គឺរបាយការណ៍ប្រចាំខែបញ្ជូនទៅភូមិភាគបស្ចិម។ ហើយក៏បានបញ្ជូនអង្គការវិញនៅក្នុង -- មកអង្គការវិញនៅក្នុងថ្ងៃ០៤ ខែសីហា ឆ្នាំ៧៨។ ខ្ញុំលើកទៅលើផ្នែកមួយតែប៉ុណ្ណោះ គឺផ្នែកទី៤ នៅក្នុងរបាយការណ៍ដែលអាចរកឃើញនៅខ្មែរ ERN លេខ 00143611 ដល់ 143612, អង់គ្លេស ERN គឺមានលេខ 00315376, បារាំងគឺមានលេខ 00593532 ដែលក្នុងនោះរួមមានការលើកឡើងដូចតទៅ លើកឡើងអំពីដំណើរការនៃផែនការ និងគោលនយោបាយរបស់មជ្ឈិម ហើយបញ្ជូនទៅដ្ឋាន សូមដកស្រង់សម្ដី "ក្នុងខែ៧ ៧៨ នេះ យើងបានបើកវគ្គអប់រំរៀនសូត្រជារួម ឲ្យកម្មាភិបាលបក្ខជន គ្រប់តំបន់ទាំងអស់នៅក្នុងភូមិភាគចាប់តាំងពីសមាជិកតំបន់ គណៈស្រុក គណៈសហករណ៍ និងបក្ខជន ជាទូទៅ ព្រមជាមួយនេះ។ ព្រមជាមួយនេះ បានបើកវគ្គរៀនសូត្រឲ្យអង្គការស្នូលជាទូទៅ ទាំងយុវកក ទាំងជនបង្គោល។ ឯកសារ

អប់រំបានយកឯកសារទាំងប្រាំពីររបស់បក្ស ដែលបក្សបានអប់រំក្នុងខែ៦ ក្នុងឆមាសទី១ ឆ្នាំ១៩៧៨ មករៀនសូត្រ ដោយយកចំណុចខ្លះដែលត្រូវរៀនសូត្រជាទូទៅ។ លទ្ធផលនៃការរៀនសូត្រឃើញថា កម្មាភិបាល បក្ខជន ព្រមទាំងអង្គការស្នូល បានយល់ និងជ្រួតជ្រាបលើគ្រប់ឯកសារ ហើយជាពិសេស លើមាគ៌ាការការពារប្រទេស ការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមគ្រប់ផ្នែក ហើយ បានយល់ច្បាស់កក្តាសំខាន់ គឺកសាងកម្លាំងដឹកនាំ និងជាពិសេស កម្ចាត់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ហើយ បានយល់ជ្រួតជ្រាបនូវវិធានការ និងវិធីដែលបក្សបានលើការប្រមូលកម្លាំងបន្ថែមមិត្ត បន្ថយសត្រូវ នេះ ច្បាស់លាស់"។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដី។

[១១:២៦:៤៨]

លោក លោកស្រីចៅក្រម ជាទីគោរព! ឯកសារមួយចំនួនទៀត ដែលខ្ញុំសូមបង្ហាញនៅក្នុងថ្ងៃ នេះផងដែរ គឺក្រុមសំណុំឯកសារដែលបានបក្សបានបញ្ជូនផ្សព្វផ្សាយអំពីការណែនាំសារចរ និងមាគ៌ា របស់បក្ស។ នៅពេលនេះ គឺខ្ញុំសូមលើកឧទាហរណ៍ចេញពីឯកសារនេះមួយចំនួន។ ជាដំបូង គឺឯកសារ E3/781 ៗ នេះជាសារចរដែលបានចែកជូននៅក្នុងខែធ្នូ ឆ្នាំ៧៥ មានចំណងជើងថា "ការពិនិត្យទៅលើ ការគ្រប់គ្រង និងការអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំប្រទេសគ្រប់ផ្នែក"។ ឯកសារនេះ គឺចុះខែកញ្ញា ឆ្នាំ១៩៧៥។ គោលបំណងនៃឯកសាររបស់ឯកសារនេះ គឺមានសរសេរនៅក្នុងចំណុចទី១ គឺតាំងពីដើមដំបូងមកម្ល៉េះ ដូចដែលបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "ឯកសារនេះ ស្តីពី សេដ្ឋកិច្ច ហិរញ្ញវត្ថុ វប្បធម៌ សង្គមកិច្ច។ ផ្នែក១ ការក្តាប់ និងអនុវត្តមាគ៌ានយោបាយ កសាងកសិកម្ម របស់បក្ស។ សំណួមពរ ពិនិត្យមើលការក្តាប់ ការជ្រួតជ្រាប និងការអនុវត្តនូវមាគ៌ាកសិកម្មរបស់បក្ស ដើម្បីជំរុញកសិកម្មឲ្យបានចម្រើន លោតផ្លោះជាអតិបរមា តាមទិសណែនាំរបស់បក្ស"។ ខ្ញុំសូមបញ្ចប់ ការដកស្រង់សម្ដី។

[១១:២៨:៤]

ប្រធានបទមួយចំនួនទៀត ក៏បានលើកឡើងនៅក្នុងសារចរនេះផងដែរ រួមទាំងសេចក្តីសម្រេច របស់បក្សក្នុងការប្រើប្រាស់ថវិកា។ ខ្មែរ ERN គឺមានលេខ 00072389, អង់គ្លេសគឺ 00523585, បារាំង គឺ 00543760 រហូតទៅដល់ 61។ ឯកសារបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "យើងមិនទាន់ត្រូវការចាំបាច់ចាយប៉ុន្មានទេ។ មូលហេតុដែលមិនទាន់ គឺមកពីបញ្ហាគ្រប់គ្រង យើងមិន ទាន់ម្ចាស់ការ មិនទាន់មានបទពិសោធន៍ថែរក្សា។ មូលហេតុមួយទៀត មានខ្មាំង វាធ្វើសកម្មភាព

បំផ្លាញលុយយើង។ ពិសេស ចក្រពិត្តអាមេរិកដែលដើរសំខាន់”។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្តី។

[១១:៣០:០០]

ការលើកឡើងនៅក្នុងនេះ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់លុយ គឺបន្តនិយាយនៅក្នុងទំព័រដូចតទៅដូចខាងក្រោមនេះទៀត។ ខ្មែរគឺ 72390, អង់គ្លេស 25235866, បារាំងគឺ 543761។ សូមដកស្រង់សម្តី “ដូច្នេះ បើយើងចាយលុយ លុយនេះនឹងធ្លាក់ទៅកណ្តាប់ដៃឯកជន។ បើធ្លាក់យ៉ាងនេះ នាំឲ្យកើតកម្មសិទ្ធិស្វនត្ត បើមានកម្មសិទ្ធិស្វនត្តហើយ គឺឃ្លាតពីសមូហភាព។ លុយជាឧបករណ៍មួយ ដែលវាទៅជាសិទ្ធិអំណាច។ បើសិនជាលុយនេះធ្លាក់ទៅក្នុងកណ្តាប់ដៃពួកមិនល្អ ខ្លាំង វាប្រើដើម្បីធ្វើសកម្មភាពបំផ្លាញជួរកម្មាភិបាលយើងដែលមិនល្អ ដោយវាប្រើជាការសូកប៉ាន់ យ៉ាងនេះ យ៉ាងនោះ។ ដូច្នេះយូរៗទៅធ្លាក់ៗទៅប្រមូលកម្មសិទ្ធិនេះ បង្កើតកម្មសិទ្ធិនេះ តាមរយៈនេះវាជាសិទ្ធិអំណាចមួយ ព្រោះវាមានលុយ វាសូកប៉ាន់ទាក់ទាញមនោសញ្ចេតនាបាន។ បើយ៉ាងនេះ១ឆ្នាំ ១០ឆ្នាំ ២០ឆ្នាំ សង្គមកម្ពុជាស្អាតស្អំយើង នឹងទៅជាប្រទេសវៀតណាម” បញ្ចប់ការដកស្រង់សម្តី។

[១១:៣១:៣៦]

ផែនការរបស់បក្សក្នុងការនាំចេញអង្ករ ក៏បានរៀបរាប់នៅក្នុងសាវាចរណ៍នេះផងដែរ គឺខ្មែរ ERN លេខ 00072393, អង់គ្លេសគឺ 00523548, បារាំងគឺ 00543763 ដល់ 764។ ជាថ្មីម្តងទៀតខ្ញុំសូមដកស្រង់សម្តី “យើងអាចផលិតស្រូវបានបីតោន ៣លានតោន។ យើងទុកសម្រាប់ប្រជាជនហូប ១,៨ លានតោន សម្រាប់ខាងសង្គមកិច្ច ៤០០.០០០ តោន យើងនៅសល់ ៨០០.០០០ តោន។ ចំនួននេះយើងនាំចេញទៅក្រៅរកទុនបានមួយចំនួនដែរ។ ទុននេះយកមកកសាងប្រទេស។ បើគិតតាមទុននេះយើងយកមកកសាងប្រទេស និងការពារប្រទេសបានដែរ។ បញ្ហាចោទសព្វថ្ងៃនៅត្រង់ការប្រមូល និងការដឹកជញ្ជូនប៉ុណ្ណោះ។ នៅខាងមូលដ្ឋានត្រូវកំណត់ផលិតផល តើត្រូវឃុំ ស្រុក តំបន់ ភូមិភាគទុកប៉ុន្មាន ហើយផ្តល់មកខាងលើប៉ុន្មាន។ ថ្ងៃក្រោយយើងលុបភូមិមិនឲ្យមាន ហើយចាត់តាំងជាសហករណ៍វិញ”។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្តី។

[១១:៣៣:០៨]

ហើយសេចក្តីសារាចរណ៍ណែនាំក៏និយាយអំពីការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនទៅកាន់តំបន់ផ្សេងទៀតផងដែរ។ ខ្ញុំសូមអានសារចំនួនពីរនៅក្នុងអត្ថបទនេះ យើងអាចរកឃើញនៅក្នុង ERN 0072396 (ស៊ីក) ដល់ 72397, អង់គ្លេស ERN 00523590 ដល់ 591,

ERN ជាភាសាបារាំង 00543765 ដល់ 766។ ហើយផ្នែកនៃសារាចរណែនាំនេះ គឺមានការដកស្រង់ដូចតទៅ សូមដកស្រង់ "ក្នុងគុណសម្បត្តិ គឺខិតខំដោះស្រាយបានច្រើនដែរ តែខ្វះខាតក៏នៅមាន។ កន្លងមកខ្វះថ្នាំសង្កូវ នាំឲ្យឈឺថ្កាត់ស្គមស្គាំងគ្រុនចាញ់ខ្វះស្បៀងអាហារ។ បញ្ហានេះ ក៏នាំឲ្យប៉ះពាល់ដល់កម្លាំងពលកម្មកម្រិតសំខាន់ដែរ។ ប្រជាជនដែលខ្វះជាងគេ គឺពួកដែលជម្លៀសចេញពីទីក្រុងភ្នំពេញ និងនៅជុំវិញភ្នំពេញ"។ សូមដកស្រង់ "យើងត្រូវបែងចែកប្រជាជនទៅតាមសេចក្តីត្រូវការនៃកសិកម្ម។ យើងរៀបចំឲ្យសមស្របនឹងសេចក្តីត្រូវការ ត្រូវរៀបចំឲ្យល្អមកុំឲ្យឃ្លោងម្ខាងៗ។ យើងត្រូវរៀបចំចាត់ចែងកម្លាំងពលកម្មចំនួន ៥.០០០នាក់។ នៅក្នុងខេត្តព្រះវិហារមានលទ្ធភាព ដែលអាចផ្គត់ផ្គង់ស្បៀងអាហារបាន។ នៅព្រះវិហារស្នើ ៥០.០០០នាក់ចំពោះមុខសិន ហើយនៅព្រះវិហារមានប្រជាជនចាស់ប្រាំពីរនាក់ហើយ អំ! ៧០.០០០នាក់ហើយ។ នៅឧត្តរ ក៏ត្រូវការប្រជាជនផ្តល់ឲ្យខេត្តកំពង់ធំផងដែរ។ ដូច្នេះ ភូមិភាគនីមយៗត្រូវរៀបចំឲ្យសមស្របកុំឲ្យឃ្លោងម្ខាងៗ លៃលកប៉ុន្មានខាងលើ និងឥតយកទៅបែងចែកកន្លែងណាផ្សេងទៀតទេ"។ បញ្ចប់ការដកស្រង់សម្តី។

សេចក្តីសម្រេចចិត្តក្នុងការជម្លៀសប្រជាជន៥.០០០នាក់ គឺដោយយោងទៅលើសារាចរណែនាំនេះកើតចេញអំពីដំណើរទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅកាន់ភូមិភាគៗពាយ័ព្យដែលមាននៅក្នុងឯកសារ E3/216។ ខ្ញុំសូមបង្ហាញជូនឯកសារនេះ មុននឹងលើកជូននូវឧទាហរណ៍មួយចំនួននៃសារាចរណែនាំមួយចំនួនទៀត។

[១១:៣៦:២២]

កំណត់ហេតុនៃដំណើរទស្សនកិច្ច អំពីទស្សនកិច្ចអចិន្ត្រៃយ៍ទៅកាន់ភូមិភាគពាយ័ព្យគឺរាយការណ៍អំពីស្ថាភាពរួមនៅមូលដ្ឋាន។ កថាខណ្ឌនេះ គឺនិយាយអំពីសភាពការណ៍ប្រជាជន នៅត្រង់ទំព័រទី១ដែលមានការកត់សម្គាល់ដូចខាងក្រោម សូមដកស្រង់ "នៅគ្រប់កន្លែងបានរៀបចំឲ្យប្រជាជនមានជម្រក។ ប្រជាជនចាស់នឹងនរ។ ការរស់នៅមិនទាន់ខ្វះខាត។ បក្សបានផ្តល់ជយភណ្ឌពីក្រុងជាបន្តបន្ទាប់ ប៉ុន្តែកន្លែងស្រុកឆ្ងាយៗនៅខ្វះខ្លះដែរ។ ជំងឺឈឺថ្កាត់ក៏មានច្រើនដែរ។ ប្រជាជនថ្មីមានការខ្វះខាតខ្វះស្បៀងផង ខ្វះថ្នាំសង្កូវផង។ ខាងលិចល្វា និងតាមស្ទឹងមង្គលបុរី គ្រុនក្តៅច្រើន"។ បញ្ចប់ការដកស្រង់។

ផ្នែកនៃឯកសារនេះក៏និយាយអំពីស្ថានភាពខ្លាំង ដែលមានៗសេចក្តីថ្លែងការណ៍របស់គណៈមជ្ឈិមដូចតទៅ ដែលមាន ERN ជាភាសាខ្មែរ 00008486, ERN ជាភាសាអង់គ្លេស 00850973,

ERN ជាភាសាបារាំង 00343375។

សូមដកស្រង់ "នៅខាងក្នុងជួរយើង ដែលសម្រិតសម្រាំងមិនទាន់អស់ក៏នៅមាន។ វាប្រើប្រាស់ពួកនេះ ឲ្យនាំប្រជាជនរត់។ យើងចាប់វាបានជាបន្តបន្ទាប់ ហើយកំពុងបន្តរាវរកទៀត"។ បញ្ចប់ការដកស្រង់។

[១១:៣៨:២៥]

ផ្នែកនៃឯកសារនេះ គឺរាយការណ៍អំពីសេចក្ដីសម្រេច ឬជាមតិយោបល់របស់គណៈអចិន្ត្រៃយ៍ ដែលពាក់ព័ន្ធទៅនឹងប្រជាជនថ្មី ដែលត្រូវបានជម្លៀសទៅភូមិភាគពាយ័ព្យ។ រួមទាំងសម្រង់ពីរដែលខ្ញុំបានដកស្រង់ ដែលអាចរក ដែលមាននៅត្រង់ ERN ជាភាសាខ្មែរ 00008489, អង់គ្លេស 008550975 (ស៊ីក) ដល់ 976, ERN ជាភាសាបារាំង 00343377។ នៅផ្នែកមួយនៃឯកសារនេះ គឺគណៈអចិន្ត្រៃយ៍បានលើកឡើងដូចខាងក្រោមនេះ៖ "តួនាទីក្រោយពេលរំដោះទាំងស្រុងគឺសហករណ៍ស្រូបប្រជាជនថ្មីចេញពីទីក្រុងទាំងអស់ ជាពិសេសទីក្រុងភ្នំពេញ ហើយនៅពាយ័ព្យគឺបាត់ដំបង។ ប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបង មានសមាសភាពអាក្រក់គ្រប់យ៉ាង តែសហករណ៍ស្រូបយកអស់ ផ្គត់ផ្គង់ស្បៀង ព្រមទាំងចាត់ចែងកម្លាំងធ្វើការងារទៀត។ អានុភាពរបស់សហករណ៍គឺខ្លាំងក្លាណាស់"។

[១១:៤០:០៥]

ហើយបន្តទៅកថាខណ្ឌពីរបីខាងក្រោម គឺសូមដកស្រង់ "នៅភូមិភាគពាយ័ព្យ ជាបណ្ដោះអាសន្នដោះស្រាយបាន នៅខ្វះខាតខ្លះ។ ប្រជាជនចាស់មិនអីទេ តែប្រយ័ត្នសមាសភាពមិនល្អក្នុងប្រជាជនថ្មី។ វាឆ្លៀតឱកាស។ ព្រោះពួកអានេះ បើទុកជាយើងឲ្យវាគ្រប់គ្រាន់ពីរកំប៉ុង ក៏វានៅ -- ក៏នៅមិនគ្រប់គ្រាន់ដែរ"។ វិធានការដ៏រឹងមាំដែលដាក់ចេញដោយគណៈអចិន្ត្រៃយ៍ គឺនិយាយអំពីកងទ័ពដែលត្រូវការពារនៅតាមព្រំដែន។ ឯកសារនេះគឺមាននៅត្រង់ ERN ជាភាសាខ្មែរ 00008490, ជាអង់គ្លេស 00850977, ជាភាសាបារាំង 00343378។ ខ្ញុំសូមលើកនូវចំណុចទី២ នៃវិធានការដ៏រឹងមាំ។ សូមដកស្រង់ "ផ្នែកអាវុធត្រូវប្រើរួមផ្សំសម័យខ្លះ បុរាណខ្លះ ពិសេសប្រើចម្រូងតាមព្រំដែន។ ត្រូវមានផែនការមួយខែដាក់ចម្រូងប៉ុន្មាន។ ចម្រូងត្រូវប្រើគ្រប់ប្រភេទ កម្ពស់ត្រឹមបាតជើង ខ្នងជើង -- ស្មងជើង ឡើងទៅដល់ត្រឹមពោះ"។

[១១:៤២:០០]

ហើយនៅផ្នែកចុងក្រោយនៃឯកសារនេះ គឺនៅត្រង់ERN ជាភាសាខ្មែរ 00008492, ERN ជា

ភាសាអង់គ្លេស 00850978, ERN ជាភាសាបារាំង 00343379។ គណៈអចិន្ត្រៃយ៍សម្រេចថា តម្រូវឲ្យមានប្រជាជនបន្ថែមទៀតទៅភូមិភាគពាយ័ព្យ ដោយលើកឡើងថា សូមដកស្រង់ “កម្លាំងមនុស្សមិនគ្រប់គ្រាន់ ត្រូវបន្ថែមកម្លាំងពលកម្ម ៣ឬ៤សែន ថែមទៀតក៏មិនគ្រប់ដែរ។ កម្លាំង១លាននាក់បច្ចុប្បន្នធ្វើមិនបាន៥០ភាគរយទេ ត្រូវថែម៤ ឬ៥សែនទៀត” បញ្ចប់ការដកស្រង់។

[១១:៤៣:០៩]

ត្រឡប់ចូលទៅឧទាហរណ៍នៃសារាចរ ឬសេចក្តីណែនាំដែលចេញដោយគណៈមជ្ឈិម ខ្ញុំសូមបង្ហាញឯកសារ E3/1173 ដែលសារាចរណែនាំលេខ 02/76 ដែលមានចំណងជើងថា “សេចក្តីណែនាំពីគណៈ៨៧០ ដែលចេញនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ៧៦។ កម្មវត្ថុនៃសារាចរណែនាំនេះ សូមដកស្រង់ “ការទម្លាក់គ្រាប់ដោយពួកចក្រពត្តិអាមេរិកនៅសៀមរាប”។ នៅក្នុងសារាចរណែនាំនេះ គឺគណៈអចិន្ត្រៃយ៍។ យើងឃើញថា ការផ្ទុះគ្រាប់នៅសៀមរាប គឺជាលទ្ធផលនៃការទម្លាក់គ្រាប់បែករបស់អាមេរិក។ ហើយបន្ទាប់មកក៏មានការលើកឡើងពាក់ព័ន្ធទៅនឹងគោលបំណងនៃការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ។ ហើយកថាខណ្ឌនៅខាងក្រោមនៃទំព័រទី១ នេះ ខ្ញុំសូមដកស្រង់ដូចតទៅ៖

“ពេលមហាសន្និបាតជាតិលើកទី២របស់យើង ប្រកាសគោលជំហរមហាសាមគ្គីជាតិ ហើយផ្តន្ទាទោសតែពួកអាក្បត់៧នាក់។ ចក្រពត្តិអាមេរិក វាសង្ឃឹមថា ជាឱកាសឲ្យវាអនុវត្តផែនការវាយយើង ក្រោយពេលវាចាញ់ ដោយវារក្សាកម្លាំងរបស់វាបានតទៅទៀតនៅក្នុងក្រុងភ្នំពេញ និងទីរួមខេត្ត។ តែក្រោយពីយើងឈ្នះ យើងដកប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្ត។ ផែនការចក្រពត្តិអាមេរិកដែលត្រៀមវាយយើងក្រោយពេលវាចាញ់ត្រូវខ្ចាត់ខ្ចាយខ្ទេចខ្ទី” បញ្ចប់ការដកស្រង់។

[១១:៤៥:១៨]

នៅទំព័រចុងក្រោយនៃសារាចរណែនាំនេះ គឺគណៈអចិន្ត្រៃយ៍បានដាក់វិធានការដើម្បីឲ្យយកទៅអនុវត្ត។ សូមដកស្រង់ “គណៈអចិន្ត្រៃយ៍ស្នើយកព្រឹត្តិការណ៍នេះអប់រំផ្ទៃក្នុងបក្ស អង្គការស្នូល កងទ័ព និងមហាជន សំដៅបំផុសកំហឹងជាមួយខ្មាំងឲ្យក្តៅគគុក និងស្រួចជាប់ជានិច្ច។ សំដៅកសាងគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ជាប់ជានិច្ច កសាងគោលជំហរសតិអារម្មណ៍ នយោបាយ និងចាត់តាំង។ ធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមឲ្យបានខ្លាំងក្លា។ ការការពារទឹកដីឲ្យបានជាដាច់ខាត។ ការពារលទ្ធផលបដិវត្តន៍ឲ្យបានជាដាច់ខាត។ ហើយរួមជាមួយប្រជាជនសាច់មួយ ឈាមមួយ ជាផ្លុងមួយ សម្រុកធ្វើប្រព័ន្ធភ្លឺស្រែ ដើម្បីសម្រេចឲ្យបានបីតោនក្នុងមួយហិកតា និងកែប្រែជីវភាពប្រជាជនឲ្យ

បានតាមសំណូមពររបស់បក្ស។ វិធីដំណើរការ អប់រំផ្ទៃក្នុងបក្ស អង្គការស្ទូល និងកងទ័ព។ ធ្វើមីទ្ទិង បំផុសកំហឹងប្រជាជន" បញ្ចប់ការដកស្រង់។

លោកប្រធាន លោក លោកស្រីចៅក្រម គោលបំណងនៃការបង្ហាញឯកសារនេះគឺ អ្នកបកប្រែជាភាសាអង់គ្លេសនោះ គឺអត្ថបទនេះគឺត្រូវបានថតចម្លងចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយថតតែពីរបីទំព័រ មានបាត់ទំព័រទី២ យើងខ្ញុំកំពុងធ្វើការស្នើសុំថតចម្លង ដើម្បីបំពេញបន្ថែមឯកសារនេះ។ បើសិនណាអង្គជំនុំជម្រះមិនមានគំនិតផ្តួចផ្តើមណានោះទេ ដូច្នេះខាងការិយាល័យសហព្រះរាជអាជ្ញានឹងស្នើសុំថតចម្លងដើម្បីបំពេញឯកសារដែលបានបាត់នៅក្នុងសំណុំរឿងនេះ។

[១១:៤៧:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៨:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះនឹងចាត់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងធ្វើកិច្ចការនេះ ដើម្បីបញ្ជាក់ថាតើបញ្ហានេះវាកើតឡើងដោយសារតែបច្ចេកទេស ឬក៏ដោយសារមានកំហុសខ្វះខាតក្នុងការដែលនាំមានការបាត់នូវទំព័រឯកសារដូច្នេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមចូលបន្តទៅឯកសារថ្មីគឺឯកសារ E3/740 ដែលជាឯកសារចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៧ ជាសេចក្តីណែនាំចេញពីគណៈមជ្ឈិមពាក់ព័ន្ធទៅនឹងការប្រើពាក្យ "អង្គការ" និង "បក្ស"។ ផ្នែកសំខាន់នៃសេចក្តីណែនាំនេះ យើងខ្ញុំសូមអានដូចខាងក្រោម សូមដកស្រង់ "ម៉្យាងទៀតបក្សយើងបានសង្កេតឃើញថា ការប្រើពាក្យ "អង្គការ" សម្រាប់ហៅបុគ្គល មិនចំណេញសោះដល់ការកសាងគោលជំហរនយោបាយ ជំហរសតិអារម្មណ៍ និងជំហរចាត់តាំងរបស់បក្ស។ វាផ្ទុយស្រឡះពីជំហរបដិវត្តន៍សង្គមនិយមរបស់យើង ពីជំហរកម្ចាត់កម្មសិទ្ធសួនតួរបស់បក្សយើង។ អាស្រ័យហេតុនេះគណៈមជ្ឈិមបក្សស្នើសុំណែនាំចំពោះគ្រប់មូលដ្ឋាន ចំពោះគ្រប់ក្រសួងមន្ទីរ និងអង្គភាពដូចតទៅ ពាក្យ "អង្គការ" ឬពាក្យ "បក្ស" ប្រើតែចំពោះអង្គការចាត់តាំង មិនត្រូវ ប្រើសម្រាប់បុគ្គលឡើយ។ ២) ចំពោះបុគ្គល ត្រូវប្រើពាក្យថា សមមិត្តឈ្មោះនេះ ឬសមមិត្តតំណែងនេះនោះ ឬសមមិត្តតំណាងអង្គការថ្នាក់នេះ ថ្នាក់នោះ។ ឧទាហរណ៍ សមមិត្ត ទាញ សមមិត្តលេខា សមមិត្ត

តំណាងអង្គការភូមិភាគ។ល។ សូមអង្គការបក្សគ្រប់ថ្នាក់ណែនាំអប់រំអំពីបញ្ហានេះ ដើម្បីឲ្យសមមិត្ត និងសមមិត្តយើងជ្រួតជ្រាប និងអនុវត្តបានល្អ"។

[១១:៥០:៥២]

ឯកសារដែលខ្ញុំត្រូវបង្ហាញបន្ទាប់ គឺឯកសារ E3/741 ដែលជាឯកសារមានចំណងជើងថា ជាឯកសារដែលចេញដោយគណៈ៨៧០ នៅខែមីនា -- នៅថ្ងៃទី០៣ ខែតុលា ៧៨ ដែលមានកម្មវត្ថុ សូមដកស្រង់ "នៅថ្ងៃទី០៣ ខែមករា -- (សូមកែប្រែ) ៧៨ ដើម្បីវាយខ្ទាំងស្ពានភាព -- ដែលលេប ទឹកដីទាំងស្រុង ទាំងយុទ្ធវិធីរបស់វា"។ សេចក្ដីណែនាំនេះ គឺមានសេចក្ដីណែនាំទាក់ទងទៅនឹងជម្លោះ ជាមួយនឹងកងទ័ពវៀតណាម វិធានការដែលជាកម្មវត្ថុនេះ គឺត្រូវសង្ខេបនៅត្រង់ផ្នែកទី៣ ដែលអាចរក ឃើញនៅត្រង់ ERN ជាភាសាខ្មែរ 00284278, ERN ជាភាសាអង់គ្លេស 00296003 ដល់ 04, ERN ជាភាសាបារាំង 00611865។ ហើយនៅត្រង់ផ្នែកនេះ គឺមានសរសេរដូចតទៅ សូមដកស្រង់ "វិធានការវាយខ្ទាំងឲ្យស័ក្ដិសិទ្ធិ ដណ្ដើមជ័យជម្នះនៅចំពោះមុខ និងយូរអង្វែង។ ដើម្បីវាយខ្ទាំងយួន ឈ្លានពានលេបទឹកដីទាំងយុទ្ធសាស្ត្រ យុទ្ធវិធីរបស់វា ឲ្យស័ក្ដិសិទ្ធិ និងទទួលបានជ័យជម្នះជាបន្តបន្ទាប់ យើងត្រូវមាន នឹងត្រូវក្ដាប់ឲ្យជាប់វិធានការរបស់បក្សដូចតទៅ៖ វាយខ្ទាំងខាងយោធា វាយខ្ទាំងខាង នយោបាយ និងកម្លាត់ចារកម្ម បង្ក្រាបចិត្តសាស្ត្រ វាយខ្ទាំងខាងផ្ដាច់ស្បៀង និងសេដ្ឋកិច្ចរបស់វា បង្អត់បាយវាជាប់ជានិច្ច វាយខ្ទាំងដោយផ្ដាច់ផ្លូវដឹកជញ្ជូនស្បៀងអាហារ គ្រាប់រំសេវ និង ទ័ពទឹងរបស់ វាជាប់ជានិច្ច"។

[១១:៥៣:១៦]

ហើយសេចក្ដីណែនាំនេះ ក៏មានការអនុវត្តចេញ ថាតើត្រូវវាយកម្ទាត់ខ្ទាំងយួន ដោយរបៀប ណាផ្នែកនោះ គឺបានសរសេរដូចទៅ ដែលអាចរកនៅត្រង់ ERN ជាភាសាខ្មែរ 00284281, ERN ជាភាសាអង់គ្លេស 00296006, ERN ជាភាសាបារាំង 00611867។ សេចក្ដីណែនាំនេះ គឺមាន ខ្លឹមសារដូចតទៅ៖ "ស្នើថ្នាក់ភាគ តំបន់ ស្រុក គណៈបញ្ជាការគ្រប់ថ្នាក់ និងកម្មាភិបាលយោធា នៅមូលដ្ឋានយកចិត្តទុកដាក់រៀនសូត្រ ចុះឡើង អំពីមាគ៌ាវាយដូចចែងខាងលើ ឲ្យស័ក្ដិសិទ្ធិបំផុត។ បំផុតកម្មាភិបាល និងយុទ្ធជនយើង ប្រឡងប្រណាំងវាយកម្ទេចក្បាលខ្ទាំងយួនឈ្លានពានទឹកដីឲ្យអស់ រលីង ការពារបក្សបដិវត្តកម្ពុជាប្រជាធិបតេយ្យ ការពារប្រជាជនយើងសហករណ៍យើង ស្រូវអង្ករ ស្រែចម្ការ និងភោគផលរបស់យើង"។

[១១:៥៤:៣២]

នៅផ្នែកបន្ទាប់នៃឯកសារ នៃសរាចរណែនាំនេះ គឺនិយាយអំពីការវាយខ្មាំងខាងនយោបាយ។ ដែលមាននៅត្រង់ ERN ជាភាសាខ្មែរ 00284282, អង់គ្លេស ERN 00296007, បារាំង 00611868។ សូមដកស្រង់ "សរុបមកត្រូវដាច់ខាត ទាំងនយោបាយ សតិអារម្មណ៍ និងចាត់តាំង កម្ចាត់សកម្មភាពចារកម្ម សន្តិសម្ព័ន្ធ និងបង្ក្រាបចិត្តសាស្ត្ររបស់ខ្មាំង។ ថ្នាក់បក្ស ភាគតំបន់ និងគណៈបញ្ជាការសមរភូមិ គណបក្ស មន្ទីរ ក្រសួង ត្រូវលើកវិធានការឲ្យច្បាស់លាស់ ហើយសហការឲ្យជាប់ជានិច្ច" ហើយបន្តនូវកថាខណ្ឌខាងក្រោម គឺថា "ត្រូវធ្វើការងារនយោបាយ សតិអារម្មណ៍ និងចាត់តាំងក្នុងប្រជាជនយើងឲ្យជាប់ ដោះស្រាយជីវភាពប្រជាជន ជម្រក និងកក់ក្ដៅ ជានិច្ច។ ត្រូវមានកម្មាភិបាលមូលដ្ឋានរឹងមាំ និងជាប់ជានិច្ច បំផុសកំហឹងប្រជាជន ចំពោះខ្មាំងឈ្លានពានដើម្បីប្រែក្លាយកំហឹងនេះ ទៅជាកំហឹងសម្ភារៈ ស្ដែងចេញជាអំពើសកម្មភាពជាក់ស្ដែងគ្រប់បែបយ៉ាង ដើម្បីពង្រឹងសេដ្ឋកិច្ច ជីវភាព រួមទាំងកម្លាំងការពារនៅសមរភូមិមុខ" បញ្ចប់ការដកស្រង់។

[១១:៥៦:១៤]

ហើយក៏ដូចជាសេចក្ដីណែនាំដទៃទៀតដែរ ឯកសារនេះគឺបានធ្វើការសរុបសេចក្ដី ទាក់ទងទៅនឹងការអនុវត្ត សេចក្ដីណែនាំនៅទូទាំងប្រទេសតែម្ដង។ ហើយខ្ញុំសូមអាននូវផ្នែកចុងបញ្ចប់នៃឯកសារនេះតទៅ សូមដកស្រង់ "សេចក្ដីបញ្ជាក់៖ សេចក្ដីណែនាំនេះត្រូវចែកចាយ និងសិក្សាគណបក្ស ភាគតំបន់ សហករណ៍ និងគណៈសមរភូមិ គណៈកងពល វរសេនាធំ វរសេនាតូច អនុសេនាធំ អនុសេនាតូច ក្រុម និងយុទ្ធជន។ គណៈបញ្ជាការមុខព្រួញនីមួយៗឲ្យជ្រួតជ្រាបសាចុះសាឡើង ដកពិសោធជាប់ជានិច្ច និងកែលម្អការអនុវត្តតាមពិសោធខុសត្រូវជាប់ជានិច្ច។ អនុវត្តមាគ៌ាយោធា មាគ៌ាសង្គ្រាមប្រជាជន សង្គ្រាមឈ្លបរបស់បក្សឲ្យបានល្អ គឺឃ្មួនឈ្លានពានជាឆ្អឹងវាទាំងគំនរ មកចោលនៅលើទឹកដីយើងហើយ"។

[១១:៥៧:៣១]

ហើយសេចក្ដីណែនាំរបស់បក្សនៅត្រង់ផ្នែកចុងក្រោយ គឺឯកសារ E3/763 ៗ ដែលជាឯកសារបានចេញដោយគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា សូមដកស្រង់ "សេចក្ដីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ទៅលើគោលនយោបាយបក្ស ទៅចំពោះអ្នកដែលយល់ខុស ចូលរួមជាមួយនឹង ពួក សេ.អ៊ី.អា, កា.ហ្សេ.បេ និងប្រឆាំង

ជាមួយបក្សកុម្មុយនីស្តកម្ពុជា"។ នៅក្នុងឯកសារនេះគឺ បក្សបានកែតម្រូវគោលនយោបាយ ពាក់ព័ន្ធទៅនឹងគោល-- ពាក់ព័ន្ធទៅនឹង សេ.អ៊ី.អា, កា.ហ្សេ.បេ ដោយបានចាត់ទុកថា មានក្រុមមនុស្សមួយចំនួនគឺមាន មនុស្សចំនួនបីក្រុម គឺយើងអាចឃើញនៅក្នុងឯកសារនេះ។ គឺក្រុមទី១ អ្នកណារឹងរូស បន្តធ្វើសកម្មភាពប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា អំណាចបក្សចាប់តាំងពីឆ្នាំ១៩៧៥ ក៏ប៉ុន្តែនៅក្រុមទី៤ គឺក្រុមដែលចាប់ផ្តើមបានចូលរួមជាមួយខ្មាំងតាមពីឆ្នាំ១៩៧៥ ដល់ ៧៨ ដែលមានការដកស្រង់ដូចតទៅនៅត្រង់ ERN ជាភាសាខ្មែរ 00079280, ERN ជាភាសាអង់គ្លេស 00275218, ERN ជាភាសាបារាំង 00623529។ ដែលមានការលើកឡើងដូចតទៅ សូមដកស្រង់ "អ្នកណារឹងរូសបន្តធ្វើសកម្មភាពប្រឆាំង បក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងរដ្ឋអំណាចបដិវត្ត កម្មករ កសិករ ប្រឆាំងរបបសម្ពហភាពសង្គមនិយម ប្រឆាំងប្រជាជនកម្ពុជា និងប្រឆាំងកម្ពុជាប្រជាធិបតេយ្យតទៅទៀត។ អ្នកនោះ ត្រូវមានទោសពីព្រោះអ្នកនោះ ធ្វើសកម្មភាពក្បត់ដោយចេតនា ដោយគោលជំហរប្រឆាំងដាច់ខាត ដោយគោលជំហរពេញចិត្ត ពេញថ្លើម បម្រើខ្មាំងសត្រូវ ជា សេ.អ៊ី.អា, ជាយួន, ជា កា.ហ្សេ.បេ។ អ្នកនោះគេបែងចែកព្រំដែនរបស់គេច្បាស់ហើយ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជាត្រូវតែកម្ចាត់ចោល"។

[១២:០០:១៤]

ហើយទាក់ទងទៅនឹងអ្នកទាំងអស់នេះ ដែលនៅតែបន្តប្រឆាំងទៅនឹងសកម្មភាពរបស់បក្ស បក្សបានចែកអ្នកទាំងនោះទៅជាបួនប្រភេទ ដូចខាងក្រោម សូមដកស្រង់ "សូម្បីតែអ្នកដែលធ្វើសកម្មភាពនៅក្នុងប្រភេទទាំងបួននេះ ក៏បានលើកដែរ"។ គណៈមជ្ឈិមបានលើកឡើងថា សូមដកស្រង់ "បក្សបែងចែក និងធ្វើការតាមដានសកម្មភាពរបស់ពួកគេជាប់ជានិច្ច"។ ជាការកត់សម្គាល់គឺ ប្រភេទទី៤ គឺមានដូចតទៅ សូមដកស្រង់ "ពួកដែលគ្រាន់តែអូសទាញឃោសនា ហើយដែលគេគ្រាន់តែកត់ឈ្មោះថា ចូល សេ.អ៊ី.អា ចូលនេះចូលនោះជាមួយគេ។ អ្នកប្រឆាំងប្រភេទទី១ គឺជាអ្នកប្រភេទប្រឆាំងធ្ងន់ធ្ងរ ដែលបក្សកំណត់ថា អ្នកដែលធ្វើសកម្មភាពប្រឆាំងដាច់ខាត ជាខ្សែចង្វាក់ដោយអំពើប្រព្រឹត្តជាក់ស្តែង និងជាបន្តបន្ទាប់" បញ្ចប់ការដកស្រង់។

[១២:០១:៤០]

ហើយម្យ៉ាងទៀត ឯកសារនេះគឺបានលើកឡើងនូវសេចក្តីណែនាំ ទាក់ទងទៅនឹងការទំនាក់ទំនង និងការអនុវត្តនូវគោលនយោបាយនេះ។ ឯកសារនៅចុងបញ្ចប់គឺ សូមដកស្រង់ "ស្នើគ្រប់ភាគ គ្រប់តំបន់ គ្រប់អង្គភាពយកសេចក្តីនាំខាងលើនេះទៅអប់រំ និងធ្វើមីទ្ទិងនៅក្នុងបក្ស អង្គការស្នូល ក្រសួងមន្ទីរ

អង្គភាពកងទ័ពក្នុងសហករណ៍ ក្នុងរោងចក្រ និងក្នុងការដ្ឋាន ដើម្បីឲ្យមហាជនទាំងអស់ក្ដាប់បាននូវគោលនយោបាយរបស់បក្ស។ ស្នើផ្សព្វផ្សាយ និងតាមដានការផ្សព្វផ្សាយសេចក្ដីណែនាំនេះឲ្យបានម៉ត់ចត់ធ្វើហើយធ្វើទៀត ជាបន្តបន្ទាប់ក្នុងវគ្គរៀនសូត្រខ្លី ក្នុងការប្រជុំជីវភាព ក្នុងសន្និបាត ក្នុងមីទ្ទិង ឬនៅរាល់ថ្ងៃសម្រាកការងារ។ ពីនេះតទៅដល់ដំណាច់ឆ្នាំ៧៨ ស្នើសហករណ៍នីមួយៗ រោងចក្រ នីមួយៗ ការដ្ឋាននីមួយៗ អង្គភាពនីមួយៗ កន្លែងនីមួយៗ រៀបចំរៀនសូត្រ ឬធ្វើមីទ្ទិងឲ្យបានពីប្រាំទៅ ប្រាំមួយដង" បញ្ចប់ការដកស្រង់។

លោកប្រធាន ខ្ញុំត្រូវចូលទៅឯកសារមួយថ្មីទៀត ខ្ញុំមានឯកសារមួយចំនួនតូចទៀត ដែលត្រូវចំណាយពេលប្រហែលជា១៥ ទៅកន្លះម៉ោង នៅថ្ងៃរសៀលនេះ។ សូមជម្រាបលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីនៅរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា!

[១២:០៣:៣៧]

**លោក ហ្សាស្តេ ប៉ោ៖**

លោក នួន ជា ស្នើសុំតាមដានដំណើរការនីតិវិធី នៅបន្ទប់បំពាក់ប្រព័ន្ធសោតទស្សន៍ នៅខាងក្រោម ដោយសារតែគាត់ឈឺខ្នង និងបាត់បង់ការផ្ចង់អារម្មណ៍ ក៏ពាក់ព័ន្ធទៅដល់បញ្ហាសុខភាពមួយទៀតដែរ។ យើងខ្ញុំនឹងដាក់ជូននូវពាក្យស្នើសុំលះបង់សិទ្ធិនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយយូរក្នុងការតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះបាន។ សំណើសុំរបស់លោក នួន ជា ធ្វើឡើងមានមូលហេតុសមស្រប អង្គជំនុំជម្រះសម្រេចយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈ

ឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ហើយលោក នួន ជា បានលះបង់សិទ្ធមានវត្តមានដោយផ្ទាល់ នៅក្នុងកិច្ចដំណើរការសវនាការនៅបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី លោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិមានវត្តមាន ដោយផ្ទាល់នៅក្នុងបន្ទប់សវនាការរបស់ លោក នួន ជា។

[១២:០៤:៥៤]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃដំណើរការសវនាការនៅរសៀលថ្ងៃនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម។ ដោយនៅរសៀលនេះឲ្យ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសនាវការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីរសៀល។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការបង្ហាញឯកសារភស្តុតាង។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់។

ពីព្រឹកមិញនេះ ខ្ញុំបានបញ្ចប់ទៅដោយការបង្ហាញនូវឯកសារ ដែលចេញដោយគណៈមជ្ឈិម ចុះខែមិថុនា ឆ្នាំ៧៨ ដែលជាការដាក់ចេញនូវគោលនយោបាយ ទាក់ទងទៅនឹង កា.ហ្សេ.បេ, សេ.អ៊ី.អា និងភ្នាក់ងារខ្មាំង។ គោលនយោបាយដែលបានកែប្រែនេះ ក៏ត្រូវបានចេញផ្សាយនៅខែឧសភា-មិថុនា ៧៨ គឺឯកសារ E3/727។ ទំព័រជាក់លាក់មួយនេះ គឺជាគោលនយោបាយ មាគ៌ានយោបាយបក្សដែលបានធ្វើការកែប្រែ ដែលអាចយើងរកបាននៅត្រង់ ERN ជាភាសាខ្មែរ 00064561 ដល់ 64562, ERN ជាអង់គ្លេស 00185328 ដល់ 329, ERN ជាភាសាបារាំង 00524455 ដល់ 456។

[១៣:៣៤:០០]

ខ្ញុំមិននឹងលើកមកនិយាយនូវមាគ៌ាបក្ស ដែលបានកែប្រែនេះដដែលៗម្តងទៀតទេ ប៉ុន្តែទង់បដិវត្តនេះគឺកំណត់សម្រាប់តែចំពោះសមាជិកបក្ស ដែលមានព័ត៌មានបន្ថែមដែលជាការពន្យល់ថា ហេតុអ្វីបានជាគោលនយោបាយ បានជាមាគ៌ារបស់បក្សដែលបានកែប្រែថ្មីនេះ ត្រូវបានដាក់ចេញនោះ។

ខ្ញុំសូមអាននូវការពន្យល់ សូមដកស្រង់ "បក្សរបស់យើងគឺ បានដាក់ចេញមាគ៌ាថ្មី ដើម្បីវាយកម្ទេចខ្មាំង ៗយើងត្រូវតែប្រមូលផ្តុំកម្លាំង។ ដូច្នេះមហាជនអាចនឹងមានការយល់អំពីខ្មាំង"។ ហើយបន្តទៅពីរបីកថាខណ្ឌខាងក្រោមទៀត សូមដកស្រង់ "ការដែលយើងដាក់ចេញនូវគោលនយោបាយនេះគឺដើម្បីធ្វើឲ្យបញ្ហាមានការស្ងប់ស្ងាត់ ដើម្បីទប់ស្កាត់ខ្មាំងកុំឲ្យ -- ដើម្បីកុំឲ្យអ្នកដទៃទៀតមានការធ្លាក់ចូលក្នុងអន្ទាក់របស់ខ្មាំង"។ បញ្ចប់ការដកស្រង់។

[១៣:៣៥:២៣]

ហើយនៅពេលនោះដែរគឺថា បក្សបានបញ្ជាក់បានយ៉ាង -- បញ្ជាក់យ៉ាងច្បាស់នៅក្នុងទស្សនាវដ្តីទង់បដិវត្តនេះ។ សូមដកស្រង់ "ខ្មាំងដែលធ្វើសកម្មភាពចំបក្សកុម្មុយនីស្តកម្ពុជា គឺថាត្រូវតែកម្ទេចត្រូវតែកម្ចាត់ចោល"។ បិទការដកស្រង់។ ដូចដែលឃើញនៅក្នុងផ្នែកពាក់ព័ន្ធនៅក្នុងទង់បដិវត្តនេះដែរ ខ្ញុំសូមអានដូចតទៅ "បក្សគឺថា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការកម្ចាត់ខ្មាំង"។ ហើយត្រង់នេះគឺថា អាចរកឃើញនៅត្រង់ ERN ជាភាសាខ្មែរ 0006556 (ស៊ីក) ដល់ 64557, ERN ជាភាសាអង់គ្លេស 00185324, ERN ជាភាសាបារាំង 00524451។

ឯកសារនេះគឺថា បានដាក់ចេញដូចខាងក្រោមនេះ សូមដកស្រង់ "អ្វីដែលបាន -- យើងបានឃើញយ៉ាងច្បាស់នៅក្នុងឆមាសទី១ ឆ្នាំ១៩៧៨ គឺខ្មាំងដែលខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។ នៅពេលនេះគឺថា ខ្មាំងបានប្រើប្រាស់កម្លាំង ខាងក្នុង គឺមូលដ្ឋាន គឺខ្មាំងនៅក្នុងជនបទ នៅក្នុងក្រសួង មន្ទីរ ក្នុងកងទ័ព។

ឯខ្មាំងខាងក្រៅគឺគ្រាន់តែផ្តួបផ្សំ"។ ហើយកថាខណ្ឌមួយខាងក្រោម សូមដកស្រង់ "វិធានការដែលយើងបានលើកឡើងនេះ មិនមានអ្វីខុសប្លែកពីវិធានការពីមុនៗទេ តែយើងត្រូវសម្រួចគោលជំហរ វាយកម្ចាត់ខ្មាំងខាងក្នុង ឲ្យកាន់តែស្រួចស្រាល់ថែមទៀត។ មានវិធានការដាច់ខាតជាបន្តបន្ទាប់ ជាមួយខ្មាំងសត្រូវខាងក្នុង និងខ្មាំងខាងក្រៅ ដូចតទៅ យើងត្រូវតែចាត់វិធានការបែបនេះ ពីព្រោះខាងខ្មាំងជាកម្មាភិបាលកុម្មុយនីស្តកម្ពុជា ជាកម្មាភិបាលរបស់ប្រជាជនកម្ពុជា តែធាតុពិតរបស់វា ជាកម្មាភិបាលរបស់បក្សពលករកម្ពុជារបស់យួន ជាកម្មាភិបាលរបស់ សេ.អ៊ី.អា ដើម្បីរំលំរបបសម្ងួហភាព។ វារំលំបក្សកុម្មុយនីស្តកម្ពុជា ដើម្បី -- របស់យួន ហើយកម្មាភិបាលរបស់ សេ.អ៊ី.អា គឺដើម្បីវាយរំលំរបបសម្ងួហភាព វាយរំលំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីពួកពលករក្បត់របស់យួន សម្រាប់ សេ.អ៊ី.អា វិលមកវិញយករបបឯកជន នាយទុនមកវិញ។

[១៣:៣៨:៣៤]

ហើយនៅផ្នែកមួយទៀត នៃទង់បដិវត្តនោះគឺនិយាយអំពីការទំនាស់គ្នារវាងបដិវត្តន៍ និងពួកប្រឆាំងនឹងបដិវត្តន៍ ដែលអាចរកឃើញនៅត្រង់ ERN 00065466 ដល់ 65467, ERN អង់គ្លេស 00185382 ដល់ 384, ERN ជាភាសាបារាំង 0024459 ដល់ 460។ គឺឯកសារនេះ បានលើកឡើងដូចតទៅ សូមដកស្រង់ "ក្រោយរំដោះភ្លាម វាចាប់ផ្តើមវាយយើងភ្លាម តើនរណាវាយយើង? គឺ សេ.អ៊ី.អា, យួន និង កា.ហ្សេ.បេ។ យើងមិនដែលឃើញសមាសភាព ជានាយទុនធម្មតា អនុធនធម្មតាទេ។ ដូច្នេះ បានជាយើងចង់សង្កត់ថា បើយើងនិយាយរួមថា មូលធននិយម ខ្លាចក្រែងទស្សនៈវិភាគរបស់យើងមិនច្បាស់។ ហើយវិធានការរបស់យើងគឺ យើងត្រូវតែកម្ចាត់ ហើយពួកដែលក្បាល ដែលត្រូវវាយកម្ចាត់នោះ គឺ សេ.អ៊ី.អា, យួន និងកា.ហ្សេ.បេ។ តាំងពីឆ្នាំ១៩៧៥ មកកម្លាំងដែលវាយយើងសុទ្ធតែ សេ.អ៊ី.អា និង យួន។ អាចក្រី, អាឈូក, អាធុច, អាឌឿន, អាភឹម, អាស៊ី អាកែវ មាស, អាជ័យ ទាំងអស់សុទ្ធតែជា សេ.អ៊ី.អា គ្រាន់តែ សេ.អ៊ី.អា អាមួយវាធ្ងន់ខាងអាមេរិក អាមួយទៀតវាធ្ងន់ខាងយួនជាង។ ឯកសារជាបន្តបន្ទាប់បញ្ជាក់ថា មុនដំបូង វារួមជាមួយ អានល់ វាយកុម្មុយនីស្ត"។ បញ្ចប់ការដកស្រង់។

[១៣:៤១:០០]

ហើយនៅផ្នែកមួយ ដែលមានចំណងជើងថា "បក្សបានធ្វើការកែប្រែផ្តោតការយកចិត្ត -- ទៅលើកាតព្វកិច្ចឆ្នាំ១៩៧៨"។ ផ្នែក១ នៃឯកសារនេះ ដែលនិយាយថា "សភាពការណ៍ទូទៅ និងការផ្តោត

ការយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឆ្នាំ១៩៧៨ ដែលមាននៅត្រង់ ERN ជាភាសាខ្មែរ 0064576 (ស៊ីក) ដល់--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន អ្នកបកប្រែតាមអត់ទាន់ ញាប់ពេក។

**លោក ឌេល លីសាក់៖**

បាទ ខ្ញុំសូមនិយាយ ERN ជាភាសាខ្មែរឡើងវិញ 0064576 (ស៊ីក) ដល់ 64577។ នៅត្រង់ផ្នែកនេះនៃឯកសារនេះគឺ យើងអាចឃើញនូវសេចក្តីថ្លែងការណ៍ ដូចតទៅ សូមដកស្រង់ "ទាំងខ្មាំងខាងក្នុងខាងក្រៅត្រូវបានវាយកម្ចាត់ភ្លាមៗនៅក្នុងកាលៈទេសៈនេះ ក៏ដូចជាកាលៈទេសៈដទៃទៀត។ ដោយ-សារម៉្យាងគឺយើងបានវាយកម្ទេច និងកម្ចាត់ខ្មាំងយួនឈ្លានពានមកពីក្រៅ និងធ្វើឲ្យពួកវាបរាជ័យយ៉ាងធ្ងន់ធ្ងរជាបន្តបន្ទាប់។ ម៉្យាងទៀត យើងកម្ទេចបាននូវក្បាលម៉ាស៊ីនដឹកនាំក្បត់ទូទាំងប្រទេស ព្រមទាំងបក្សពួកវាជាក់ស្តែង គឺកម្ទេចកម្លាំងក្បត់នៅភូមិភាគបូព៌ា, ពាយព្យ, បស្ចិម, ភ្នំពេញ, តំបន់១០៣, ក្រចេះ និងតំបន់២៥"។ បញ្ចប់ការដកស្រង់។

[១៣:៤៣:១៥]

ហើយសេចក្តីណែនាំរបស់បក្សទាក់ទងទៅនឹងខ្មាំងនេះដែរ គឺអាចរកបាននៅត្រង់ខ្មែរ ERN 00064578 ដល់ 64579, ERN អង់គ្លេស 00185342 ដល់ 343 ហើយ ERN ជាភាសាបារាំង 00524469 ដល់ 470។ ហើយនៅត្រង់ផ្នែកនេះ គឺមានសេចក្តីណែនាំ ដូចតទៅ សូមដកស្រង់ "ដូច្នេះភារកិច្ចរបស់យើងគឺវាយកម្ទេចពួកភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារយួន និងភ្នាក់ងារ កា.ហ្សេ.បេ នេះជាដាច់ខាត ខ្លាំងក្លាជាបន្តបន្ទាប់ វាយហើយវាយទៀត វាយវារលំរលាយ ហើយរលំរលាយជាបន្តបន្ទាប់។ លុះត្រាតែវាយវាយ៉ាងនេះ បានកម្លាំងចាស់របស់វាត្រូវខ្ទេចខ្ទី ហើយកម្លាំងនៅសេសសល់របស់វា ត្រូវខ្ទេចខ្ទីទៀត កម្លាំងថ្មីរបស់វាក៏ខ្ទេចខ្ទីទៀតជាបន្តបន្ទាប់។ យើងស្ថិតនៅក្នុងសភាពវាយសម្រុកម្ចាស់ការហើយឈានទៅមុខជាន់ខ្មាំង ដណ្តើមយកជ័យជម្នះជាបន្តបន្ទាប់។ ឯខ្មាំងវិញត្រូវខ្ទេចខ្ទី ខ្ចាត់ខ្ចាយ និងរលំរលាយ។ កាលបើយើងវាយកម្ទេចខ្មាំងសត្រូវឲ្យវាខ្ទេចខ្ទី និងរលំរលាយជាបន្តបន្ទាប់យ៉ាងនេះ នាំឲ្យសភាពការណ៍បដិវត្តន៍យើងគ្រប់ផ្នែកកាន់តែល្អប្រសើរ ហើយវាឈានទៅមុខទៀត កាន់តែសន្ធោ-សន្ធៅ នៅក្នុងក្របខ័ណ្ឌបដិវត្តន៍ក្នុងប្រទេសយើង"។ ហើយផ្នែកនៅខាងក្រោមបន្តមកទៀតនេះ ខ្ញុំសូមអាននូវសេចក្តីណែនាំត្រង់ចំណុច "ឃ" "ត្រូវឃើញភារកិច្ចវាយខ្មាំងខាងក្នុងជាភារកិច្ចគន្លឹះ ទាក់ទងទៅ

នឹងគ្រប់ភារកិច្ចផ្សេងៗទៀតទាំងអស់។ ដូច្នេះគ្រប់ថ្នាក់បក្សត្រូវប្រកាន់មាគ៌ាដឹកនាំកងទ័ពប្រជាជនវាយខ្មាំងទាំងនេះ វាយសម្អាតខ្មាំងទាំងនេះ បោសហើយបោសទៀតៗ គ្មានឈប់ឈរ ដើម្បីឲ្យកម្លាំងបក្សរបស់យើងស្អាត កម្លាំងដឹកនាំរបស់យើងគ្រប់ថ្នាក់ គ្រប់ផ្នែក និងគ្រប់ពេលវេលាស្អាត"។ បញ្ចប់ការដកស្រង់។

[១៣:៤៦:០៧]

លោកប្រធាន លោក លោកស្រីចៅក្រម ចំណុចចុងក្រោយដែលបក្សបានព្យាយាមដាក់ចុះនៅក្រោមនោះ គឺសារទូរលេខដែលផ្ញើចេញពីមន្ទីរ៨៧០។ ឯកសារ E3/1186 ៗ ជារបាយការណ៍ដែលផ្ញើមកពីតំបន់២២ មកពីភូមិភាគបូព៌ានៅ -- ភូមិភាគបូព៌ាដែលរៀបរាប់អំពីសភាពការណ៍ខ្មាំងនៅក្នុងស្រុកមុខកំពូល គឺបានស្នើសុំឲ្យជម្រាបជូនទៅភូមិភាគពាយព្យ។ គឺនៅក្នុងឯកសារនេះឯង ឯកសារ E3/1186 មានចំណារផ្ទាល់ដៃតែម្តង ដែលបញ្ជាក់ថា "គោរពជូនមន្ទីរ៨៧០"។ គឺទំព័រទី១ នៅត្រង់ ERN ជាភាសាខ្មែរ 00019203 ដែលជាចំណារសរសេរដោយដៃនៅផ្នែកខាងលើខាងឆ្វេងថា "គោរពជូន ម-៨៧០"។ ហើយឯកសារមួយច្បាប់មួយទៀតនោះ គឺរកឃើញនៅត្រង់ ERN ជាភាសាខ្មែរ 00019204 ក៏មានចំណារសរសេរដោយដៃដែរ ថា "ផ្ញើជូនទៅភូមិភាគបស្ចិម" គឺជាចំណារសរសេរដោយដៃ ដោយមានចម្លងជូន "បងវន មួយច្បាប់" "បងស៊ី មួយច្បាប់" "បងពក មួយច្បាប់" បងស៊ី ដែលជាលេខាភូមិភាគបស្ចិម និងបងពក មួយច្បាប់។

[១៣:៤៨:១៦]

ឯកសារ E3/11 -- (សូមកែប្រែ) ឯកសារ E3/177 គឺផ្ញើចេញពីមន្ទីរ៨៧០ ទៅដល់តំបន់២២ គឺផ្ញើជូននៅថ្ងៃ -- ផ្ញើចេញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ៧៨។ នេះគឺ -- ចម្លងជូនទៅភូមិភាគកណ្តាល ក៏ដូចទៅភូមិភាគបស្ចិម។ ខ្ញុំសូមដកស្រង់ដូចតទៅ "យើងសូមបញ្ជាក់ថា ភូមិភាគបូព៌ាបានជូនរបាយការណ៍មួយច្បាប់ ស្តីអំពីសភាពការណ៍ខ្មាំងក្នុងស្រុកមុខកំពូល មកមន្ទីររបស់យើង ដោយស្នើសុំឲ្យមន្ទីររបស់យើងជូនទៅសមមិត្តទាំងអស់។ សមមិត្តសូមតាមដានមើលសភាពការណ៍ និងចាត់វិធានការទាំងអស់ដោយទាក់ទងជាមួយនឹងស្រុកមុខកំពូល គឺចុះថ្ងៃទី២០ ខែមីនា ១៩៧៨ ពីមន្ទីរ៨៧០"។

[១៣:៤៩:២៨]

លោក លោកស្រីចៅក្រម សារទូរលេខនេះ ផ្ញើចេញពី៨៧០ នេះ ជាសារទូរលេខ៣២ ដែលផ្ញើចេញមកពីមន្ទីររបស់គណៈមជ្ឈិម។

លោក លោកស្រីចៅក្រម ជាទីគោរព! សំខាន់បំផុតនោះ គឺទង់បដិវត្តដែលបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនោះ គឺខ្ញុំចង់ឲ្យអង្គជំនុំជម្រះមេត្តាយកចិត្តទុកដាក់ទៅលើអត្ថបទជា អត្ថបទ*កូល័រ* នេះ ចំនួនពីរច្បាប់។ ខ្ញុំគិតថា ទោះបីជាឯកសារនេះពី -- មកពីលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ឬក៏មកពី ស្ទីវ ហេដឌ័រ ក៏ដោយ គឺឯកសារនេះឯកសារ E169/4/1.1។ ខ្ញុំអានម្តងទៀត E169/4/1.1.1 ជាឯកសារមាន -- ឯកសារ*កូល័រ* មានពណ៌ដែលចេញនៅ -- ដាក់ចេញនៅខែកក្កដា ឆ្នាំ១៩៧៥ ដែលអង្គជំនុំជម្រះបានទទួលហើយ។ ហើយឯកសារនេះគឺថាបានដាក់ជូនអង្គជំនុំជម្រះ តាមរយៈការិយាល័យសហព្រះរាជអាជ្ញារួចមកហើយ គឺឯកសារ E3/724។ ជាការសង្ខេបជាភាសាអង់គ្លេស នូវទង់បដិវត្តនេះ អាចថារៀបចំឡើងដោយសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ក៏ថាបាន ដោយសាស្ត្រាចារ្យ ស្ទីវ ហេដឌ័រ ក៏ថាបាន ដែលជាការបកប្រែចេញមកពីឯកសារទង់បដិវត្តដើមតែម្តង។

[១៣:៥១:២០]

ហើយដូចគ្នានេះដែរ ឯកសារ E169/4/1.1.1 គឺថាមានពណ៌របស់វា *កូល័រ* របស់វា ដែលចន្លោះចេញពីឆ្នាំ១៩៧៥ ទៅ៧៦ ជាឯកសារទង់បដិវត្ត។ ហើយឯកសារនេះក៏បានដាក់ជូនអង្គជំនុំជម្រះដោយការិយាល័យសហព្រះរាជអាជ្ញារួចមកហើយដែរ ជាឯកសារ E3/73។ បាទ សូមកែប្រែ E3/731 គឺជាទង់យុវជនបដិវត្តដែរ ហើយខ្ញុំផ្តល់ជូននូវឯកសារ E នេះ ដែលក្នុងនោះរួមបញ្ចូលទាំងពីឯកសារ E3 នេះផងដែរ ដែលខាងការិយាល័យសហព្រះរាជអាជ្ញា បានដាក់ជូនអង្គជំនុំជម្រះរួចមកហើយ។

ដូច្នេះខ្ញុំគ្រាន់តែចំណាយពេលខ្លីទេ ដើម្បីបង្ហាញចំនួនពីរបីទំព័រនូវទង់យុវជនបដិវត្ត ខែកក្កដា ឆ្នាំ៧៥។ ខ្ញុំសូមការអនុញ្ញាតពីលោកដើម្បីបង្ហាញឯកសារនៅលើអេក្រង់។

វាជា វាមានសារៈសំខាន់ណាស់ ដែលយើងត្រូវពិនិត្យមើលទៅលើឯកសារពណ៌នេះ គឺឯកសារទង់យុវជនបដិវត្ត។ យើងឃើញមានពណ៌ក្រហម ដែលមានទង់ពណ៌ក្រហម ហើយយើងឃើញថាមានកិប មានស្នាមកិបនៅកៀនខាងឆ្វេង។ ហើយខ្ញុំយល់ -- ខ្ញុំគិតឃើញថា អាចមើលឃើញហើយខាងក្រុមការពារក្តីរបស់លោក នួន ជា។

[១៣:៥៣:១៦]

ថ្ងៃនេះខ្ញុំនឹងបញ្ចប់ដោយអានតែសម្រង់ផ្សេងៗ ដែលខ្ញុំយល់ឃើញថា ផ្នែកនេះគឺនៅក្នុងឯកសារទង់យុវជន យុវនារីបដិវត្ត លេខ៧ កក្កដា ១៩៧៥ គឺថាជាឯកសារមួយដែលបានដាក់ចេញបន្ទាប់ពី

ជ័យជម្នះខែមេសា ឆ្នាំ១៩៧៥។ ERN ជាភាសាខ្មែរ 00809798 ដល់ 809799 គឺទង់បដិវត្ត ដែល -- ទង់យុវជន យុវនារីបដិវត្ត ខែកក្កដា ៧៥ ERN ជាភាសាអង់គ្លេស 00815132 ដល់ 815133, ERN ជាភាសាបារាំង 00815911 ដល់ 912។ មានការពិភាក្សាគ្នាអំពីព្រឹត្តិការណ៍ ក្រោយថ្ងៃរំដោះ១៧ មេសា ៧៥។

ខ្ញុំសូមអាន សូមដកស្រង់ "នៅពេលយើងរំដោះទីក្រុងភ្នំពេញ និងទូទាំងប្រទេសភ្លាម យុវជន យុវនារី និងកម្មាភិបាលយើងត្រូវចូលមកកាន់កាប់ទីក្រុងភ្លាម។ ដូច្នេះ គឺយើងចូលមករស់នៅក្នុងបរិយាកាសសក្តិភូមិនាយទុន ដែលមានសម្ភារៈប្រណិត សម្បូរបែបគ្រប់យ៉ាង ដែលពីមុនយើងមិនដែលមាន មិនដែលស្គាល់ និងមិនដែលជួបប្រទះឡើយ"។

[១៣:៥៥:០២]

កថាខណ្ឌក្រោយមកទៀត "ហេតុដូច្នេះហើយ កម្មាភិបាលខ្លះបានប្រមូលយកវិទ្យុ ទូរទឹកកកជាដើម ប៉ុន្តែគេទុកចោលនូវសម្ភារៈសំខាន់ៗ ដូចជាកាំភ្លើងធំ អាល់តែរី គ្រាប់រំសេវផ្សេងៗ កាំភ្លើងដៃ ហើយកាំភ្លើងយន្តសំខាន់ៗនោះ គឺថាទុកចោលគ្រប់ទីកន្លែងទាំងអស់។ មិនមានអ្នកណាម្នាក់យកចិត្តទុកដាក់មើល និងយកទៅទុកនៅកន្លែងណាមួយឲ្យបាន -- គ្មានអ្នកណាម្នាក់យកភ្នែកមើល ឬប្រមូលទុកដាក់ឡើយ។ បើជាយុទ្ធវិធីវិញ ខ្លះលបលួចស្លៀកពាក់ខោអាវខ្មាំង។ លបលួចលាបទឹកអប់ លាបម្សៅ ពួកគេភ្លេចអំពីទស្សនៈប្រុងប្រយ័ត្ន និងជំហរបដិវត្តន៍ខ្ពស់។ ពួកគេភ្លេចអំពីកាតព្វកិច្ចរបស់បក្ស ដែលបានប្រគល់ទៅឲ្យពួកគេដើម្បីការពារ និងបោសសម្អាតទីក្រុងជាប្រចាំ។ ហើយនេះក៏ជាឥទ្ធិពលមួយមិនល្អរបស់ខ្មាំងនោះផងដែរ។ ក្នុងស្ថានភាពភ្លើតភ្លើនហ៊ឺហាគគ្រឹកគគ្រេងបាត់ម្ចាស់ការ ភ្លេចគោលជំហរបដិវត្តន៍យ៉ាងនេះ។ ប្រសិនជាបក្សគ្មានវិធានការជម្លៀសប្រជាជនឲ្យចេញអស់ពីទីក្រុងភ្នំពេញ និងទីរួមខេត្តនានាទេនោះ ប្រហែលជាខ្មាំងនឹងវាយសង្គ្រប់យើងពីក្រោយទៅវិញ កម្ទេចកម្លាំងបដិវត្តន៍យើងខ្ទេចខ្ទីរអស់ ឬយ៉ាងហោចណាស់ក៏ខ្មាំងស៊ីរូងផ្ទៃក្នុងបដិវត្តន៍យើង ធ្វើឲ្យផ្ទៃក្នុងជួបប្រទះភាពច្របូកច្របល់ ឥតអង្គការវិន័យ បែកបាក់សាមគ្គី និងគោលជំហរបដិវត្តន៍។ ដូច្នេះ ខ្មាំងអាចវាយកម្ទេចយើងថ្ងៃណាមួយក៏បាន។ ដូច្នេះមហាជ័យជម្នះរបស់យើងនៅថ្ងៃទី១៧ មេសា របស់យើងគឺនឹងត្រូវរលាយខ្យល់ទៅវិញពុំខាន"។

លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់ការអានសម្រង់នៃឯកសារនេះ។ ហើយខ្ញុំសូមបញ្ជូនសូមជូនវេទិកានេះទៅសហការីរបស់ខ្ញុំ ដើម្បីធ្វើការបង្ហាញ។ សូមអរគុណ។

[១៣:៥៧:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្លាឯល៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ជម្រាបសួរសាធារណជនផងដែរ។ ឥឡូវនេះ ខ្ញុំចូលទៅដល់ប្រធានបទផ្សេងទៀត គឺពាក់ព័ន្ធទៅនឹងរដ្ឋាភិបាលដែលមានក្រសួងផ្សេងៗដែលបង្កើតបានជារដ្ឋាភិបាលនេះ។ ខ្ញុំនឹងនិយាយអំពីរចនាសម្ព័ន្ធ ការប្រព្រឹត្តទៅ និងការទំនាក់ទំនងគ្នានៅក្នុងរដ្ឋាភិបាល។

មុននឹងចូលទៅដល់ឯកសារជាក់លាក់ដែលពាក់ព័ន្ធទៅនឹងក្រសួងមួយចំនួននោះ។ ជាដំបូងខ្ញុំចង់បង្ហាញនូវឯកសារមួយ -- ឯកសារមួយចំនួនពាក់ព័ន្ធនឹងរដ្ឋាភិបាលទាំងមូល។ ជាដំបូង គឺរដ្ឋាភិបាលនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បន្ទាប់មកគឺរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីឱ្យយល់ច្បាស់អំពីការវិវត្ត នៃរដ្ឋាភិបាល និងប្រភេទផ្សេងៗនៃរដ្ឋាភិបាលរបស់ហ្វ្រុង និងរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ នៅចន្លោះថ្ងៃទី១៧ ខែមេសា ៧៥ រហូតទៅដល់ថ្ងៃទី៧ ខែមករា ឆ្នាំ៧៩។ ខ្ញុំចង់ប្រើពេលប្រាំទៅដប់នាទី ត្រឡប់មកនិយាយអំពីឯកសារបី ដែលនិយាយអំពីរដ្ឋាភិបាលក្នុងអំឡុងរយៈពេលមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដើម្បីឱ្យយើងយល់ច្បាស់អំពីស្ថានភាព -- ការវិវត្ត ពីស្ថានភាពមួយទៅស្ថានភាពមួយ។

[១៣:៥៩:០៩]

ឯកសារដំបូងនោះ គឺឯកសារលេខ E3/28 ដែលចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៣ ដែលមានចំណងជើងថា "អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ"។ ខ្ញុំសូមដកស្រង់តែមួយឃ្លាទេ គឺនៅចុងឯកសារ នៅក្នុងឧបសម្ព័ន្ធដែលនិយាយអំពីសមាសភាពរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅសម័យនោះ។ ខ្ញុំសូមដកស្រង់ "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាហ្វ្រុង ស្ថិតនៅក្រោមការគាំទ្ររបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលបានបង្កើតឡើងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ៧០។ រដ្ឋាភិបាលនេះ គឺជារដ្ឋាភិបាលស្របច្បាប់តែមួយគត់របស់ប្រទេសកម្ពុជា។ សមាសភាពរបស់រដ្ឋាភិបាលនេះគឺមានដូចតទៅ"។ ដូច្នេះនេះគឺ ជាសមាសភាពរដ្ឋាភិបាលនៅឆ្នាំ៧៣។ ដូច្នេះដើម្បីឱ្យចំណេញពេល ខ្ញុំសូមដកស្រង់តែឈ្មោះមួយចំនួនតែប៉ុណ្ណោះ ដូច៖ ទី១) លោក ប៉ែន នុត នាយករដ្ឋមន្ត្រី, ទី២)លោក ខៀវ សំផន ឧប

នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ, ទី៣) លោក សារិន ឆាក រដ្ឋមន្ត្រីក្រសួងការបរទេស, លោក ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន។

យើងនឹងឃើញថានៅក្នុងបញ្ជីឈ្មោះឯកសារនេះក៏មានឥស្សរជនមួយចំនួនទៀតដូចជា៖ ចាន់ យូរ៉ាន់, ឧត្តមសេនីយ ដួង សំអុល, ហួត សម្បត្តិ, ជា សាន, ជួន ប្រាសិទ្ធ, គាត ឈន់, វ៉ាន់ ពីនី, ទីវ អុល និងក៏មាន អៀង ធីរិទ្ធ ផងដែរ ដែលជាអនុរដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជន, ជូ ជេត អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ ក្រសួងកិច្ចការសាសនា និងសង្គមកិច្ច ហើយនិង លោក កុយ ធួន អនុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

[១៤:០១:១២]

ឯកសារបន្ទាប់មកទៀត គឺឯកសារលេខ E3/1399 ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៥។ ឯកសារនេះមានចំណងជើងថា "ខុទ្ទកាល័យរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សេចក្តីថ្លែងការណ៍របស់សម្តេចសីហនុ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៤"។ ឯកសារនេះគឺផ្សព្វផ្សាយនូវសេចក្តីថ្លែងការណ៍មួយចំនួនរបស់ហ្រ្គុងដែលបានចុះផ្សាយនៅក្នុងហ្វីប៊ីស ហើយនៅក្នុងនោះយើងអាចដឹងថា បើធៀបទៅនឹងខែមករា ឆ្នាំ១៩៧៣ ឥស្សរជនមួយចំនួនបានឆ្លងពីឋានៈអនុរដ្ឋមន្ត្រីឡើងទៅជារដ្ឋមន្ត្រី។

ឧទាហរណ៍ ដូចជា ជូ ជេត និង អៀង ធីរិទ្ធ គឺនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៣។ ហើយយើងកត់សម្គាល់ឃើញផងដែរថា បើតាមសេចក្តីថ្លែងការណ៍របស់សម្តេចសីហនុ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៤ "កុយ ធួន នៅពេលនោះបានក្លាយទៅជាអនុរដ្ឋមន្ត្រី សូមទោស គឺបានក្លាយទៅជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកាលពីមុនគាត់ជាអនុរដ្ឋមន្ត្រី"។ ឯកសារហ្វីប៊ីស ដែលចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៥ គឺនៅក្នុងឯកសាររបស់យើង E3/31 គឺថា -- E9/31 គឺជាឯកសារថ្មី។ ខ្ញុំសូមផ្តល់លេខ ERN ជាភាសាខ្មែរ 00811259 រហូតទៅដល់ 00811265, ជាភាសាអង់គ្លេស 00166706 រហូតទៅដល់ 08។ ឯកសារហ្នឹងមិនមានការបកប្រែជាភាសាបារាំងទេ។

មានសម្រង់ពីរដែលខ្ញុំចង់អាន។ មានអត្ថបទមួយដែលមានចំណងជើងជាភាសាអង់គ្លេស ពីព្រោះថាជាភាសាបារាំងមិនមានទេ។

[១៤:០៣:៤០]

(គ្មានការបកប្រែ)

[១៤:០៣:៥៣]

នៅទំព័រជាភាសាអង់គ្លេស 00166706 ជាភាសាខ្មែរ 008811259 (ស៊ីក) រហូតដល់ 261ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។

ខ្ញុំសូមអភ័យទោសចំពោះអ្នកបកប្រែផង ដែលឆ្លងពីភាសាបារាំងចូលអង់គ្លេសបែបនេះ។ គឺលេខ១៥០ មាត្រាទី១ ដោយមានការស្នើសុំពីក្រសួងការងារគឺតែងតាំង ហួត សម្បត្តិ, ជា សាន, ចាន់យូរ៉ាន់, ជួន មុំ, ដួង សំអុល, ថៅ សេង, គាត ឈន់ ហើយនិង ជួន ប្រាសិទ្ធ”។ សូមបញ្ចប់ការដកស្រង់។

អត្ថបទទី២ នៃឯកសារនេះដដែលមានចំណងជើងថា “សីហនុ តែងតាំងរដ្ឋមន្ត្រីថ្មីនៃរាជរដ្ឋាភិបាលរួបរួមជាតិ”។ ខ្ញុំក៏សូមដកស្រង់ឯកសារនេះជាភាសាអង់គ្លេសដែរ គឺនៅទំព័រ 00166707 ERN ជាភាសាខ្មែរ 008811263 (ស៊ីក)។ ដូច្នេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។

មាត្រាលេខ១០១ -- អនុក្រឹត្យលេខ ១០១ មាត្រា១ ក្នុងការអនុវត្តក្រឹត្យលេខ៩០ ដែលបានចែងពីខាងលើចុះថ្ងៃទី -- ក្នុងពេលនេះ គឺថាមានការតែងតាំងព្រះអង្គម្ចាស់ នរោត្តម ភូរីស្សារា ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ជួន ជឿន ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ទូរគមនាគមន៍ និងសាងសង់។ លោក តូច ភឿន រដ្ឋមន្ត្រីក្រសួងសាសនា និងសង្គមកិច្ច។ លោក ជូ ជេត រដ្ឋមន្ត្រីក្រសួងអប់រំ និងយុវជន អៀង ធីរិទ្ធ ជា -- ហើយនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ គឺ គាត ឈន់។

[១៤:០៦:២៧]

ឥឡូវនេះ ខ្ញុំនិយាយអំពីសមាសភាពផ្លូវការរបស់រដ្ឋាភិបាលហ្រ្គុង ក្រោយជ័យជម្នះថ្ងៃទី១៧ ខែមករា (ស៊ីក) ឆ្នាំ១៩៧៥ និងការតែងតាំងមួយចំនួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ស្របពេលជាមួយគ្នានោះ។ យោងតាមក្រឹត្យថ្ងៃទី១៥ ធ្នូ ឆ្នាំ៧៤ គ្មានអ្វីដែលអាចបញ្ជាក់នៅក្នុងនោះថា មានការផ្លាស់ប្តូរសមាសភាពផ្លូវការរបស់ហ្រ្គុង ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ នោះទេ ក៏ប៉ុន្តែមានឯកសារមួយដែលមានលេខ E3/1256 ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៥។

ឯកសារនេះ គឺជាសេចក្តីប្រកាសរបស់ស្ថានបេសកកម្មនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសបារាំង។ នៅក្នុងទំព័រជាភាសាខ្មែរ ERN S00630985, ជាភាសាបារាំងទំព័រទី២ ERN S00004674, ERN ជាភាសាអង់គ្លេស 00280610។ ខ្ញុំសូមដកស្រង់ “សេចក្តីប្រកាស៖ ស្ថានបេសកកម្មនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសបារាំង ត្រូវបានអនុញ្ញាតឲ្យផ្តល់សេចក្តីបញ្ជាក់ដូចតទៅ ទាក់ទងទៅនឹងការតែងតាំងថ្មីៗនេះ នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

ដែលបានធ្វើឡើងកាលពីថ្ងៃទី១២ ខែសីហា នេះគឺនៅឆ្នាំ៧៥។

[១៤:០៨:២៣]

លោក អៀង សារី ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការបរទេសប្រចាំនៅទីស្តីការគណៈរដ្ឋមន្ត្រី។ លោក សុន សេន ត្រូវបានតែងតាំងជាឧបនាយរដ្ឋមន្ត្រី ទទួលបន្ទុកការពារជាតិ អមទីស្តីការគណៈរដ្ឋមន្ត្រី។ ហើយចុះមកក្រោមមកទៀត រដ្ឋមន្ត្រីដទៃទៀតទាំងអស់ នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រក្សាមុខតំណែងរបស់ខ្លួននៅដដែល។

ខ្ញុំសូមចូលទៅឯកសារមួយផ្សេងទៀត គឺចុះឆ្នាំ៧៥ គឺជាឯកសារនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ៧៥ គឺឯកសារ E3/182។ ឯកសារនេះត្រូវបានលើកឡើងដោយសហភាតារបស់ខ្ញុំកាលពីព្រឹកមិញរួចហើយ។ ក៏ប៉ុន្តែខ្ញុំសូមលើកឡើងនូវផ្នែកផ្សេងទៀត នៃឯកសារដដែលនេះ គឺកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ រហូតមកដល់ពេលនេះគឺឯកសារដែលខ្ញុំលើកឡើង គឺជាឯកសាររបស់ក្រុង ក៏ប៉ុន្តែឯកសារនេះ គឺជាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:០៩:៤១]

នៅចំណុចដំបូងដែលយើងឃើញនិយាយ អំពីការបែងចែកការងារ និងកិច្ចដំណើរការនោះ គេនិយាយអំពីការបែងចែកភារកិច្ច របស់បក្សកុម្មុយនីស្តកម្ពុជានៅផ្ទៃក្នុង។ ខ្ញុំសូមដកស្រង់នូវឃ្លាដំបូងនៃឯកសារ ដែលជាភាសាខ្មែរ គឺចាប់ពីទំព័រ ដែលមានលេខ ERN 00019108, ជាភាសាអង់គ្លេស 00183393 រហូតដល់ 94, ជាភាសាបារាំង 00292868 ដល់ 69។ ខ្ញុំសូមដកស្រង់ "១. សមមិត្ត លេខា ទទួលរួមយោធា និងសេដ្ឋកិច្ច។ ២. សមមិត្តអនុលេខា កាងារបក្សសង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ។ ៣. សមមិត្ត វ៉ាន់ ការងារបរទេស ទាំងបក្ស ទាំងរដ្ឋ។ ៤. សមមិត្ត ហែម ទទួលរណសិរ្ស និងរាជរដ្ឋាភិបាល ពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ។ ៥. សមមិត្ត ធុច ខ្ញុំសូមប្រកប "តេ.អាស.អ៊ុយ.សេ.អាស" ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស។ ៦. សមមិត្ត ខៀវ ទទួលសេនាធិការ និងសន្តិសុខ។ ៧. សមមិត្ត វន ឧស្សាហកម្ម ស្ថានីយរដ្ឋភ្លើង និងនេសាទ។ ៨. សមមិត្ត ខឿន ប្រធានមន្ទីរនយោបាយ៨៧០។ ៩. សមមិត្ត ភា ទទួលបន្ទុកវប្បធម៌ សង្គមកិច្ច និងកិច្ចការបរទេស។ ១០. សមមិត្ត អាត ឃោសនាការ អប់រំ ទាំងក្នុង និងក្រៅ។ ១១. សមមិត្ត ជ័យ "សេ.អាស.អឺ.អ៊ីការិច" កសិកម្ម។ ១២. សមមិត្ត យ៉ែម ការិយាល័យ៨៧០។ និងជាចុងក្រោយលេខ ១៣ សមមិត្ត ប៉ង់ មន្ទីរដ្ឋាភិបាល"។

[១៤:១២:១២]

ដូចដែលយើងបានឃើញពីមុនមកហើយគឺថា មេដឹកនាំតែប្រាំប៉ុណ្ណោះដែលមាននៅក្នុងបញ្ជីនេះ ដែលកាន់មុខងារជារដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាល រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមានដូចជា វ៉ាន់ ដែលជា អៀង សារី, ហែម ដែលជា ខៀវ សំផន, ខៀវ ដែលជា សុន សេន ដែលទាំងអស់នេះគឺ កាលពីមុនគឺ ជាឧបនាយករដ្ឋមន្ត្រី នៃហ្វ្រុង។ បន្ថែមពីលើនេះទៀត មានឈ្មោះ ធុច ដែលជា កុយ ធួន ជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយនិងមាន ភា ដែលជា អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជន។

ឥឡូវនេះ ខ្ញុំសូមចូលទៅឯកសារបន្តទៅទៀត គឺការលាលែងតំណែងរបស់ សីហនុ និងការរៀប ចំការបោះឆ្នោតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ៧៦ ផ្តល់ឱកាសឲ្យមានការផ្លាស់ប្តូរ ឧបសម្ព័ន្ធទាំងស្រុង ហើយនិងធ្វើឲ្យរុញផ្ទប់រាជរដ្ឋាភិបាលហ្វ្រុង ហើយឲ្យលេចឡើងនៅតែ -- ឲ្យលេចឡើងតែមេដឹកនាំនៃ បក្សកុម្មុយនីស្តកម្ពុជា។

ខ្ញុំសូមលើកឡើងនូវឯកសារ ដែលបានលើកឡើងកាលពីព្រឹកមិញរួចមកហើយ គឺឯកសារ E3/197 ដែលជាកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្ស ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦។ យើងដឹងហើយថា នេះគឺជាកំណត់ហេតុដែលនិយាយអំពីជំហររបស់បក្ស ចំពោះ សីហនុ ហើយនិង ចំពោះពួកសក្តិភូមិ។ ក្នុងនេះ មានបង្ហាញអំពីអ្នកចូលរួមមាន លេខា, អនុលេខា, សមមិត្ត វន, សមមិត្ត ខៀវ, សមមិត្ត ហែម, សមមិត្ត ឌឿន, សមមិត្ត ទុំ និងសមមិត្ត ទូច។

[១៤:១៤:២០]

ខ្ញុំសូមអានសម្រង់ជាភាសាខ្មែរ ដែលនៅក្នុង -- ដែលមានលេខ ERN 00000744, ជាភាសា អង់គ្លេស 00182639, ជាភាសាបារាំងគឺទំព័រទី១ ទី២ ERN 00334961 ទៅដល់ 62។ គេ និយាយអំពីបច្ច័យល្អ និងបច្ច័យអាក្រក់បណ្តាលមកពីការលាលែងរបស់ សីហនុ ចំពោះបដិវត្តន៍។ ខ្ញុំ សូមដកស្រង់ "២ក) បច្ច័យល្អឲ្យបដិវត្តន៍យើង។ ម្យ៉ាងប្រជាជនយើងទាំងមូលបានដកដង្ហើមធំចុង ក្រោយរបស់ខ្លួនផុតហើយ កម្មាភិបាលយើង កងទ័ពយើង ក៏ដូច្នេះ។ ចំណុចទី៣ នៅ ២ក ការងារ បរទេសយើង ក៏នឹងល្អជាងមុន ពីព្រោះយើងធ្វើខ្លួនយើង យើងយកជំហរដោយខ្លួនយើង ព្រោះអត់ សីហនុ យើងជ្រះស្រឡះ"។

ចុះក្រោមមកទៀត នៅក្នុងឯកសារដដែលនេះ គឺ ERN ជាភាសាខ្មែរ 00000747 ទៅដល់ 48,

ជាភាសាអង់គ្លេស 00182640 ទៅដល់ 41, ជាភាសាបារាំង ទំព័រ៣ ERN 00344963។ គឺចំណងជើង “III.មតិរបស់អង្គការ អង្គប្រជុំយកថ្ងៃទី១៣ ខែមីនា”។

[១៤:១៦:១៧]

ខ្ញុំសូមដកស្រង់ “សមមិត្ត ហែម បានបញ្ជាក់ថា គាត់និយាយអំពីការលាលែងរបស់ សីហនុ។ គាត់និយាយថា បញ្ហានេះ សំខាន់ណាស់ យើងទុកឲ្យគណៈអចិន្ត្រៃយ៍នៃអង្គការជាអ្នកសម្រេច”។ ហើយគាត់បានស្នើនូវវិធានការមួយចំនួនដែលមិនបាននិយាយពីព្រឹកមិញនេះទេ គឺវិធានការទី២ “គឺថាត្រូវប្រជុំគណៈរដ្ឋមន្ត្រី រាយការណ៍ជូនគណៈរដ្ឋមន្ត្រីដើម្បីសម្រេច រួចហើយទៅជួប សីហនុ ទៀត ដោយមាន ប៉ែន នុត ចូលរួមផង។ បើលែលកឲ្យគាត់ថតសំឡេងបានទៀត រឹតតែជាប្រសើរ”។ ឯកសារទាំងអស់នេះ យើងឃើញថា អំពីថាឆន្ទៈរបស់គណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា គឺថា ទី១ គណៈមជ្ឈិមសម្រេចអំពីបញ្ហារបស់ សីហនុ។ ទី២ យើងឃើញថា មានគណៈរដ្ឋមន្ត្រីរបស់ក្រុង ហើយនិងនាយករដ្ឋមន្ត្រី ប៉ែន នុត ដែលបានអនុម័តលើការលាលែងរបស់សម្តេច សីហនុ។

បន្ទាប់មកទៀត ខ្ញុំសូមលើកឡើងនូវឯកសារ E3/12 ដែលជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមលើបញ្ហាមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦។ យើងបាននិយាយកាលពីព្រឹកមិញហើយ ក៏ប៉ុន្តែខ្ញុំសូមដកស្រង់នូវឃ្លាផ្សេងទៀត នៃសេចក្តីសម្រេចដដែលនេះ។ ឃ្លានោះគឺដែលបញ្ជាក់អំពីការសម្រេចរបស់គណៈអចិន្ត្រៃយ៍ពាក់ព័ន្ធទៅនឹងការលាលែងរបស់សម្តេច សីហនុ ហើយនិងការដកចេញនូវសម្តេច ប៉ែន នុត។ ឃ្លាដំបូង ដែលពាក់ព័ន្ធនោះ គឺជាភាសាខ្មែរ នៅទំព័រដែលមាន ERN 00003140 រហូតទៅដល់ 41, ជាភាសាអង់គ្លេស 00182813, ជាភាសាបារាំង គឺ 00224366។ នៅចំណុច១២ នៃឯកសារនេះ ដែលមានចំណងជើងថា “អំពីការរៀបចំចាត់តាំងអង្គការរដ្ឋ”។

[១៤:១៨:៤៧]

ខ្ញុំសូមដកស្រង់ “គឺសេចក្តីសម្រេចរបស់គណៈមជ្ឈិម។ តាមពិត អង្គការរដ្ឋយើងពេលនេះ គឺខុសពីមុន។ ពេលមុន ធាតុពិតរណសិរ្ស ឥឡូវនេះ មិនដូច្នេះទេ ជាអង្គការរដ្ឋរបស់បក្សសុទ្ធសាធ។ ត្រូវឲ្យអង្គការរដ្ឋទាំងអស់មានលក្ខណៈជាតំណាងពិតប្រាកដ មានឥទ្ធិពលគ្រប់គ្រាន់ ទាំងនៅក្នុងបក្ស ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស។ នេះ ជាការវាយសម្រុកខាងនយោបាយមួយដែរ ប៉ែន នុត មិនមានបញ្ហាអ្វីទេ។ សភាពការណ៍ សីហនុ ទុំហើយ គាត់ដាច់ខ្យល់ហើយ ដំណើរទៅមុខទៀតមិនរួចទេ។ ដូច្នេះ យើងសម្រេចឲ្យគាត់ចូលនិវត្តន៍តាមសំណូមពររបស់គេ”។ សូមបញ្ចប់ការដកស្រង់។

ហើយយើងកត់សម្គាល់ឃើញថា នៅទីនេះ គេមិននិយាយអំពីការលាលែងរបស់សម្ដេច សីហនុ នៅចំពោះមុខគណៈអចិន្ត្រៃយ៍ទេ គេនិយាយអំពីការចូលនិវត្តន៍របស់សម្ដេច សីហនុ ទៀតទៅវិញ។ ឃ្លាទី២នៃឯកសារដដែល ដែលឯកសារ E3/12 នេះគឺនៅចំណុច១២ ERN ជាភាសាខ្មែរ 04--

**អ្នកបកប្រែ៖**

លោកប្រធានសូមអនុញ្ញាតឲ្យលោកសហព្រះរាជអាជ្ញាអានលេខ ERN ជាភាសាខ្មែរឡើងវិញ អ្នកបកប្រែតាមអត់ទាន់។

[១៤:២០:២៥]

**ប្រធានអង្គជំនុំ៖**

អានៗ លេខ ERN ឡើងវិញ ព្រោះបកប្រែបកអត់ទាន់ទេ ហើយសូមឲ្យយឺតជាងនេះបន្តិច។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធានសូមអភ័យទោស។ ជាភាសាខ្មែរគឺ ERN 00003141 រហូតទៅដល់ 42, ជាភាសាអង់គ្លេស 00182814, ជាភាសាបារាំងទំព័រ៤, ៥ នៅលេខ ERN 00224366 ទៅដល់ 67។ នៅក្នុងឃ្លានេះ គឺបន្ទាប់ពីការរៀបរាប់ពីសមាសភាពនៃរដ្ឋសភា ដែលដឹកនាំដោយ នួន ជា រួចហើយ ហើយនឹងមានការរៀបរាប់ពីគណៈប្រធានរដ្ឋ ដែលដឹកនាំដោយសមមិត្ត ហែម។ ឯកសារបន្តទៅទៀត ដោយរៀបរាប់ថា "រដ្ឋាភិបាលត្រូវជាអង្គការរបស់បក្សសុទ្ធសាធ ជារដ្ឋរបស់យើងផ្ទាល់។ សំណូមពរឲ្យខ្លាំងដែរ ត្រូវមានឥទ្ធិពលនៅក្នុងបក្ស នៅក្នុងប្រទេស នៅក្រៅប្រទេស ចំពោះប្រទេសជាមិត្តក្ដី ចំពោះខ្មាំងក្ដី។ បញ្ហារៀបចំរដ្ឋាភិបាលនេះ ពិភាក្សាគ្នាសាចុះសាឡើងតាំងពីខែឧសភា ជាបន្តបន្ទាប់មក។ សមមិត្ត ប៉ុល រដ្ឋមន្ត្រីទី១, សមមិត្ត វ៉ាន់ ឧបនាយកទទួលខាងការបរទេស, សមមិត្ត វន ឧប-នាយកទទួលខាងសេដ្ឋកិច្ច ហិរញ្ញវត្ថុ, សមមិត្ត ខៀវ ឧបនាយកទទួលខាងការពារប្រទេស"។ ហើយចុះខាងក្រោមមកទៀតគឺ វិធានការដោះស្រាយ៖

[១៤:២២:៤៥]

១) ការងាររដ្ឋាភិបាលត្រូវឧបនាយកទាំងបីទទួល។ ដូច្នេះឧបនាយករដ្ឋមន្ត្រីទាំងបី ត្រូវតែខ្លាំង។ ខ្លាំងទាំងបុគ្គល ខ្លាំងទាំងម៉ាស៊ីនធ្វើការងារ។ បន្ទាប់ពីការពិនិត្យបញ្ហាលាលែង ឬក៏បញ្ហាសុំចូលនិវត្តន៍របស់សម្ដេចសីហនុ និងការកែប្រែទាំងស្រុងនូវរដ្ឋាភិបាលដោយគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ៧៦ ដូចដែលយើងបានឃើញរួចមកហើយ និងក្រោយមកទៀតដោយគណៈមជ្ឈិម នៅថ្ងៃ

ទី៣០ ខែមីនា ឆ្នាំ៧៦ គឺនៅជុំវិញគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានការប្រជុំនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ៧៦"។

ដូច្នេះខ្ញុំសូមបង្ហាញឯកសារ E3/1371 ដែលមានចំណងជើងថា "សេចក្តីប្រកាសរបស់រាជរដ្ឋ -- របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចំពោះសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ សុំចូលនិវត្តន៍។ ជាភាសាខ្មែរគឺ 00806211 ខ្ញុំគិតថា គ្រប់ភាសាទាំងអស់ គឺថានៅទំព័រទី១ ព្រោះថាមានតែមួយទំព័រ។ នេះជាសេចក្តីប្រកាសរបស់រដ្ឋាភិបាលហ្គ្រុង ខ្ញុំមិនបានផ្លាស់ប្តូរឈ្មោះទេ ពីព្រោះថាមានសមាសភាពដដែល។ ខ្ញុំសូមដកស្រង់៖

[១៤:២៤:៣២]

"បន្ទាប់ពីបានដឹងអំពីសេចក្តីថ្លែងការណ៍សុំចូលនិវត្តន៍របស់ប្រមុខរដ្ឋ សម្តេចនរោត្តម សីហនុ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ៧៦ គណៈរដ្ឋមន្ត្រីបានបើកកិច្ចប្រជុំនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ៧៦ ក្រោមអធិបតីភាពសម្តេច ប៉ែន នុត នាយករដ្ឋមន្ត្រី ដើម្បីពិនិត្យមើលបញ្ហានេះឲ្យបានហ្មត់ចត់"។ សូមបញ្ចប់ការដកស្រង់។

ហើយបន្ទាប់មកទៀត សេចក្តីថ្លែងការណ៍នេះបន្តទៅទៀត "បន្ទាប់ពីបានលើកឡើងអំពីគុណូបការៈរបស់សម្តេច សីហនុ។ គណៈរដ្ឋមន្ត្រីយល់ឃើញថា យល់ព្រមទៅលើសំណើរបស់សម្តេច ហើយស្នើឲ្យរដ្ឋសភាតំណាងប្រជាជនកម្ពុជាដូចតទៅ៖ "ផ្តល់ជូនដល់សម្តេចសីហនុ នូវកិត្តិនាមជាវរជនស្នេហាជាតិ។ល។" ដូច្នេះយើងឃើញថា យើងមានការលើកឡើងអំពីសេចក្តីសម្រេចរបស់គណៈមជ្ឈិមឈានចូលទៅដល់គណៈអចិន្ត្រៃយ៍ ហើយមានការសម្រេចរបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះយើងអាចសន្និដ្ឋានសមហេតុផលបានថា សភាតំណាងប្រជាជនកម្ពុជា បានគិតអំពីបញ្ហានេះ ហើយអ្វីៗបានស្តែងចេញឲ្យឃើញច្បាស់នៅក្នុងឯកសារE3/165 ដែលនិយាយអំពីកិច្ចប្រជុំលើកទីមួយនៃសភាតំណាងប្រជាជនកម្ពុជានីតិកាលទី១ ដែលប្រព្រឹត្តទៅលើថ្ងៃទី១១ ទៅដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦។

[១៤:២៦:២១]

យើងមានឯកសារមួយទៀត គឺឯកសារដូចគ្នាហ្នឹងដែរ គឺឯកសារ E3/262 ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ៧៦ គឺឯកសារនេះគ្រាន់តែលើកឡើងដដែល នូវសេចក្តីប្រកាសព័ត៌មានដែលមាននៅក្នុងឯកសារមុន ដែលឯកសារ E3/165 រួចមកហើយ។ ហើយសេចក្តីប្រកាសព័ត៌មាននេះចុះហត្ថលេខា

ដោយនួន ជា។ យើងមើលឃើញទៀតថា មានការសម្រេចរបស់គណៈអចិន្ត្រៃយ៍ ហើយនិងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល។ ឯកសារថ្ងៃទី១៤ ខែមេសា ៧៦នេះបញ្ជាក់អំពីការតែងតាំង នួន ជា ជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា។ បន្ទាប់មកទៀត សភាឯកភាពជាឯកច្ឆន្ទនូវការស្នើសុំចូលនិវត្តន៍ របស់សម្តេចសីហនុ ទៅតាមសំណើដែលមានចុះនៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលនៅថ្ងៃទី៤ ខែមេសា ឆ្នាំ៧៦ ដែលខ្ញុំបានអានរួចមកហើយ។ នៅក្នុងឯកសារនេះដដែលសភាចាត់តាំង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។

[១៤:២៧:៤២]

នៅចំណុចទី៤ នៃឯកសារនោះ និយាយអំពីសេចក្តីព្រាងនៃសេចក្តីសម្រេច ការពិនិត្យ និងការឯកភាពទៅលើការលាលែងនៃរដ្ឋាភិបាលចាស់។ យើងអាចឃើញនៅក្នុងឯកសារជាភាសាខ្មែរ 00053634, ជាភាសាអង់គ្លេស 00184067 ទៅដល់ 68, ជាភាសាបារាំង គឺទំព័រ២១ ERN 00301354។ ក្នុងឯកសារនោះបាននិយាយថា សភាកត់សម្គាល់ឃើញថា រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យដែលពីមុនគេហៅថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ៧០ ខ្ញុំសូមរំលងឃ្លាមួយចំនួន។ រាជរដ្ឋាភិបាល -- រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលពីមុនហៅថា ហ្គ្រុង នោះបានបញ្ចប់បេសកកម្មរបស់ខ្ញុំទាំងស្រុង។ ហើយបន្ទាប់មកបានស្នើលាលែងនៅថ្ងៃទី៦ ខែមេសា ឆ្នាំ៧៦ សភាបានអនុម័តជាឯកច្ឆន្ទនូវការលាលែងរបស់រដ្ឋាភិបាលចាស់។ ក្រៅពីមានការលាលែងរបស់រដ្ឋាភិបាលចាស់ គឺមានការតែងតាំងរដ្ឋាភិបាលថ្មីនៅក្នុងចំណុចទី៦ នៃឯកសារដដែលនេះគឺឯកសារ E3/165 នៅចំណុចទី៦ ដែលមានចំណងជើងថា "ការតែងតាំងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ ជាភាសាខ្មែរគឺ 00053635, ភាសាបារាំង ទំព័រ២២ ERN 00301355, ជាភាសាអង់គ្លេស 00184068 ទៅដល់ 69។

[១៤:៣០:០០]

ខ្ញុំសូមដកស្រង់នូវឃ្លាដែលពាក់ព័ន្ធទៅនឹងរដ្ឋាភិបាលថ្មី "ក្រោយពីបានពិភាក្សាយ៉ាងហ្មត់ចត់ និងល្អិតល្អន់ ទៅលើលក្ខណៈសម្បត្តិនោះ រដ្ឋសភាបានសម្រេចការតែងតាំងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យដែលមានសមាសភាពដូចតទៅ៖

ទី១) សមមិត្ត ប៉ុល ពត នាយករដ្ឋមន្ត្រី

២) សមមិត្ត អៀង សារី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស

៣) សមមិត្ត វន វេត ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច

៤) សមមិត្ត សុន សេន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការការពារជាតិ

៥) សមមិត្ត ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន

៦) សមមិត្ត ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាល

៧) សមមិត្ត អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច

៨) សមមិត្ត តូច ភឿន រដ្ឋមន្ត្រីក្រសួងសាធារណការ និងជាចុងក្រោយ គឺលេខ

៩) សមមិត្ត យុន យ៉ាត រដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងសិក្សាធិការ

ក្នុងក្របខ័ណ្ឌរដ្ឋាភិបាលមានការចាត់តាំងគណៈកម្មាធិការរបស់ក្រសួង ទីស្តីការឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច ដែលមានដូចតទៅ៖

[១៤:៣១:៣០]

១) គណៈកម្មាធិការកសិកម្ម

២) គណៈកម្មាធិការឧស្សាហកម្ម

៣) គណៈកម្មាធិការពាណិជ្ជកម្ម

៤) គណៈកម្មាធិការគមនាគមន៍

៥) គណៈកម្មាធិការថាមពល

៦) គណៈកម្មាធិការចម្ការកៅស៊ូ

ប្រធានគណៈកម្មាធិការនីមួយៗមានឋានៈស្មើនឹងរដ្ឋមន្ត្រី និង -- នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"។ សូមបញ្ចប់ការដកស្រង់។

[១៤:៣១:៥៨]

ដូច្នេះយើងកត់សម្គាល់ឃើញថា ឯកសារនេះមិនបានចាត់តាំង -- ឯកសារនេះបានចាត់តាំងអំពីប្រធានគណៈកម្មាធិការដែលមានឋានៈជារដ្ឋមន្ត្រី។ ទី២ យើងកត់សម្គាល់ឃើញថា "ប៉ែន នុត លែងជានាយករដ្ឋមន្ត្រីហើយ ហើយត្រូវជំនួសជាផ្លូវការដោយ ប៉ុល ពត។ ហើយក៏យើងកត់សម្គាល់ឃើញនូវអវត្តមានរបស់ កុយ ធួន ក្នុងឋានៈជារដ្ឋមន្ត្រី"។ យើងយល់ថាហេតុអ្វីបានជាសភាមិនបានចាត់តាំងលេខានៃគណៈកម្មាធិការដែលខ្ញុំបានលើកឡើងនេះ។ នៅពេលដែលយើងអានឯកសារ គឺឯកសារ E3/235 ឯកសារនេះមានចំណងជើងថា "សេចក្តីសង្ខេបនៃសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៅ

ឆ្នាំ៧៦"។ នៅដំបូងឯកសារនេះបានលើកឡើងនៅទំព័រជាភាសាខ្មែរ 00019142 រហូតទៅដល់ 43, ជាភាសាអង់គ្លេស 00183416 ទៅដល់ 17, ជាភាសាបារាំង ERN 00322968 ទៅដល់ 69។ ខ្ញុំសូមដកស្រង់ "បន្ទាប់ពីបានពិភាក្សាអស់រយៈពេល៣ថ្ងៃលើបញ្ហាដែលមានចុះក្នុងរបៀបវារៈ គណៈអចិន្ត្រៃយ៍បានសម្រេចដូចតទៅ៖

I) អំពីការរៀបចំចាត់តាំងគណៈកម្មាធិការផ្សេងៗនៅជុំវិញ៨៧០ នៅក្នុងឯកសារនេះនិយាយអំពីគណៈកម្មាធិការដល់ទៅ១១ មិនមែន៦ ទេ។ ខ្ញុំសូមដកស្រង់គណៈកម្មាធិការមួយចំនួន៖ គណៈកម្មាធិការទី១ គឺគណៈកម្មាធិការពាណិជ្ជកម្ម ដែលមានសមាជិក សមមិត្ត វិត សមមិត្ត ញ៉ែម សមមិត្ត ឈឿន។

យើងនឹងត្រឡប់មកនិយាយអំពីគណៈកម្មាធិការនេះនៅពេលក្រោយ។ ហើយមានគណៈកម្មាធិការផ្សេងៗទៀតដូចជា៖ គណៈកម្មាធិការដឹកជញ្ជូនផ្លូវគោក មានសមមិត្ត ហាន គណៈកម្មាធិការឧស្សាហកម្ម មានសមមិត្ត អន ឃ្លាំងនៅភ្នំពេញដែលមាន រឿន ជាលេខា គណៈកម្មាធិការកំពង់ផែដែលដឹកនាំដោយឈ្មោះ គ្រិន ។ កសិកម្ម ដឹកនាំដោយឈ្មោះ ជ័យ ហើយនិងមានគណៈកម្មាធិការផ្សេងៗទៀត។

[១៤:៣៥:០៤]

សម្រង់ទី២ នៃឯកសារ E3/235 ជាភាសាខ្មែរ នៅទំព័រ 00019146 ទៅដល់ 47, ជាភាសាអង់គ្លេស 00183420, ភាសាបារាំង 00322971។ នៅក្នុងនេះ នៅក្នុងចំណងជើងលេខ IV និយាយអំពីបញ្ហាពាណិជ្ជកម្ម និង ឧស្សាហកម្ម។ កថាខណ្ឌទី១ និយាយអំពីគណៈប្រតិភូកូរ៉េ។ នេះគឺជាការលើកឡើងនៃឯកសាររបស់គណៈអចិន្ត្រៃយ៍ តែងតាំងគណៈកម្មាធិការមួយដើម្បីទៅចរចាជាមួយអ្នកផ្សេង គឺសមមិត វន, សមមិត្ត អន, សមមិត្ត ជ័យ និង សមមិត្ត ឈឿន។ ចំណុចទី២ ខាងមន្ទីរជាជំនួយពាណិជ្ជកម្មមាន សមមិត្ត វ៉ាន់ (យើងអាចសន្មតថាជា អៀង សារី), សមមិត្ត ហែម (ដែលយើងអាចសន្មតបានថាជា ខៀវ សំផន) និងសមមិត្ត ទូច។

មុននឹងចូលទៅនិយាយអំពីកិច្ចប្រជុំប្រចាំខែរបស់រដ្ឋាភិបាលនៃគណៈរដ្ឋមន្ត្រី មុនពេលឈប់សម្រាកខ្ញុំសូមបង្ហាញឯកសារចុងក្រោយ គឺឯកសារផ្សព្វផ្សាយរបស់ក្រសួងអប់រំ ដែលចុះឆ្នាំ៧៧។ ឯកសារនេះមានលេខ E3/ -- សូមទោស! ឯកសារនេះ មានលេខ D366/7.1.63។

[១៤:៣៧:៣៤]

ឯកសារនេះ មិនមានលេខ E3 ទេ នៅពេលនេះ។ ឯកសារនេះមានចំណងជើងថា "ភូមិសាស្ត្រនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ"។ ដែលពន្យល់នៅក្នុងមេរៀនទី២ អំពីស្ថាប័នរដ្ឋ ហើយនិងជាពិសេសនៅចំណុច៤ ដែលមានចំណងជើងថា "រដ្ឋាភិបាល"។ ខ្ញុំសូមដកស្រង់ "រដ្ឋាភិបាលគឺជាអង្គការនីតិប្រតិបត្តិច្បាប់ និងមាគ៌ានយោបាយដែលកំណត់ដោយសភាតំណាងប្រជាជនកម្ពុជា ហើយដែលខ្លួនត្រូវទទួលខុសត្រូវទាំងស្រុងអំពីសកម្មភាពរបស់ខ្លួន" សូមបញ្ចប់ការដកស្រង់។

រដ្ឋាភិបាល -- ទំនួលខុសត្រូវរបស់រដ្ឋាភិបាលនោះ គឺថាបំពេញយ៉ាងពេញលេញចាប់ពីឆ្នាំ៧០ -- ចាប់ពីខែមេសា ឆ្នាំ៧៦ ហើយក៏មានការបញ្ជាក់នៅពេលប្រជុំនៃគណៈរដ្ឋមន្ត្រីដំបូងនៃកម្ពុជាប្រជាធិបតេយ្យ ដែលខ្ញុំនឹងបង្ហាញជូននៅក្រោយពេលឈប់សម្រាក លោកប្រធាន។

[១៤:៣៨:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការបង្ហាញនូវឯកសារភស្តុតាង។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ បាទ មុនសម្រាកអម្បាញ់មិញនេះ គឺថាយើងកំពុងតែនិយាយអំពីការដែលរដ្ឋាភិបាលនៅសម័យនោះ គឺថានៅឆ្នាំ១៩៧៦ បាននិយាយថា នឹងទទួលខុសត្រូវចាប់ពី

ពេលដែលរបបហ្នឹងបានផ្លាស់ប្តូរធាតុពិតរបស់ខ្លួន គឺថាចាប់ពីឆ្នាំ១៩៧៦ នោះ គឺថា របបនោះទទួលខុសត្រូវយ៉ាងពេញលេញ អំពីកាតព្វកិច្ចរបស់ខ្លួន និងសកម្មភាពរបស់ខ្លួន។ បាទ យើងនឹងឃើញថា នៅក្នុងឯកសារ E3/817, ហើយនិងឯកសារ E3/818 ដូច្នេះគឺថាមានយោងពីរនេះ ចំពោះឯកសារតែមួយហ្នឹង គឺថានិយាយអំពីទំនួលខុសត្រូវរបស់រដ្ឋាភិបាល ហើយនៅក្នុងសំណុំរឿងថា មានកំណត់ហេតុកិច្ចប្រជុំគណៈរដ្ឋមន្ត្រីពីរ គឺថា នេះជាប្រជុំលើកទី១ ដែលខ្ញុំនឹងលើកយកមកជាសម្រង់នៅថ្ងៃនេះ គឺថាមានចំណងជើងថា "ប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ បទឧទ្ទេសនាមរបស់សមមិត្តលេខានៅក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ថ្ងៃទី២២ មេសា ឆ្នាំ១៩៧៦"។ បាទ សម្រង់ទីមួយនេះគឺថាទាក់ទងទៅនឹង ធាតុ និងការទទួលខុសត្រូវរបស់រាជរដ្ឋា -- រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមដកស្រង់ នៅទំព័រទី១ ជាភាសាខ្មែរគឺ ERN 00072553, ជាភាសាអង់គ្លេស គឺថា 00143461, ជាភាសាបារាំង ទំព័រទី១ គឺថា ERN 00548894។ បាទ លេខា ប៉ុល ពត និយាយយ៉ាងដូច្នេះ ខ្ញុំសូមដកស្រង់ដូចតទៅៈ

[១៥:០៤:១៥]

"រដ្ឋាភិបាលយើង មិនមែនជារដ្ឋាភិបាលផ្សំដូចមុនទេ គឺថា យើងធ្វើការងារល្អ ការងារ -- ចំណេញ ឬខាត ទាំងនៅក្នុង ក៏ដូចជាទាំងនៅក្រៅប្រទេសដែរ ហើយក៏ដូចជាធៀបទៅនឹងមិត្ត ឬក៏សត្រូវដែរ គឺថា យើងទទួលខុសត្រូវទាំងស្រុងតែម្តង។ ពុំមានអ្នកណាផ្សេងទៀតក្រៅពីយើងនោះទេចាប់ពីពេលនេះទៅនោះ"។ បាទ នៅឆ្ងាយជាងនេះបន្តិចទៀត "ដូច្នេះ សមាជិករដ្ឋាភិបាល ហើយនិងសមាជិករបស់គណៈកម្មាធិការគ្រប់ផ្នែកត្រូវតែក្តាប់នូវធាតុពិតរបស់រដ្ឋាភិបាលយើង ហើយនិងតួនាទីរបស់យើង ហើយខិតខំបំពេញភារកិច្ចឲ្យបានល្អទៅតាមមាគ៌ារបស់បក្ស"។ បាទ សូមបញ្ចប់ការដកស្រង់។

[១៥:០៥:០០]

បាទ ខ្ញុំសូមអានសម្រង់មួយទៀត នៅឯកសារដដែលនេះគឺថា ឯកសារ E3/817 ទំព័រ ERN ជាភាសាខ្មែរ 00072761, ជាភាសាអង់គ្លេសគឺ 00143467, ហើយជាភាសាបារាំងគឺ 00548899 រហូតដល់ 8900។ "នៅចំណងជើងទី៣ ពីភារកិច្ចរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត កំណត់ភារកិច្ចបួន សំខាន់គឺថា អនុវត្តធម្មនុញ្ញ ហើយនិងការពារប្រទេស កសាងប្រទេស ហើយនិងប្រមូលកម្លាំងជាមិត្តនៅលើពិភពលោក"។ ខ្ញុំសូមដកស្រង់ នូវអ្វីដែលគាត់និយាយទាក់ទងទៅនឹងការ

ការពារជាតិគឺថា ចំណុចទី២ "ជាការសំខាន់ណាស់ ក្នុងការការពារអំណាចបដិវត្តន៍ លទ្ធផលបដិវត្តន៍ ការពារបក្សប្រជាជន កងទ័ព១បដិវត្តន៍ ឯករាជ្យ អធិបតេយ្យភាព។ល។ ប្រឆាំងនូវគ្រប់រូបភាពដែលខ្លាំងធ្វើសកម្មភាពទាំងចំហ ទាំងសម្ងាត់។ យើងត្រូវតែប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច"។ បាទ សូមបញ្ចប់ការដកស្រង់។

[១៥:០៧:៤៦]

យើងនឹងត្រឡប់មកនិយាយអំពីការអនុវត្ត នៃក្រសួងទាំងអស់អំពីមាគ៌ានយោបាយ ប្រឆាំងនឹងសត្រូវ។ បាទ ខ្ញុំសូមលើកយកឯកសារ ដែលពាក់ព័ន្ធទៅនឹងក្រសួងការបរទេស។ ឯកសារទី១ គឺយើងធ្លាប់បានលើកឡើងនៅក្នុងសវនាការនេះហើយ ក៏ប៉ុន្តែជាលក្ខណៈទូលំទូលាយ។ ដូច្នេះវាមានសារៈសំខាន់ក្នុងការលើកចំណុចមួយចំនួនមកនិយាយទៀតគឺថា ឯកសារ E3/522 ដែលមានលេខយោងមួយទៀតគឺថា E3/926 ដែលគឺជា កូនជាសៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេស ដែលហាក់ដូចជានិយាយទាក់ទងតែក្នុងឆ្នាំ១៩៧៦ នោះទេ។ បាទ ឥឡូវ ខ្ញុំសូមគូសបញ្ជាក់ផងដែរថា ទាក់ទងនឹងឯកសារនេះគឺថា មានសំណៅត្រឹមត្រូវមួយ ហើយនិងសំណៅមិនត្រឹមត្រូវមួយ ជាភាសាខ្មែរ។ សំណៅត្រឹមត្រូវនោះ គឺថាមានលេខ ERN 00427814 រហូតដល់ 00427964។

បាទដោយអកុសល គឺថាដូចដែលខ្ញុំបានចង្អុលបង្ហាញពីមុនមកហើយគឺថា សំណៅជាភាសាបារាំងនោះ ត្រូវបានបកប្រែចេញពីសំណៅមិនត្រឹមត្រូវ ហើយអ៊ីចឹងនៅក្នុងសំណៅនេះមានផ្នែកមួយចំនួនដែលខ្វះខាត ហើយលំដាប់លំដោយទំព័រនោះក៏បញ្ច្រាសដែរ ហើយក៏ជាន់គ្នាផងដែរ។ ទាក់ទងនឹងការទំនាក់ទំនងនៅផ្នែក នៅក្នុងក្រសួងការបរទេស ហើយនិងរចនាសម្ព័ន្ធ ហើយនិងតួនាទីរបស់ប្រធានក្រសួងនេះ ហើយនិងផ្នែកមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាការផ្សព្វផ្សាយនៅក្នុងក្រសួងការបរទេសជាដើម។ ឯកសារនេះ មានច្រើនផ្នែក ដែលមាន ដែលនិយាយអំពីកិច្ចប្រជុំមួយចំនួនដែលធ្វើឡើងនៅ ប-១ ហើយក៏មានការប្រជុំនៅតាមសាខា ដែលចុះថ្ងៃទី២២ ឧសភា ឆ្នាំ១៩៧៦ និងការប្រជុំនៅក្រសួងការបរទេស ប-១ ចុះថ្ងៃទី១០ កក្កដា ឆ្នាំ១៩៧៦ ហើយនិងផែនការនៃក្រសួងនេះនៅក្នុងឆ្នាំ១៩៧៦ ដែរ ខែ៧។

[១៥:០៩:៤៧]

ហើយមានការប្រជុំជីវទស្សន៍ និងរិះគន់ ឬក៏ស្វ័យទិតៀនជាដើម ដែលមានបង វ៉ាន់ ជាអ្នក -- ជាធ្វើប្រធាន ជាអ្នកដឹកនាំ។ ហើយមានការប្រជុំមួយទៀត ដែលចុះនៅខែធ្នូ ឆ្នាំ១៩៧៦ ផងដែរ។ តើ

ឯកសារទាំងអស់នេះ ឯកសារនេះនិយាយអំពីអ្វី? គឺថានិយាយអំពីរចនាសម្ព័ន្ធនៃក្រសួងការបរទេស។ ឯកសារនេះនិយាយលម្អិតអំពីផ្នែក និងសាខាមួយចំនួននៃក្រសួងនៅទំព័រភាសាខ្មែរគឺថា 00427849, ហើយលក្ខណៈពិសេសនៃសំណៅជាភាសាខ្មែរនោះ កាលណាយើងបើកទៅឃើញហាក់ដូចជាកាលវិភាគ ឬ *កាឡង់ឌីយេ* នោះ ហើយមានចុះថ្ងៃខែដូច ១៤, ១៥ មីនា ជាដើម។ អង់គ្លេស ERN គឺ 00003266, ជាភាសាបារាំង 00657989។ បាទ នេះជាផ្នែកផ្សេងៗនៃមន្ទីរ ប-១ គឺផ្នែកឃោសនាអប់រំ, ទី២ គឺផ្នែកមន្ទីរ, ផ្នែកទី៣ គឺថាផ្នែកបង្កបង្កើនផល, ទី៤ គឺថាផ្នែកនយោបាយ, ទី៥ គឺផ្នែកពិធីការ, ទី៦ គឺថាផ្នែកលេខាដ្ឋាន និងរដ្ឋបាល ហើយជាភាសាអង់គ្លេសថាជាផ្នែកលេខាដ្ឋានហើយនិងសភា, ហើយផ្នែកទី៧ នេះគឺអាកាសចរណ៍ស៊ីវិល។

[១៥:១១:៤៤]

បាទ មានផ្នែកមួយទៀត ដែលមានចំណងជើងថា "កិច្ចប្រជុំថ្ងៃទី១៥ ធ្នូ ឆ្នាំ១៩៧៦ ដែលនិយាយពីស្ថិតិបុគ្គលិកនៃក្រសួងការបរទេសនេះនៅឆ្នាំ១៩៧៦ ហើយនិងការកំណត់ផ្នែកនៃបុគ្គលិកនៅក្រសួងនេះជាច្រើនផ្នែក"។ ERN ជាភាសាខ្មែរគឺ 00427928, ជាភាសាអង់គ្លេសគឺ 00003221, ជាភាសាបារាំងគឺ 00657891។ យើងថាមានសរសេរដូចតទៅនេះ៖ "មានមនុស្ស -- បុគ្គលិកជាច្រើននៅតាខ្មៅ យុវជន ១២នាក់ បួននាក់ល្អ ប្រាំមួយនាក់មធ្យម ហើយពីរអន់។ ហើយទំព័រដដែលនេះ នៅខាងក្រោមបន្តិចទៀតនោះ ដែលអ្នកមកពីរណសិរ្ស ម-១ ចង់រៀនសូត្រនយោបាយ នៅក្រសួង ប-១ គឺថាមានមនុស្ស៤៤០នាក់ គឺ -- ៦៤០នាក់ ហើយក្មេង១៥៤ -- កុមារ ៥៤នាក់។ មានឯកសារមួយទៀតនៅផ្សារគឺថាមានមនុស្ស៨៨នាក់ ហើយនៅផ្នែកកាត់ដេរ១៨នាក់។ នៅសៀមរាបមាន២៥នាក់, កំពតមាន២០នាក់, កំពង់សោមមាន៣៦នាក់។ មន្ទីរ ប-១ មាន១៨០នាក់ នៅម-១ មាន១១៨នាក់ ហើយក្នុងនោះមានក្មេង៨ -- កុមារ៨នាក់ ហើយមាននិយាយពីផ្ទះ ហើយនិងស្ថានទូតចិន ឬក៏កូរ៉េផងដែរ។

[១៥:១៣:៤៦]

ទាក់ទងទៅនឹងរចនាសម្ព័ន្ធដែលមាននៅក្នុងឯកសារនេះ គឺថាអ្វីដែលសំខាន់ជាងគេទៅនោះ គឺមានចុះនៅខែធ្នូ ឆ្នាំ១៩៧៦ ដែលមានទំព័រជាភាសាខ្មែរគឺ ERN 00427949, ហើយជាភាសាអង់គ្លេស 00003336 រហូតដល់ 37 នៅចុងកន្ទុយ។ អត់ទាន់មានបកប្រែជាភាសាបារាំងទេ។ ជា -- ERN ជាភាសាខ្មែរសូមអានម្តងទៀតគឺ 00427949, ជាភាសាអង់គ្លេសម្តងទៀតគឺ 00003336 ទៅដល់ 37។

មិនទាន់មានការបកប្រែជាភាសាអង់គ្លេសនៅឡើយទេ -- អ៎ ជាភាសាបារាំងនៅឡើយទេ។ ឯកសារនេះនិយាយអំពីរចនាសម្ព័ន្ធ ប-១ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះមិនទាន់មានការបកប្រែជាភាសាបារាំងនៅឡើយនោះទេ។

"លេខ៦ បញ្ហាចាត់តាំងគណៈសាខា។ ក្រសួង បងវ៉ាន់ លេខា, សមមិត្ត ហុង អនុលេខា។ ៣.សមមិត្ត រឿន សមាជិក, ៤.សមមិត្ត វ៉ែន សមាជិក, ៥.សមមិត្ត ជាម សមាជិក"។ សូមបញ្ចប់ការដកស្រង់។

បាទ យើងមានសមាជិកគណៈកម្មការនេះជាច្រើន ដែលបានមកផ្ដល់សក្ខីកម្មនៅទីនេះ។ ចំណុចទី២ ឬក៏ជំពូកទី២ នេះនិយាយអំពីផ្នែកមួយចំនួននៃឯកសារ E3/522 ដែលនិយាយអំពីការស្វ័យទិតៀន។ គឺថាមាន យើងអាចកំណត់នូវកម្មាភិបាលនៃក្រសួងនេះមួយចំនួន នៅក្នុងកិច្ចប្រជុំជីវទស្សន៍។ ផ្នែកនេះមានចំណងជើងថា "យោបល់កសាងនៃសមូហភាព" ចុះថ្ងៃទី១១ ធ្នូ ឆ្នាំ១៩៧៦ ហើយនិងលាតសន្ធឹងជាទំព័រភាសាខ្មែរនេះគឺពីទំព័រ សូន្យ -- ជា ERN គឺថា 00427907 ពីទំព័រនេះទៅដល់ទំព័រ 00427926 ហើយជាភាសាអង់គ្លេស គឺពីទំព័រ 00003304 ទៅដល់ 00003320។ បាទមិនអាចឲ្យទំព័រពាក់ព័ន្ធទាំងអស់នេះទេ ជាភាសាបារាំងនោះ ពីព្រោះថាទំព័រវាច្របូកច្របល់គ្នា។

[១៥:១៧:១០]

កម្មាភិបាលដែលធ្វើស្វ័យទិតៀនខ្លួនឯងនោះ ដូចជាសមមិត្ត នូ, ជាម បាទ យើងអាចសន្និតថាប្រហែលជា ភី ភួន ហើយ ឌៀន, មឿន, រួន, ធី, ហុង បាទ យើងអាចសន្និតថាប្រហែលជា សួរ ហុង ហើយ ទូច, ស៊ូ ដែលក្នុងនេះមានបញ្ជាក់ថា ស៊ូ នេះនៅប្រទេសថៃ។ ហើយមានអ្នកផ្សេងទៀតឧទាហរណ៍ដូចជា គង់ យើងអាចសន្និតថាប្រហែលជា សួង ស៊ីគឿន ហៅ គង់ ហ្នឹងហើយ។ បុគ្គលទាំងអស់នេះ គឺថាមានលើកឡើងអំពីគុណសម្បត្តិ និងគុណវិបត្តិរបស់គាត់។ ខ្ញុំសូមលើកឧទាហរណ៍នៅទំព័រជាភាសាខ្មែរគឺ 00427850 បាទខ្ញុំសូមអានម្ដងទៀត 00427850, បាទជាភាសាអង់គ្លេសគឺ 00003267 ជាភាសាបារាំងគឺ 00657884។ បាទនេះគឺជាការធ្វើជីវទស្សន៍របស់សមមិត្ត មឿន ខ្ញុំសូមដកស្រង់ ចំណុចទី២ លើផ្នែកនយោបាយពីគុណវិបត្តិរបស់គាត់។ "គឺថាគាត់ហ្នឹងមិន -- គាត់ច្របូកច្របល់បន្ទាប់ពីឮបានថាប្រជាជនទាំងអស់នោះគ្មានអ្វីហូបចុក។ គាត់មិនដាចខាត។ នៅពេលការសិក្សាគឺថាឮនិយាយថា ខ្មាំងទាំងអស់ហ្នឹងពួននៅក្នុងហ្នឹង ហើយគាត់ហ្នឹងក៏ភ័យខ្លាច"។ បាទ សូមដកស្រង់ត្រឹមនេះ។

[១៥:១៩:១៤]

បើតាមរយៈការធ្វើជីវទស្សន៍សមមិត្ត មឿន នោះ នៅក្នុងឆ្នាំ១៩៧៦ នោះ យើង -- ធ្វើឲ្យយើងយល់ឃើញថា មានព័ត៌មានមួយចំនួនទាក់ទងទៅនឹងទុរ្គិក្ស ហើយអ៊ីចឹងព័ត៌មាននេះដឹងទៅដល់ក្រសួងការបរទេស។ មាន -- កម្មាភិបាលដែលធ្វើស្វ័យទិតៀននោះ គឺថាពេលដែលធ្វើនោះតែងតែមានការអត្ថាធិប្បាយរបស់ បងវ៉ាន់ អ៊ីចឹងយើងអាចសន្និដ្ឋានថាជា អៀង សារី នៅក្នុងវគ្គនេះដែលធ្វើការស្វ័យទិតៀននេះ។ អ៊ីចឹងគឺថាមានការឆ្លាស់គ្នារវាងការអត្ថាធិប្បាយ ហើយនិងការធ្វើ -- ធ្វើអត្ថាធិប្បាយ ហើយនិងស្វ័យទិតៀន។ ដូចគាត់និយាយទាក់ទងសមមិត្ត នូ, ហុង, មឿន, ជាម, ឌៀន ហើយនិង ស៊ូ ជាដើម។ បាទ ខ្ញុំសូមផ្តល់ឧទាហរណ៍ពីរនៃការអន្តរាគមន៍របស់ បងវ៉ាន់ ដែលយើងអាចចាត់ទុកថាជា អៀង សារី។ ជាបឋម គឺទាក់ទងទៅនឹងការធ្វើស្វ័យទិតៀនរបស់ ហុង -- សួរ ហុង។ ទំព័រខ្មែរ ERN គឺ 00427916, ជាភាសាអង់គ្លេស 00003310, ជាភាសាបារាំង 006557883 *(ស៊ីក)* (00657883) នៅចុងកន្ទុយ។ បាទ ខ្ញុំសូមដកស្រង់អំពីការអត្ថាធិប្បាយរបស់ បងវ៉ាន់ ទាក់ទងនឹងគង់ "មានមូលហេតុ គឺមានការខ្វះខាតបី គឺថាគាត់មិនទាន់ជ្រួតជ្រាបនូវមាគ៌ាបដិវត្តន៍សង្គមនិយម។ ក្តាប់ការតស៊ូវណ្ណៈមិនទាន់ និងរឹងប៉ឹងនូវឡើយ។ ដូច្នេះត្រូវយល់ទំនាស់នៅក្នុងសង្គម។ ចំណុចទី២) សតិអារម្មណ៍អនុធន ចង់រួចខ្លួន សម្រុះសម្រួលវណ្ណៈ។ ចំណុចទី៣) មិនទាន់ជ្រួតជ្រាបលាក់ការណ៍ចាត់តាំងរបស់បក្សនៅឡើយ"។ បាទ សូមបញ្ចប់ការដកស្រង់។

[១៥:២១:៣៨]

អ៊ីចឹងយើងឃើញនៅទីនេះ គឺថាមានប្រធានបទមួយចំនួនដែលនិយាយដដែលៗនៅក្នុងការបោះពុម្ពផ្សាយរបស់បក្ស។ ឧទាហរណ៍ទី២ របស់ -- ការអត្ថាធិប្បាយរបស់ បងវ៉ាន់ អ្វីដែលគាត់លើកឡើងទៅកាន់ ស៊ូ គាត់និយាយទៅកាន់ ស៊ូ ដែលថានៅក្នុងនេះនិយាយថា នៅប្រទេសថៃ។ ជាភាសាខ្មែរគឺ 00427924, ជាភាសាជាអង់គ្លេសគឺថា 00003318 ហើយជាភាសាបារាំងគឺ 00657888។ បាទ វ៉ាន់ និយាយកាន់ទៅ ស៊ូ ទាក់ទងនឹងកង្វះខាតសម្បើមរបស់ខ្លួនយ៉ាងដូច្នេះ "មនោគមន៍វិជ្ជា ហើយនិងគោលជំហរវណ្ណៈពលករមិនទាន់រឹងប៉ឹងនូវឡើយទេ។ គេនៅតែគិតនៅឡើយថា បញ្ញាជនជាអ្នកដឹកនាំ។ បើធៀបទៅនឹងអ្វី អ្នកដែលមានសញ្ញាបត្រនោះត្រូវតែប្រុងប្រយ័ត្នឲ្យបានខ្លាំងជាងនេះទៅទៀត តាមដែលអាចធ្វើទៅបាន"។ សូមបញ្ចប់ការដកស្រង់។

នៅក្នុងឯកសារដដែល ខ្ញុំសូមនិយាយអំពីផ្នែកមួយចំនួនទៀត ដែលនៅក្រោមឱវាទក្រសួងការ

បរទេស ហើយទាក់ទងទៅនឹងខ្មាំង ហើយនិងវណ្ណៈសង្គម។ នៅក្នុងផ្នែកទាក់ទងទៅនឹងការប្រជុំសាខា នៅថ្ងៃទី២២ ឧសភា ឆ្នាំ១៩៧៦ គឺថានៅទំព័រ ERN ជាភាសាខ្មែរ 00427822, បាទខ្ញុំសូមអានម្តងទៀត 00427822, ជាភាសាអង់គ្លេសគឺ 00003247, ជាភាសាបារាំង 00657828។ កម្រិតនយោបាយមហាជននៅខ្សោយនៅឡើយ ហើយមហាជនមិនទាន់ចេះតាមដានខ្មាំងនៅឡើយ ហើយមហាជននោះនៅតែមានលក្ខណៈសន្តិភាពនិយមនៅឡើយ។

[១៥:២៤:១៩]

ហើយពីរបីទំព័រខាងក្រោមមកទៀតនោះ ជាភាសាខ្មែរនៅលេខ ERN 00427825, ជាភាសាអង់គ្លេសគឺ 00003249 ហើយជាភាសាបារាំងគឺ 00657829។ ហើយមានសរសេរដូចតទៅនេះ “ភារកិច្ចត្រូវតែពង្រឹងស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ដោយកម្ទេចឲ្យអស់នូវល្បិចកលខ្មាំងឲ្យខាងតែឈ្នះ ហើយជាដាច់ខាត។ ក្រសួង ប-១ មានមហាជនបួនប្រភេទ គឺថា មហាជនចម្រើន, មធ្យម១, មធ្យមកម្រិត២ ហើយនិងអ្នកដែលមិនទាន់ -- ដែលមិនអាចកែ -- ដែលកែមិនឡើង”។ បាទ សូមបញ្ចប់ការដកស្រង់ត្រឹមនេះ។ បាទ សូមដកស្រង់មួយទៀត នៅក្នុងក្រសួង ប-១ ដដែល គឺថាថ្ងៃ១០ កក្កដា ឆ្នាំ១៩៧៦ ដែលនៅទំព័រ ERN ជាភាសាខ្មែរនោះគឺ 00427830 បាទ ខ្ញុំសូមអានម្តងទៀត 00427830 ជាភាសាអង់គ្លេសគឺ 00003252 ជាភាសាអង់គ្លេសគឺ 00657832 ទំព័រ -- ចំណងជើងទី១ ស្ថានភាពសង្គមកម្ពុជាប្រជាធិបតេយ្យ មានសរសេរដូចតទៅនេះ “មហាជោគជ័យ ១៧ មេសា ឆ្នាំ១៩៧៥ ជាមហាជោគជ័យជាងជោគជ័យសម័យអង្គរទៅទៀត ពីព្រោះថាចំណុចៈ

ក) នៅក្នុងសង្គមកម្ពុជាមានភាពស្មើគ្នា លែងមានអ្នកមាន លែងមានអ្នកក្រ លែងមានសក្តិភូមិ លែងមានមូលធន លែងមានអនុធន មានតែកម្មករ និងកសិករ”។ បាទ សូមបញ្ចប់ការដកស្រង់។ បាទ នេះគឺជាទស្សនៈនៃការតស៊ូវណ្ណៈ និងគោលដៅនៃភាពស្មើភាព។ ហើយក៏មានយោងទៅនឹងការជម្លៀសប្រជាជនចេញពីក្រុងផងដែរ។ បាទ នៅជាភាសាខ្មែរ ERN គឺ 00427856 ជាភាសាអង់គ្លេសគឺ 0000 3270 រហូតដល់ 71 ជាភាសាបារាំងគឺ 00657846។ បាទ ខ្ញុំសូមដកស្រង់ដូចតទៅ “ការតស៊ូប្រឆាំងនឹងមូលធន យើងបានធ្វើឲ្យខ្មាំងបរាជ័យ។ នៅឆ្នាំ១៩៧៣ យើងបានបង្កើតសហករណ៍។ នៅថ្ងៃទី១៧ មេសា អង្គការរបស់យើងមានភាពប៉ិនប្រសប់ ហើយបានកម្ទេចមូលធននៅក្នុងប្រទេសទាំងមូលតែម្តងនៅលើផ្នែកចាត់តាំង”។ បាទ សូមបញ្ចប់ការដកស្រង់។

[១៥:២៨:០៤]

បាទ ខ្ញុំសូមបន្តដោយនិយាយអំពីវត្តមានខ្មាំងនៅក្នុងជួរ។ បាទ សូមដកស្រង់ដូចតទៅនេះ គឺថា ភាសាខ្មែរ ERN 00427845 ជាភាសាអង់គ្លេស 00003263 -- 62 (សូមទោស) និងជាភាសាបារាំង គឺ 00657991។ បាទ ខ្ញុំសូមអានត្រង់ចំណុចទី២ នៃឯកសារនេះ គឺថា “ការស៊ើរូងផ្ទៃក្នុង ហើយនិងការបង្កប់ខ្លួនក្នុងជួរ។ ប្រទេសយើងត្រូវបាន -- មានខ្មាំងបង្កប់ ហើយនិងស៊ើរូងផ្ទៃក្នុងពី ១ ទៅ៥% យើងត្រូវតែតាមដានប្រវត្តិរូប ហើយនិងឲ្យបានច្បាស់លាស់បំផុត ហើយនិងតាមដានតាមរយៈការប្រជុំជីវទស្សន៍ ជាពិសេសនៅក្នុងក្រសួងការបរទេសតែម្តង។ ស្ថានទូតទាំងអស់ ម៉្យាងគឺថា ចង់ដឹងអំពីការងាររបស់អ្នកដឹកនាំដើម្បីចង់រាយការណ៍ទៅប្រទេសរបស់ខ្លួន រៀងៗខ្លួន។ ហើយម៉្យាងទៀត ពួកគេមានទិសដៅមួយនៅក្នុងស្មារតីរបស់គេ”។ សូមបញ្ចប់ការដកស្រង់ត្រឹមនេះ។

[១៥:២៩:៣៣]

ហើយមានវគ្គមួយទៀតផងដែរ ដែលខ្ញុំចង់អានជូនទៅអង្គជំនុំជម្រះដែរ ជាភាសាខ្មែរគឺ ERN 00427935 -- 40 សូមទោស ហើយជាភាសាអង់គ្លេស 00003331 ហើយជាភាសាបារាំងគឺ 0065 7902។ បាទ ខ្ញុំសូមដកស្រង់ដូចតទៅនេះ៖

ចំណុចទី I ស្ថានភាពខ្មាំងនៅប្រទេសកម្ពុជា

“នៅឆ្នាំ១៩៧៦ គឺជាឆ្នាំគន្លឹះ ឥឡូវនេះខ្មាំងទាំងអស់ហ្នឹងខ្ចាត់ខ្ចាយអស់ហើយ ហើយនិងងាប់។ បដិវត្តន៍បានដកឫស ទាញឫសខ្មាំងទាំងអស់ និងគ្រប់ស្រទាប់វណ្ណៈ ហើយបណ្តាញគិញទាំងអស់នុំងត្រូវបានកម្ទេច។ ក្នុងឋានៈជាវណ្ណៈនោះ ខ្មាំងលែងមានទៀតហើយ ក៏ប៉ុន្តែឥឡូវនេះ វានៅមានចក្រពត្តិអាមេរិកនៅឡើយ។ ហើយបុគ្គល បុគ្គលិករបស់ សេ.អ៊ី.អា ពួកសេរីនិយម ពួក កា.ហ្សេ.បេ ពួកយួនជាដើម។ ទោះបីជាពួកវាដកខ្លួនថយក៏ដោយក៏នៅតែវា នៅបន្តប្រតិបត្តិការរបស់វានៅឡើយ។ ម្យ៉ាងទៀត ខ្មាំងទាំងអស់នោះនៅក្នុងខ្លួនយើងផងដែរ នៅក្នុងកងកម្លាំងរបស់យើង នៅក្នុងជួរកម្មករកសិករ ហើយនិងក្នុងជួរបក្សជាដើម។

[១៥:៣១:០៩]

ដំណើរការបដិវត្តន៍សង្គមនិយមជ្រាលជ្រៅ ហើយនិងមានអានុភាពខ្លាំង ខ្មាំងទាំងអស់នេះយើងត្រូវតែកម្ទេចវាបន្តិចម្តងៗឲ្យអស់តែម្តង”។ បាទ សូមបញ្ចប់ការដកស្រង់។

បាទ មានផ្នែកមួយទៀតនៅទីបញ្ចប់នេះ ដែលមានលេខ ERN ជាភាសាខ្មែរ 00427946, ជាភាសាអង់គ្លេស គឺ 00003334 ទៅដល់ 35, ហើយជាភាសាបារាំងគឺ 00657905។ បាទ ខ្ញុំសូម

ដកស្រង់ "ជាការចាំបាច់ណាស់ដែលត្រូវតែត្រៀមលក្ខណៈលក្ខខណ្ឌដើម្បីធានាសន្តិសុខ ហើយនិងតាមដានជីវប្រវត្តិនៅក្នុងក្រសួងទាំងអស់ ហើយនិងប្រមូលអាវុធ ហើយនិងគ្រឿងរំសេវ ហើយនិងបញ្ជូនទៅដល់អគ្គសេនាធិការ ហើយត្រូវតែតាមដានខ្មាំងនៅក្នុងក្រសួង"។ ដូច្នេះយើងសង្កេតឃើញថា នៅគឺថា ប្រធានបទតាមដានខ្មាំងទាំងអស់នេះ គឺថាមានលើកឡើងរហូតនៅក្នុងកិច្ចប្រជុំស្វ័យទិតៀននៅក្រសួងការបរទេស។

[១៥:៣២:៣៦]

បាទ ឥឡូវខ្ញុំសូមចូលទៅនិយាយឯកសារមួយទៀត គឺថា ឯកសារ E3/857 នេះជារបាយការណ៍ក្រសួងការបរទេសដែលមានចំណងជើងថា "សហការជាមួយនឹងអង្គភាពទាំងអស់" ចុះថ្ងៃទី ១២ កញ្ញា ១៩៧៨។ ហើយនេះ គឺជាឯកសារដែលបោះពុម្ពផ្សាយក្រោយមកហើយ គឺថាដែលផ្ទៀបនឹងឯកសារទាំងប៉ុន្មាននេះដែលខ្ញុំអាននេះ។ បាទ ខ្ញុំសូមអានដកស្រង់ឯកសារចំនួន សម្រង់បួននៃឯកសារនុ៎ង។ សម្រង់ទី១ គឺមាននៅទំព័រជាភាសាខ្មែរ 00086707 បាទ សូមអានម្តងទៀត 00086707, ជាភាសាអង់គ្លេស គឺ 00355487, ភាសាបារាំងគឺ 00811327។

ខ្ញុំគិតថា នៅទំព័រដំបូងនៃឯកសារនេះ៖

<u>សរុបលើសេចក្តីរាយការណ៍ពីគ្រប់អង្គភាព</u>

ទី១) អំពីសកម្មភាពលើខ្មាំង ក្នុងសន្និបាតក្រសួងយើង យើងបានកត់សម្គាល់ឃើញថា យើងបានកម្ទេច និងបោសសម្អាតជាមូលដ្ឋានខ្មាំងជា សេ.អ៊ី.អា, កា.ហ្សេ.បេ និងយួនលេបទឹកដី។ កម្ទេចនិងបោសសម្អាតជាមូលដ្ឋាន មានន័យថា ក្បាលម៉ាស៊ីនធំៗរបស់ខ្មាំងដែលធ្វើផែនការ និងដឹកនាំចង់ធ្វើរដ្ឋប្រហារដណ្តើមយករដ្ឋអំណាចពីកសិករ កម្មករក្រីក្រយើងទៅវិញ ត្រូវយើងកម្ទេច និងបោសសម្អាតហើយ។

[១៥:៣៤:៤២]

យើងបានឯកភាពគ្នាលើបញ្ហាបោសសម្អាតខ្មាំងទាំងនេះ ទន្ទឹមនឹងនេះយើងក៏បានឯកភាពគ្នាថា ខ្មាំងមិនទាន់អស់នៅឡើយទេក្នុងក្រសួងយើង ក៏ដូចក្នុងអង្គភាពនីមួយៗ"។ សូមបញ្ចប់ការដកស្រង់។

សម្រង់ទី២ គឺនៅទំព័រដដែល ហើយនិងបន្តរហូតដល់ទំព័រក្រោមទៀត។ ខ្ញុំសូមដកស្រង់ "បើយើងមើលក្នុងក្រសួងទាំងមូល យើងឃើញថា ៩៨ភាគរយ ក្នុងក្រសួងទាំងមូលបានស្អាតហើយ គឺ ៩៨ ភាគរយល្អ យល់ពីការបោសសម្អាតខ្មាំង។ ក៏ប៉ុន្តែនៅពីរភាគរយទៀត កំពុងធ្វើសកម្មភាព។ ហើយបន្ត

មកទៀត យើងត្រូវតែប្រឹងប្រែងធ្វើយ៉ាងម៉េចកុំឲ្យពីរភាគរយនេះ រីកឡើង. ពីព្រោះថា បើមិនអ៊ីចឹងទេ ពួកហ្នឹងនឹងពង្រីកខ្លួនឡើងពីពីរភាគរយ ទៅបីភាគរយ បួនភាគរយ ជាបន្តបន្ទាប់។ ដូច្នេះ យើងត្រូវតែហ៊ុំព័ទ្ធវា ពង្រួមក្ដោបវាឲ្យមកនៅមួយភាគរយកន្លះ ឬមួយភាគរយ ឬក៏កន្លះភាគរយ។ ក្រសួងយើងជានិយាយជារួមមានការភ្ញាក់រឭកខ្ពស់ដែរ មានហេតុភេទអ្វីបន្តិចបន្តួច បងប្អូនចេះចាប់អារម្មណ៍លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នហើយរាយការណ៍។

[១៥:៣៦:១៩]

ឧទាហរណ៍ខ្មាំងវាបន្លឺថា “បន្តិចទៀតចាប់អស់ហើយ នៅតែបង ខៀវ សំផន ទេ” មិត្តយើង ក៏ចេះវិភាគ ហើយរាយការណ៍ដល់យើង ចាប់ហើយសួរចម្លើយ យើងឃើញខ្សែខ្មាំងច្បាស់។ ដូច្នេះ ក្រសួងយើងល្អដែរ តែត្រូវប្រយ័ត្នអាពីរភាគរយ ពីព្រោះពួកនេះវាធ្វើតាមបញ្ជាមេវា។ យើងត្រូវលើកកម្ពស់ប្រុងប្រយ័ត្នបដិវត្តន៍មែនទែន ពីព្រោះក្រសួងយើងទាក់ទងទូតបរទេសច្រើនណាស់”។ សូមបញ្ចប់ការដកស្រង់។

សម្រង់ទី៣ គឺនៅទំព័រជាភាសាខ្មែរ 00086708 ទៅដល់ 09, ជាភាសាអង់គ្លេស 00355489, ជាភាបារាំង 008711 -- សូមអភ័យទោស សូមម្ដងទៀត 008711328 (ស៊ីក) (00811328) ទៅដល់ 29។ ខ្ញុំសូមអានចំណុចទី៤ បញ្ហាពង្រឹងពង្រីកអង្គការគ្រប់បែបយ៉ាង “ប្រមាណពេលក្រោយមកនេះ ចំនួនរបស់បក្សយើងគឺបានថយចុះ ដោយសារតែមានការបោសសម្អាតខ្មាំង ក៏ប៉ុន្តែគុណភាពគឺនៅល្អដដែល។ បងប្អូនយើងយល់ដឹងច្បាស់ ហើយបានយល់អំពីកល់ល្បិចរបស់ខ្មាំងបង្កប់នៅក្នុងចំណោមយើង ដែលបង្កប់ចូលយ៉ាងជ្រៅ។ ចុះមកក្រោមទៀត នៅក្នុងការពង្រីកនេះ យើងត្រូវគិតគូរពីវណ្ណៈភាព យើងពង្រីកក្នុងវណ្ណៈកម្មករកសិករក្រ កណ្ដាល ថ្នាក់ក្រោម។ ទន្ទឹមនេះ យើងត្រូវពិនិត្យមើលប្រវត្តិរូប សីលធម៌បដិវត្តន៍ សកម្មភាពបដិវត្តន៍ឲ្យបានហ្មត់ចត់ ហើយមានមហាជនយល់ស្របផងដែរ”។ សូមបញ្ចប់ការដកស្រង់។

[១៥:៣៨:៥៤]

សម្រង់ទី៤ និងជាសម្រង់ចុងក្រោយនៃឯកសារនេះ ដែលជាសម្រង់ដ៏សំខាន់ពាក់ព័ន្ធទៅនឹងខ្មាំង។ នៅទំព័រជាភាសាខ្មែរ ERN 00086710 ទៅដល់ 11, ជាភាសាអង់គ្លេស 00355491, ជាភាសាបារាំង 00811331។ ចំណងជើងទី៣ “ភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម” ខ្ញុំសូមដកស្រង់ “នេះក៏ជាភារកិច្ចមួយសំខាន់ ខ្លះបំពេញភារកិច្ចស្ទួលបានល្អ តែទស្សនៈគឺនាយទុន អនុធន។ យើងចាត់

ទុកថា មិនល្អទេ ពីព្រោះបំពេញភារកិច្ច បន្តធ្វើបដិវត្តន៍សង្គមនិយម មិនបានល្អ។ បន្តធ្វើបដិវត្តន៍សង្គមនិយម គឺកម្ទេចកម្មសិទ្ធិឯកជន ពុះពារធ្វើការតស៊ូវណ្ណៈ គោលជំហរដាច់ខាតចំពោះខ្មាំង បែងចែកសត្រូវ និងយើង ឲ្យច្បាស់ កុំច្រឡូកច្របល់ មានព្រំដែនច្បាស់លាស់ កម្ចាត់បុគ្គលស្វនគួ មិនគិតមកខ្លួនឯង គិតគូរដល់អ្នកដទៃ"។ សូមបញ្ចប់ការដកស្រង់។ ពាក់ព័ន្ធទៅនឹងការបែងចែករវាងសត្រូវ ហើយនិងយើងនោះ មានការសរសេរដូចទៅនេះ នៅក្នុងទំព័រជាភាសាខ្មែរ 00086712, ជាភាសាអង់គ្លេស 00355493, ជាភាសាបារាំង 00811332។ ខ្ញុំសូមដកស្រង់៖ "ពុះពារអប់រំ ៗកសាងឲ្យគេមានគោលជំហរនយោបាយត្រឹមត្រូវ ឲ្យគេចេះបែងចែកយើង និងខ្មាំង។ យើងគឺមានន័យថាបក្ស បដិវត្តន៍ប្រជាជន រដ្ឋអំណាច កម្មករ កសិករ គឺអ្វីដែលបដិវត្តន៍។ ឯខ្មាំងវិញ គឺអ្វីទាំងអស់ដែលមិនបដិវត្តន៍ដែលប្រឆាំងនឹងបដិវត្តន៍។ ត្រូវបែងចែកឲ្យដាច់អ្វីដែលជាខ្មាំង អ្វីដែលជាបដិវត្តន៍ កុំឲ្យនៅប្រទាញប្រទង់ច្រឡូកច្របល់គ្នា"។ សូមបញ្ចប់ការដកស្រង់។

[១៥:៤១:៤៩]

ខ្ញុំនឹងត្រឡប់មកនិយាយអំពីរចនាសម្ព័ន្ធក្រសួងការបរទេស និងមុខតំណែងរបស់កម្មាភិបាលមួយចំនួន ក៏ប៉ុន្តែដើម្បីឲ្យបានយល់អំពីរចនាសម្ព័ន្ធក្រសួងកម្មាភិ -- ក្រសួងសុខាភិបាល -- (សូមទោស) ក្រសួងសង្គមកិច្ចនោះ គឺយើង -- ក្រសួងការបរទេសនោះ គឺយើងត្រូវពិនិត្យមើលទៅលើប្រវត្តិរូបសំខាន់ៗ។ ឧទាហរណ៍ ខ្ញុំសូមយកឯកសារ E1 -- (សូមទោស) E3/1154 -- 1534 ដែលជាបញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា "បញ្ជីឈ្មោះអ្នកទោស ស-២១"។ ឯកសារនេះមិនមានជាភាសាបារាំងទេ។ ឯកសារនេះមានពីរទំព័រ ដែលយើងមានឃើញលេខ ERN 00087007 ជាភាសាខ្មែររហូតទៅដល់ 09, ជាភាសាអង់គ្លេស 00181667 រហូតទៅដល់ 69។ កាលបរិច្ឆេទចុងក្រោយដែលក្នុងឯកសារនេះ គឺថ្ងៃទី១៥ មេសា ឆ្នាំ៧៨។ នេះជាបញ្ជីដែលមានឈ្មោះ៤៣នាក់ ប្រសិនបើយើងបញ្ជាំងនៅលើអេក្រង់ យើងឃើញថាក្នុងចំណោមអ្នកទាំង៤៣នេះ គឺមាននិស្សិតជាង១០នាក់ដែលមកពីបរទេស ជាពិសេសមកពីប្រទេសបារាំង។ ដូច្នេះយើងអាចចាត់ទុកថា ឯកសារនេះ គឺជាឯកសាររបស់ក្រសួងការបរទេស វាពាក់ព័ន្ធទៅនឹងក្រសួងការបរទេស ហើយមានកម្មាភិបាល យុទ្ធជនមកពីក្រសួងការបរទេស ឧទាហរណ៍ដូចជានៅជួរទី៣ លោក ខៀវ -- លោក កែវ ជៀន យុទ្ធជនមន្ទីរបឹងត្របែក ចូលនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ៧៨។ ដូច្នេះក្នុងនេះយើងសង្កេតឃើញថា បើតាមឯកសារនេះ គឺថាមន្ទីរបឹងត្របែកនេះ គឺស្ថិតនៅក្រោមឱវាទរបស់ក្រសួងការបរទេសទៅហើយតាំងពីដើមឆ្នាំ៧៨។

នៅក្នុងបញ្ជីនេះមានយុទ្ធជនមន្ទីរ ប-៦២ ឬ ប-៦៤ ហើយមានកម្មាភិបាលស្ថានទូតបរទេស ជាពិសេសនៅលេខ២០ គឺ មាយ ទូច ឯកអគ្គរដ្ឋទូតនៅឡាវ, លេខ៣៦ លាន សិរីវុទ្ធ លេខាទី៣នៅប៉េកាំង។ អ្នកទាំងអស់នេះ គឺជាអ្នកដែលយើងបាននិយាយរួចមកហើយនៅក្នុងសវនាការ នៅចំពោះមុខអង្គជំនុំជម្រះ ហើយនិងមានកម្មាភិបាល ប-១ ដូចជានៅលេខ២១ ឈ្មោះ វ៉ាន់ ពីនី ដែលជាអនុរដ្ឋមន្ត្រីក្រសួងការបរទេស ឬក៏លេខ ៣១ ស្វាយ បូរី ដែលមកពីផ្នែកព័ត៌មាន និងឃោសនាការ នៃក្រសួងការបរទេស។ ប្រពន្ធគាត់ក៏នៅជាប់ទីនោះដែរ។

ជាចុងក្រោយ ហើយជាការសំខាន់នោះ គឺថាលេខ១៩នៃបញ្ជីនេះ មានកម្មាភិបាលមួយរូបមកពីតំបន់១៥ ដែលជាអនុលេខាតំបន់១៥ គឺឈ្មោះ ទេព ហៃ ដែលចូលមកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ៧៨។ ហើយគាត់ក៏នៅក្នុងបញ្ជីរបស់ក្រសួងការបរទេសផងដែរ។

[១៥:៤៥:៤២]

យើងនៅសល់ពេលតែ១៥នាទីទេ លោកប្រធាន ខ្ញុំមិនអាចចប់នៅថ្ងៃនេះបានទេ ដោយសារព្រឹកមិញនេះយើងចាប់ផ្ដើមនៅម៉ោងប្រាំបួនកន្លះទៅហើយ។

ដូច្នេះឥឡូវនេះខ្ញុំចាប់ផ្ដើមនិយាយអំពីក្រសួងពាណិជ្ជកម្មម្ដង។ ពាក់ព័ន្ធទៅនឹងគណៈកម្មាធិការពាណិជ្ជកម្ម យើងដឹងហើយថា សមាសភាពមានរៀបរាប់នៅក្នុងសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ថ្ងៃទី១៩, ២០, ២១ ខែមេសា ឆ្នាំ៧៦ គឺលេខឯកសារ E3/236។ ហើយនៅពេលនោះមានសមមិត្ត វិត, សមមិត្ត ម៉ែន, សមមិត្ត នឹម, សមមិត្ត ជឿន អ្នកទាំងអស់នេះគឺជាសមាជិករបស់គណៈកម្មាធិការពាណិជ្ជកម្ម។ យើងនឹងនិយាយអំពីជោគវាសនារបស់អ្នកទាំងអស់នេះនៅពេលក្រោយ។

[១៥:៤៦:៤៣]

ឥឡូវនេះខ្ញុំចូលទៅដល់ឯកសារទី១ ដែលជាកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ ថ្ងៃទី១៣ មីនា ឆ្នាំ៧៦ ដែលនិយាយអំពីពាណិជ្ជកម្ម គឺឯកសារលេខ E3/233 និង E3/234។ នៅទំព័រដំបូងយើងឃើញថា អ្នកចូលរួមនោះមាន សមមិត្តលេខា គឺយើងអាចគិតថា ប៉ុល ពត ហើយសមមិត្តអនុលេខា នួន ជា, សមមិត្ត វ៉ាន់ ដែលជា អៀង សារី, សមមិត្ត ខៀវ ជា សុន សេន, សមមិត្ត ហែម ជា ខៀវ សំផន, សមមិត្ត១ ធុច ដែលជា កុយ ធួន, សមមិត្ត ឌឿន ដែលជា សឿ វ៉ាស៊ី ហើយនិងសមមិត្តលេខា ទូច។ ក្នុងឯកសារនេះគឺមានបញ្ជាក់ថា សមមិត្ត ធុច ដែលជា កុយ ធួន មានវត្តមាននៅក្នុងកិច្ចប្រជុំអំពីពាណិជ្ជកម្មនៅឆ្នាំ៧៦ គឺចាប់ពីខែមេសា ឆ្នាំ៧៦នោះ យើងលែងឃើញមានបញ្ជីឈ្មោះ -- លែងឃើញ

មានឈ្មោះគាត់នៅក្នុងបញ្ជីរដ្ឋាភិបាលទៀតហើយ។ នៅពេលប្រជុំនោះ គណៈអចិន្ត្រៃយ៍បានសម្រេចបង្កើតនៅក្នុងវិស័យពាណិជ្ជកម្ម នូវគណៈកម្មាធិការសម្រាប់ត្រួតពិនិត្យទំនិញដែលនឹងត្រូវទិញ។ ហើយមានសមាសភាពដូចតទៅនេះ យើងឃើញទំព័រដំបូងនៃឯកសារនោះ មាន៖ សមមិត្តធុច ប្រធាន, សមមិត្ត ហែម សមាជិក ហើយសមាជិកពិគ្រោះយោបល់មានបីនាក់ គឺសមាជិក -- សមមិត្ត វ៉ាន់, វន, ឌឿន ហើយសមមិត្ត ទូច នោះជាសមាជិកកត់ត្រា។

[១៥:៤៩:០០]

ដូច្នេះយើងកត់សម្គាល់ឃើញថា ក្រៅពី កុយ ធួន ដែលជាប្រធាន ដែលក្រោយមកបាត់ខ្លួននោះ គឺមានសមាជិកតែម្នាក់គត់ គឺមានលោក ខៀវ សំផន។

សម្រង់ទី២ និងជាសម្រង់ចុងក្រោយនៃឯកសារ E3/233 ជាភាសាខ្មែរគឺ 00000759, ជាភាសាបារាំងទំព័រ២ ERN 00301332, ជាភាសាអង់គ្លេស 00182649 *(សូមទោស)* គឺ50 ដែលមានសមាសភាពធនាគារ ដែលបង្កើតដោយគណៈអចិន្ត្រៃយ៍។ យើងឃើញថា ដូចជាផ្ទុយពីគណៈកម្មាធិការផ្សេងទៀត ពីព្រោះថានៅក្នុងនេះមានសមមិត្ត ហែម ជាប្រធាន ហើយសមមិត្ត ធុច ទៅជាសមាជិក។ មានសមាជិកពិគ្រោះពិភាក្សាពីរនាក់ គឺសមមិត្ត វ៉ាន់, សមមិត្ត ឌឿន ហើយនិងសមមិត្ត ទូច ជាសមាជិកកត់ត្រា"។ សូមបញ្ចប់ការដកស្រង់។

មានកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍មួយទៀតដែលចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ ដែលនិយាយអំពីបញ្ហាពាណិជ្ជកម្ម។ ឯកសារនេះមានលេខ E3/220 អ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ គឺមានសមមិត្តលេខា, សមមិត្តអនុលេខា, សមមិត្តវ៉ាន់, សមមិត្តវន, សមមិត្តហែម, សមមិត្តឌឿន។ នេះគឺជាសម្រង់ដែលខ្ញុំចង់ដកស្រង់។ ខ្ញុំសូមដកស្រង់ "បន្ទាប់ពីមានរបាយការណ៍របស់សមមិត្តឌឿន ស្តីពីសភាពការណ៍ខាងពាណិជ្ជកម្មមក អង្គប្រជុំបានសម្រេចរៀបចំ៖ ១) គណៈកម្មាធិការពាណិជ្ជកម្ម យកសមមិត្ត ជ័យ ពីកសិកម្មឲ្យមកកាន់កាប់ពាណិជ្ជកម្ម។ សមមិត្ត ឌឿន ចុះទៅពាណិជ្ជកម្មក្នុងរយៈ៣ខែ គឺខែឧសភា, មិថុនា, កក្កដា។ កន្លះថ្ងៃនៅមន្ទីរ គឺយើងដឹងថា គឺជាមន្ទីរ៨៧០ ហើយកន្លះថ្ងៃទៀតនៅពាណិជ្ជកម្ម។ ចំណុចទី២) ទៅហុងកុង ឲ្យសមមិត្ត រិត ទៅហុងកុង ជាមួយមិត្ត សួរម្តងទៀតដើម្បីទាក់ទងទិញអីវ៉ាន់"។ សូមបញ្ចប់ការដកស្រង់។

[១៥:៥២:១១]

ខ្ញុំមានការអត្ថាធិប្បាយតូចមួយពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងចំពោះសមមិត្ត ជ័យ ដែលជា

ជ័យ សួន ហៅ នុន សួន ហៅ សេន។ គាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៦ ហើយនិងត្រូវបានសម្លាប់ចោលនៅមន្ទីរស-២១។ ហើយដើម្បីជាប្រតិចារឹកសវនាការនោះ គឺថាយើងមាននៅក្នុងសំណុំរឿងនូវចម្លើយសារភាពនៅមន្ទីរស-២១ របស់គាត់ដែលមានលេខឯកសារ IS5.69 និងឯកសារមួយទៀតដូចគ្នា គឺលេខ E190.1.14 ចុះថ្ងៃទី -- ចុះខែវិច្ឆិកា ឆ្នាំ១៩៧៦។ ដូច្នេះគឺថា គាត់មិនអាចដើរតួនាទីសំខាន់នៅក្រសួងពាណិជ្ជកម្មបានទេ។

សមមិត្ត ឌឿន ដូចដែលយើងនឹងឃើញបន្តិចទៀតនៅក្នុងឯកសារមួយចំនួននោះ បានបន្តការងារគ្រប់គ្រង និងដឹកនាំខាងផ្នែកពាណិជ្ជកម្មមិនមែនរហូតដល់ខែកញ្ញា ៧៦នោះទេ។ គឺថាយ៉ាងហោចណាស់ គឺគាត់ដឹកនាំទៅដល់ចុងខែកញ្ញា ឆ្នាំ៧៦។ ហើយបន្ទាប់មកគឺមានការប្រគល់ទៅឲ្យអ្នកផ្សេងទៀត។ ឌឿន បានចូលទៅ ស-២១ នៅដើមឆ្នាំ៧៧ ហើយនៅក្នុងសំណុំរឿង យើងមានឯកសារចម្លើយសារភាពរបស់គាត់ដែលចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧ ដែលមានឯកសារលេខ E3/1625។

[១៥:៥៤:១១]

យើងនឹងពិនិត្យមើលថា ហេតុអ្វីបានជាយើងអាចអះអាងថា សមមិត្ត ឌឿន បានបន្តសកម្មភាពការងារពាណិជ្ជកម្មរបស់គាត់រហូតទៅដល់ខែកញ្ញា ឆ្នាំ៧៦នោះ ពីព្រោះថា មានឯកសារបួន មានរបាយការណ៍បួន នៅក្នុងសំណុំរឿងដែលត្រូវបានផ្ញើដោយគណៈកម្មាធិការពាណិជ្ជកម្មជូន បងឌឿន ជាទីគោរពស្នេហា ស្ដីអំពីទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសកូរ៉េខាងជើង។

របាយការណ៍ទាំងបួននេះ មានលេខយោងគឺ IS18.11 ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦។ IS18.12 ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦។ D366/7.1.823។

[១៥:៥៥:០៧]

ខ្ញុំសូមអានម្ដងទៀត D366/7.1.823 ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៧៦ និងឯកសារ IS18.14 ដែលជាឯកសារចុងក្រោយនៅក្នុងសំណុំរឿង និងឯកសារនេះចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦។ ក្រោយពីនេះមកគឺ -- ក្រោយពីពេលនោះមក គឺឯកសារទាំងត្រូវបានផ្ញើជូនទៅខៀវ សំផន លែងផ្ញើជូនឈ្មោះ ឌឿន ទៀតហើយ។ ខ្ញុំបាន -- ខ្ញុំនឹងរៀបរាប់ឯកសារមួយក្នុងចំណោមឯកសារទាំងបួននោះ គឺឯកសារដែលមានលេខ D366/7.1.823 ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៧៦ ឯកសារនេះជារបាយការណ៍ពាក់ព័ន្ធទៅនឹងជំនួបជាមួយមិត្តកូរ៉េខាងជើង ពាក់ព័ន្ធទៅនឹងបញ្ហាពាណិជ្ជកម្ម។ ប្រសិនបើយើងពិនិត្យមើលនៅចុងទំព័រនេះគឺថា ដូចជារបាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្មដែរ គឺមានការចម្លងជូន

មន្ទីរ ក-១ មន្ទីរ៥១ ពាណិជ្ជកម្មក្នុងប្រទេស ហើយនិងឯកសារ។

[១៥:៥៦:៣០]

យើងកត់សម្គាល់ឃើញថា កម្មាភិបាល ៣នាក់នៃខាងពាណិជ្ជកម្មបានចូលរួមតំណាងឱ្យក្រសួងពាណិជ្ជកម្មក្នុងជំនួបជាមួយនឹងពួកកូរ៉េមានសមមិត្ត ឈឿន ដែលជាសមាជិកគណៈកម្មាធិ-ការ។ អ៊ំ ហុង និងសមមិត្ត ម៉ុល ។ ការពិភាក្សាបាននិយាយអំពីការបង្កើតទំនាក់ទំនងពាណិជ្ជកម្ម និងការទំនាក់ទំនងគ្នាជាប្រចាំរវាងកូរ៉េខាងជើង និងកម្ពុជាប្រជាធិបតេយ្យ។

ចាប់ពីចុងខែតុលា ឆ្នាំ១៩៧៦ គឺថាគេលែងផ្ញើទៅ ឌឿន ទៀតហើយ គឺផ្ញើទៅ ហែម ដែលជាខៀវ សំផន នេះគឺបន្តរហូតដល់ចុងបញ្ចប់នៃរបបខ្មែរក្រហម។ យើងឃើញមានរបាយការណ៍ប្រហែលជា ២៨ ត្រូវបានផ្ញើជូនខៀវ សំផន។ នៅចន្លោះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦ រហូតទៅដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៧៨។ របាយការណ៍ ៥ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំជាមួយនឹងកូរ៉េខាងជើង ១០ដង ជាមួយនឹងចិន ហើយនិង ១០ដងទៀតជាមួយនឹងពួកយូហ្គោស្លាវី។ ខ្ញុំជ្រើសរើសយកឧទាហរណ៍ពីរ តំណាងឱ្យប្រភេទនៃឯកសារបែបនេះ។ ឧទាហរណ៍ទី១ គឺឯកសារ IS18.19 ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ឯកសារនេះគឺជារបាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្មផ្ញើជូនបងហែម ជាទីគោរពស្នេហា។ នេះជារបាយការណ៍ដែលមាន ២ទំព័រ អ្វីដែលយើងចាប់អារម្មណ៍នោះគឺមានចំណុច២ នៅក្នុងរបាយការណ៍នេះ។

ទី១) គឺទំព័រដំបូង មានការរៀបរាប់ថា មតិរបស់មិត្តកូរ៉េ៖

១) ចំពោះ*កុំប្រេសស័រ* របស់ម៉ាស៊ីនបូមទឹកនោះ មិត្តកូរ៉េរបស់យើងចង់ដឹងថាយើងចង់បានប៉ុន្មាន?

[១៥:៥៨:៤២]

ម៉ាស៊ីន*កុំប្រេសស័រ*នេះអាចឱ្យម៉ាស៊ីនបូមទឹកដំណើរការបានល្អ។ មតិរបស់យើង យើងរង់ចាំសេចក្តីសម្រេចរបស់អង្គការ មុននឹងផ្តល់ចម្លើយជូនទៅខាងមិត្តកូរ៉េ។

ឃ្លាទី២) គឺខ្ញុំគិតថានៅទំព័រដដែល ចំណុចទី២ បញ្ហាចំនួនល្ង ៨០តោន ហើយនិងកៅស៊ូក្រែប ១.០០០តោន មិត្តកូរ៉េទទួលយក តែលើកក្រោយល្ង យើងគេមិនយកទេ ពីព្រោះរដ្ឋាភិបាលយើងបញ្ជាក់ថា ប្រជាជនកម្ពុជាកំពុងខ្វះខាតស្បៀង។ ពេលណាកម្ពុជាមានស្បៀងគ្រប់គ្រាន់ហើយពេលនោះ យើងទទួលយក។ មតិយើង យើងថ្លែងអំណរគុណចំពោះមិត្តកូរ៉េ ដែលមានការយល់អំពីការខ្វះខាតរបស់

ប្រជាជនយើង ហើយស្បៀងមានការលំបាកតែឆ្នាំនេះទេ ឆ្នាំក្រោយនឹងមានគ្រប់គ្រាន់ហើយ។ យើងសូមកត់សម្គាល់ឃើញថា ការខ្វះខាតស្បៀងនៅប្រទេសកម្ពុជានេះ ត្រូវស្ដែងឡើងយ៉ាងច្បាស់នៅឆ្នាំ៧៦។ ហើយខាងពួកកូរ៉េខាងជើងក៏ដឹងច្បាស់ដែរ ហើយទោះជាយ៉ាងនេះក៏ដោយក៏កម្ពុជាប្រជាធិប-តេយ្យបាននាំចេញនូវស្បៀងអាហារ ដូចបានបង្ហាញនៅក្នុងរបាយការណ៍នេះ។

[១៦:០០:១៩]

លោកប្រធាន ខ្ញុំមិនដឹងថា តើខ្ញុំអាចលើកឡើងពីឯកសារមួយទៀត ឬក៏លោកប្រធានចង់សម្រាកសិននៅពេលនេះ។ សូមលោកប្រធានសម្រេច។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមសម្រាកហើយ ហើយអង្គជំនុំជម្រះមុននឹងប្រកាសផ្អាក អង្គជំនុំជម្រះសូមជម្រាបជូនថា នៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី១១ និងនៅថ្ងៃខានស្អែក ថ្ងៃសុក្រទី១២ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះមិនធ្វើសវនាការទេ ដោយមូលហេតុផ្អែកតាមសេចក្ដីជូនដំណឹង របស់ឯកឧត្ដមប្រធានការិយាល័យរដ្ឋបាល ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ បានអនុញ្ញាតឲ្យបុគ្គលិកខាងភាគីជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឈប់សម្រាកដើម្បីទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

[១៦:០១:១៤]

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ ទី១៨ ខែតុលា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃព្រហស្បតិ៍សប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការ ការដាក់បង្ហាញឯកសារភស្តុតាងជាការបញ្ចប់កិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ រចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យរបស់តំណាងសហព្រះរាជអាជ្ញាបន្ត។ ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ និងក្រុមមេធាវីការពារក្ដី។ សូមភាគី និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ នឹងឲ្យនាំខ្លួនពួកគាត់ទាំងពីរនាក់មកកាន់បន្ទប់សវនាការនេះវិញនៅថ្ងៃព្រហស្បតិ៍ទី១៨ ខែតុលា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*